ក្រសួងសុខាភិបាល
ព្រះរាជាណាចក្រកម្ពុជា

# គោលការណ៍ណែនាំប្រតិបត្តិសម្រាប់ យុទ្ធនាការផ្តល់ថ្នាំបង្ការជំងឺកូវីដ-១៩

# Operational Guidelines for COVID-19 Vaccine Campaign

កម្មវិធីជាតិផ្តល់ថ្នាំបង្ការ
មជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក

ខែមករា ឆ្នាំ ២០២១

# អារម្ភកថា

ថ្នាំបង្ការជំងឺកូវីដ-១៩ គឺជាសមាសភាគអន្តរាគមន៍គន្លឹះ ដើម្បីបង្ការការចម្លងនៃជំងឺ និងដើម្បីបញ្ចប់ការរាតត្បាតជាសកល។ ទូទាំងពិភពលោក រដ្ឋាភិបាលនិងអ្នកដែលពាក់ព័ន្ធបានចូលរួមក្នុងការសម្របសម្រួលការអភិវឌ្ឍថ្នាំបង្ការ។ មជ្ឈមណ្ឌលកូវ៉ាក់គឺជាលទ្ធផលនៃភាពជាដៃគូដ៏វិសេស ដែលត្រូវបានបង្កើតឡើងដើម្បីធានា ដល់ការបែងចែកនិងការទទួលបានប្រកបដោយសមធម៌ម នៃថ្នាំបង្ការជំងឺកូវីដ-១៩ ក្នុងខណៈដែលថ្នាំបង្ការត្រូវបានអភិវឌ្ឍ និងមានសម្រាប់ប្រើប្រាស់។

ព្រះរាជាណាចក្រកម្ពុជាកំពុងត្រៀមរៀបចំ សម្រាប់ការផ្តល់ថ្នាំបង្ការជូនប្រជាពលរដ្ឋក្នុងប្រទេស ដោយការអភិវឌ្ឍផែនការជាតិស្តីពីយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ និងគោលការណ៍ណែនាំប្រតិបត្តិសម្រាប់ការផ្តល់ថ្នាំបង្ការជំងឺកូវីដ-១៩។ ការផ្តល់ថ្នាំបង្ការជំងឺកូវីដ-១៩ នឹង អាចជាបន្ទុកបន្ថែមសម្រាប់កម្មវិធីជាតិផ្តល់ថ្នាំបង្ការ និងប្រព័ន្ធសុខាភិបាល។

គោលការណ៍ណែនាំត្រូវបានអភិវឌ្ឍឡើងដោយផ្អែកលើផែនការជាតិផ្តល់ថ្នាំបង្ការ ដើម្បីជាការបំពេញបន្ថែមទៅផែនការជាតិ។ គោលការណ៍ណែនាំនឹងជួយដល់ថ្នាក់ដឹកនាំ អ្នកគ្រប់គ្រងកម្មវិធីជាតិផ្តល់ថ្នាំបង្ការ អ្នកផ្តល់សេវាថែទាំសុខភាព ក្នុងការធ្វើផែនការ អនុវត្ត និងតាមដានការផ្តល់ថ្នាំបង្ការជំងឺកូវីដ-១៩ នៅក្នុងប្រទេស។ យើងសង្ឃឹមថា គោលការណ៍ណែនាំនឹងជួយធ្វើឱ្យប្រសើរឡើងការធ្វើផែនការលម្អិត ការផ្គត់ផ្គង់ ប្រព័ន្ធចែកចាយថ្នាំបង្ការ ការតាមដានហេតុការណ៍កើតមានក្រោយការផ្តល់ថ្នាំបង្ការ និងការប្រាស្រ័យទាក់ទង។

ក្រសួងសុខាភិបាលជឿជាក់ថា គោលការណ៍ណែនាំនេះនឹងផ្តល់នូវឧបករណ៍ដ៏មានតម្លៃសម្រាប់អ្នកអនុវត្តគ្រប់លំដាប់ថ្នាក់ ចាប់តាំងពីថ្នាក់ជាតិរហូតដល់ថ្នាក់ក្រោមជាតិ។

ថ្ងៃ ចន្ទ ៥ កើត ខែ មាឃ ឆ្នាំជូតទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០២១

រដ្ឋមន្ត្រី

ម៉ម ប៊ុនហេង

# អក្សរកាត់

| | |
|---|---|
| AD syringe | ស៊ីរ៉ាំងអេឌី |
| AEFI | ហេតុការណ៍កើតមានក្រោយការផ្តល់ថ្នាំបង្ការ |
| CDC | មជ្ឈមណ្ឌលប្រយុទ្ធនឹងជំងឺឆ្លង |
| CMS | ឃ្លាំងឱសថកណ្តាល |
| DDF | នាយកដ្ឋានឱសថ ចំណីអាហារ សម្ភារៈបរិក្ខាពេទ្យ និងគ្រឿងសំអាង |
| GoC | រដ្ឋាភិបាលនៃប្រទេសកម្ពុជា |
| HC | មណ្ឌលសុខភាព |
| HCW | បុគ្គលិកថែទាំសុខភាព |
| IC | មេបញ្ជាការឧប្បត្តិហេតុ |
| ICC | គណៈកម្មការសម្របសម្រួលអន្តរទីភ្នាក់ងារ |
| IEC | ព័ត៌មាន ការអប់រំ និងការប្រាស្រ័យទាក់ទង |
| LA | អាជ្ញាធរមូលដ្ឋាន |
| MoH | ក្រសួងសុខាភិបាល |
| NCDM | គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ |
| NDVP | ផែនការជាតិស្តីពីការផ្តល់ថ្នាំបង្ការជំងឺកូវីដ-១៩ |
| NIP | កម្មវិធីជាតិផ្តល់ថ្នាំបង្ការ |
| NITAG | ក្រុមប្រឹក្សាបច្ចេកទេសជាតិផ្តល់ថ្នាំបង្ការ |
| OD | ស្រុកប្រតិបត្តិ |
| PHD | មន្ទីរសុខាភិបាលខេត្ត |
| SAGE | ក្រុមប្រឹក្សាអ្នកឯកទេសយុទ្ធសាស្ត្រផ្តល់ថ្នាំបង្ការនិងវ៉ាក់សាំង |
| ToT | ការបណ្តុះបណ្តាលគ្រូបង្គោល |
| TWGH | ក្រុមការងារបច្ចេកទេសសុខាភិបាល |
| VHSG | ក្រុមទ្រទ្រង់សុខភាពភូមិ |
| UNICEF | មូលនិធិអង្គការសហប្រជាជាតិដើម្បីកុមារ (អង្គការយូនីសេហ្វ) |
| WHO | អង្គការសុខភាពពិភពលោក |
| WICR | បន្ទប់ត្រជាក់ |
| WPRO | ការិយាល័យអង្គការសុខភាពពិភពលោកប្រចាំតំបន់ប៉ាស៊ីហ្វិកខាងលិច |

# មាតិកា


អារម្ភកថា 3
អក្សរកាត់ 5
ជំពូកទី ១ - សេចក្តីផ្តើម 9
ជំពូកទី ២ - វីរុសកូរ៉ូណា និង ជំងឺកូវីដ-១៩ 12
ជំពូកទី ៣ - ថ្នាំបង្ការជំងឺកូវីដ-១៩ 13
ជំពូកទី ៤ - ការគ្រប់គ្រង សម្របសម្រួល និង រាយការណ៍អំពីការផ្តល់ថ្នាំបង្ការជំងឺកូវីដ-១៩ 15
ជំពូកទី ៥ - ក្រុមចំណុចអាទិភាព 18
ជំពូកទី ៦ - ការធ្វើផែនការ និងការបណ្តុះបណ្តាល 23
ជំពូកទី ៧ - យុទ្ធសាស្រ្ត និងការអនុវត្តផ្តល់ថ្នាំបង្ការ 29
ជំពូកទី ៨- ការគ្រប់គ្រងសំភារៈ-បរិក្ខានៃកម្មវិធីជាតិផ្តល់ថ្នាំបង្ការ 35
ជំពូកទី ៩ - ការផ្តល់ថ្នាំបង្ការប្រកបដោយសុវត្ថិភាព 41
ជំពូកទី ១០ - ការកត់ត្រា និងការធ្វើរបាយការណ៍ 45
ជំពូកទី ១១- ការតស៊ូមតិ ការប្រាស្រ័យទាក់ទង និងការកៀរគរសង្គម 48
ជំពូកទី ១២- ការតាមដាន និងវាយតម្លៃយុទ្ធនាការផ្តល់ថ្នាំបង្ការ ជំងឺកូវីដ-១៩ 51
ជំពូកទី ១៣- ហេតុការណ៍កើតក្រោយការផ្តល់ថ្នាំបង្ការ 55
ជំពូកទី ១៤ - ការបញ្ចប់យុទ្ធនាការផ្តល់ថ្នាំបង្ការជំងឺកូវីដ-១៩ 60
ឧបសម្ព័ន្ធ 61

# ជំពូកទី ១ - សេចក្តីផ្តើម

ប្រទេសកម្ពុជាមានព្រំប្រទល់ខាងលិចជាប់ប្រទេសថៃ ខាងជើងជាប់ប្រទេសឡាវនិងថៃ ទិសអាគ្នេយ៍ ជាប់ឈូងសមុទ្រថៃ ទិសខាងកើតនិងខាងត្បូងជាប់ប្រទេសវៀតណាម។ ប្រទេសកម្ពុជាមានក្រឡាផ្ទៃដីសរុប ១៨១,០៣៥ គីឡូម៉ែត្រក្រឡា និងមានប្រជាជនសរុបចំនួន ១៦,៨៧៣,៧៩៤ នៅឆ្នាំ ២០២១ (វិទ្យាស្ថានជាតិស្ថិតិឆ្នាំ ២០១៧ ក្រសួងផែនការ) ក្នុងនោះ ប្រជាជនអាយុក្រោម ៤០ឆ្នាំ មាន ៧៦% និងចាប់ពី ៦៥ឆ្នាំ ឡើងទៅមាន ៤,៥%។

ប្រទេសកម្ពុជាចែកចេញជាខេត្តចំនួន ២៤ និងរាជធានីមួយ ស្រុកចំនួន១៦៣ ក្រុងចំនួន ២៦ ខណ្ឌចំនួន១៤ សង្កាត់-ឃុំចំនួន ១,៦៤៦ និងភូមិចំនួន ១៤,៤៧៦។ រចនាសម្ព័ន្ធប្រព័ន្ធសុខាភិបាលមិនដូចគ្នានឹងរចនាសម្ព័ន្ធរដ្ឋបាលទេ ដោយប្រព័ន្ធសុខាភិបាលបែងចែកជាមន្ទីរសុខាភិបាលរាជធានី-ខេត្តចំនួន ២៥ ស្រុកប្រតិបត្តិចំនួន ១០៣ និងមណ្ឌលសុខភាពចំនួន ១,២២៩។

រូបភាពទី១៖ ផែនទីរដ្ឋបាលនៃប្រទេសកម្ពុជា




| រចនាសម្ព័ន្ធប្រព័ន្ធសុខាភិបាល | |
|---|---|
| ចំនួនមន្ទីរសុខាភិបាលរាជធានី-ខេត្ត | ២៥ |
| ចំនួនស្រុកប្រតិបត្តិសុខាភិបាល | ១០៣ |
| ចំនួនមន្ទីរពេទ្យជាតិ | ៩ |
| ចំនួនមន្ទីរពេទ្យខេត្ត | ២៤ |
| ចំនួនមន្ទីរពេទ្យបង្អែកស្រុកប្រតិបត្តិ | ៩២ |
| ចំនួនមណ្ឌលសុខភាព | ១,២២៩ |

កូវីដ-១៩ ជាជំងឺឆ្លងដែលបង្កដោយមេរោគក្សួណាថ្មីអំបូរសាកូវី-២ (SARS-CoV-2)។ ជំងឺកូវីដ-១៩ពុំធ្លាប់ប្រទះឃើញនៅលើមនុស្សពីមុនមកទេ។ ករណីដំបូងនៃជំងឺនេះនៅលើមនុស្សត្រូវបានរកឃើញនៅទីក្រុង វូហាន ខេត្តហើប៉ី នៃប្រទេសចិន។ នៅថ្ងៃទី ៣០ ខែមករា ឆ្នាំ ២០២០ ប្រធានអង្គការសុខភាពពិភពលោកបានប្រកាសថាជំងឺកូវីដ-១៩ ជាគ្រោះបន្ទាន់ផ្នែកសុខភាពសាធារណៈដែលបង្កជាកង្វល់អន្តរជាតិ (PHEIC)។ នៅថ្ងៃទី ១១ ខែមិនា ឆ្នាំ ២០២០ អង្គការសុខភាពពិភពលោកបានប្រកាសថា ជំងឺកូវីដ-១៩ ជាជំងឺរាតត្បាតសកល។

នៅប្រទេសកម្ពុជា ករណីជំងឺកូវីដ-១៩ ត្រូវបានរកឃើញដំបូងក្នុងខេត្តព្រះសីហនុ នៅថ្ងៃទី ២៧ ខែមករាឆ្នាំ ២០២០។ អ្នកជំងឺជាជនជាតិបរទេសដែលមានប្រវត្តិធ្វើដំណើរមកពីប្រទេសក្រៅ។ អ្នកជំងឺត្រូវបានដាក់ឲ្យនៅដាច់ដោយឡែកភ្លាមៗ ដោយទទួលបានការព្យាបាលរហូតជាសះស្បើយ។ ត្រឹមថ្ងៃទី ៤ ខែមករា ឆ្នាំ ២០២១ មានករណីជំងឺកូវីដ-១៩ ចំនួន ៣៨២ នាក់ ត្រូវបានរាយការណ៍នៅក្នុងប្រទេសកម្ពុជា ក្នុងនោះមានអ្នកជាសះស្បើយចំនួន ៣៦២នាក់។ ក្នុងចំណោមនោះ អ្នកជំងឺចំនួន ២៩៩ នាក់ជាករណីដែលបានឆ្លងនៅក្រៅប្រទេស។ អ្នកជំងឺកូវីដ-១៩ ចំនួន ២៥៨ នាក់ ជាប្រជាពលរដ្ឋកម្ពុជា រីឯ ១២៤ ករណីកើតមានលើជនបរទេសមកពី ១៧ ប្រទេសផ្សេងទៀត។

រូបភាពទី២៖ តារាងប្រៀបធៀបករណីជំងឺកូវីដ-១៩តាមក្រុមអាយុ និងជាតិសាសន៍ គិតត្រឹមថ្ងៃ៤ ខែមករាឆ្នាំ២០២១ (សរុប ៣៨២នាក់)




ការផ្តល់ថ្នាំបង្ការជាវិធីដ៏សំខាន់ក្នុងការប្រយុទ្ធនឹងការរាតត្បាតជាសកល ដោយអាចកាត់បន្ថយផលប៉ះពាល់ដែលបង្កដោយជំងឺ និងអាចបញ្ឈប់ការរាលដាលនៃជំងឺនៅក្នុងសកលលោក។ តម្រូវការថ្នាំបង្ការដែល មានប្រសិទ្ធភាពជាកត្តាចាំបាច់បន្ទាន់ ដើម្បីការពារប្រជាជនដែលងាយរងគ្រោះ។

ដោយមានកិច្ចសហប្រតិបត្តិការគ្រប់លំដាប់ថ្នាក់រវាងដៃគូអន្តរជាតិ រដ្ឋាភិបាល និងអ្នកដែលពាក់ព័ន្ធជាច្រើន យន្តការសម្របសម្រួលដើម្បីពន្លឿនការអភិវឌ្ឍ ផលិតកម្ម និងការទទួលបានការធ្វើរោគវិនិច្ឆ័យ ថ្នាំបង្ការ និង ការព្យាបាលជំងឺកូវីដ-១៩ប្រកបដោយសមភាពមួយ (Access COVID-19 Tool accelerator) ត្រូវបានបង្កើតឡើងនៅខែមេសាឆ្នាំ ២០២០។ ថ្នាំបង្ការគឺជាសសរស្តម្ភមួយក្នុងចំណោមសសរស្តម្ភទាំង៤នៃយន្តការនេះ។ ដៃគូសកលសម្របសម្រួលនិងជំរុញការផ្គត់ផ្គង់-ចែកចាយប្រកបដោយសមធ៌មថ្នាំបង្ការជំងឺកូវីដ-១៩ (COVAX Facility) ត្រូវបានបង្កើតឡើង និងសហការដឹកនាំដោយសម្ព័ន្ធភាពវ៉ាក់សាំងនិងថ្នាំបង្ការ (Gavi) សម្ព័ន្ធភាពផ្តួចផ្តើមនិងត្រៀមរៀបចំដើម្បីប្រយុទ្ធទល់នឹងជំងឺរាតត្បាត (CEPI) និងអង្គការសុខភាពពិភពលោក ក្នុងបំណងបង្កើនល្បឿននៃការអភិវឌ្ឍនិងផលិតវ៉ាក់សាំងកូវីដ-១៩ ព្រមទាំងធានាឲ្យបាននូវការទទួលបានវ៉ាក់សាំងប្រកបដោយសមភាពសម្រាប់គ្រប់ប្រទេសលើសកលលោក។

គណៈកម្មការពន្លឿនទីផ្សារ នៃដៃគូសកលសម្របសម្រួលនិងជំរុញការផ្គត់ផ្គង់-ចែកចាយប្រកបដោយសមធ៌មថ្នាំបង្ការជំងឺកូវីដ-១៩ (COVAX AMC) នឹងឧបត្ថម្ភថ្នាំបង្ការជំងឺកូវីដ-១៩ ដល់កម្ពុជាក្នុងចំនួនស្មើនឹង ២០% នៃប្រជាជនសរុបត្រូវនឹង ៣,៣៧៤,៧៥៩នាក់ សម្រាប់ផ្តល់ជូនប្រជាពលរដ្ឋចំណុចអាទិភាព។ រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបានត្រៀមទិញវ៉ាក់សាំងបន្ថែមចំនួន ១ លានដូសទៀតដើម្បីផ្តល់ជូនដល់ប្រជាជនផ្សេងទៀត។

កម្មវិធីជាតិផ្តល់ថ្នាំបង្ការនៃក្រសួងសុខាភិបាលទទួលភារៈក្នុងការបែងចែក និងផ្តល់ថ្នាំបង្ការកូវីដ-១៩ នៅកម្ពុជាហើយសេចក្តីណែនាំស្តីពីផែនគ្រប់គ្រងនិងអនុវត្តស្តីពីការផ្តល់ថ្នាំបង្ការជំងឺកូវីដ-១៩ ត្រូវបានព្រាងរួចជាស្រេច។

គោលបំណងចម្បងនៃការផ្តល់ថ្នាំបង្ការជំងឺកូវីដ-១៩ គឺជួយសង្គ្រោះជីវិត និងការពារប្រជាពលរដ្ឋ ដែលងាយរងគ្រោះពីការឆ្លងជំងឺធ្ងន់ធ្ងរនេះ។ កម្មវិធីជាតិផ្តល់ថ្នាំបង្ការនឹងអនុវត្តការងារជាច្រើនទៀត ដើម្បីទទួលបានជោគជ័យក្នុងយុទ្ធនាការនិងសេវាផ្តល់ថ្នាំបង្ការជំងឺកូវីដ-១៩។ ការផ្តល់ជូនថ្នាំបង្ការជំងឺកូវីដ-១៩ បន្ទាន់ គឺជា ភាពចាំបាច់បំផុតនៅពេលដែលថ្នាំបង្ការទាំងនោះបានមកដល់ប្រទេសកម្ពុជាភ្លាម ដោយមានការរំពឹងថា អត្រា គ្រប់ដណ្តប់របស់ថ្នាំបង្ការនេះលើប្រជាជនងាយរងគ្រោះបានខ្ពស់ជាង ៩៥%។

កម្ពុជាមានបទពិសោធន៍ជាច្រើន ក្នុងការធ្វើយុទ្ធនាការផ្តល់ថ្នាំបង្ការជំងឺគ្រុនស្វិតដៃជើង ជំងឺតេតាណុស ជំងឺកញ្ជ្រឹល ជំងឺកញ្ជ្រឹល-ស្អូច ជំងឺរលាកខួរក្បាលជេអ៊ី (JE) និងជំងឺផ្តាសាយសកល (H1N1) នៅឆ្នាំ ២០១០ ផងដែរ។ កម្មវិធីជាតិផ្តល់ថ្នាំបង្ការនៃក្រសួងសុខាភិបាលមានធនធានគ្រប់គ្រាន់ចាប់ពីថ្នាក់ជាតិរហូតដល់មណ្ឌលសុខភាព ព្រមទាំងប្រព័ន្ធផ្គត់ផ្គង់ដែលមានសមត្ថភាពគ្រប់គ្រាន់ ដើម្បីរក្សាទុក បែងចែកនិងគ្រប់គ្រងគ្រប់ជាន់ថ្នាក់។

សេចក្តីណែនាំនេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងផ្តល់ជាមគ្គុទេសអនុវត្តដល់មន្ត្រីសុខាភិបាលទាំងអស់សម្រាប់ធ្វើផែនការ ត្រៀមរៀបចំ អនុវត្ត តាមដាននិងវាយតំលៃកម្មវិធីជាតិផ្តល់ថ្នាំបង្ការជំងឺកូវីដ-១៩ ក្នុងប្រទេសកម្ពុជា។

# ជំពូកទី ២ - វីរុសកូរ៉ូណា និង ជំងឺកូវីដ-១៩

វីរុសកូរ៉ូណាស្ថិតក្នុងគ្រួសារនៃវីរុសដ៏ធំដែលអាចបង្កជាជំងឺលើសត្វនិងមនុស្ស។ គេបានស្គាល់ខ្លះៗថា វីរុសកូរ៉ូណាអាចបង្កជំងឺផ្លូវដង្ហើមលើមនុស្ស រួមមានជំងឺផ្តាសាយ ជំងឺផ្លូវដង្ហើមមជ្ឈឹមបូព៌ា (MERS) និង ចង្កោមរោគសញ្ញាផ្លូវដង្ហើមស្រួច (SARS)។

ជំងឺកូវីដ-១៩ ជាជំងឺឆ្លងមួយប្រភេទដែលបង្កដោយវីរុសកូរ៉ូណា សាកូវី ២ (SARS-CoV-2)។ វីរុសនិងជំងឺថ្មីនេះពុំធ្លាប់ត្រូវបានស្គាល់ទេ មុនការរាតត្បាតនៅទីក្រុងវ៉ូហាននៃប្រទេសចិននៅខែធ្នូ ឆ្នាំ ២០១៩ ហើយបច្ចុប្បន្ននេះជំងឺកូវីដ-១៩ បានរីករាលដាលក្នុងប្រទេសជាច្រើនលើពិភពលោក។

## ២.១. របៀបឆ្លង

វីរុសកូរ៉ូណា សារស៍-កូវី២ (SARS-CoV-2) អាចឆ្លងបានតាមរយៈការប៉ះពាល់ដំណក់ទឹកមាត់តូចៗ ខ្យល់ វត្ថុ លាមក ប៉ះនឹងមាត់ ឈាម ម្តាយទៅទារក និងពីសត្វមកមនុស្ស។ បន្ទាប់ពីចំលងចូលទៅក្នុងខ្លួនមនុស្សហើយវីរុសកូរ៉ូណា សារស៍-កូវី២ (SARS-CoV-2) បង្ករោគមុនគេនៅផ្លូវដង្ហើម ដែលមានកម្រិតពីមធ្យមទៅធ្ងន់ធ្ងរ និងស្លាប់ ហើយមានអ្នកឆ្លងមួយចំនួនមិនមានបង្ហាញរោគសញ្ញាអ្វីទាំងអស់។

## ២.២. សញ្ញាគ្លីនិក

រោគសញ្ញាដែលជួបញឹកញាប់មានដូចជា ក្តៅខ្លួន ក្អកស្ងួត និងអស់កំលាំង។ មានរោគសញ្ញាមួយចំនួនទៀតដែលពុំសូវជួបញឹកញាប់រួមមាន ការឈឺចាប់ តឹងច្រមុះ ឈឺក្បាល ត្របកភ្នែកក្រហម ឈឺបំពង់ក រាគ មិនឃ្លាន អាហារ រមាស់លើស្បែក ស្លេកស្លាំងចុងម្រាមដៃ ជើង។ រោគសញ្ញាទាំងនេះភាគច្រើនមានកម្រិតស្រាល ហើយវិវត្ត បន្តិចម្តងៗទៅរកភាពធ្ងន់ធ្ងរ។ អ្នកឆ្លងមេរោគនេះមួយចំនួនមានអាការៈកម្រិតស្រាល។

## ២.៣. ការបង្ការ

វិធានការការពារប្រឆាំងការឆ្លងជំងឺកូវីដ-១៩ ដែលមានប្រសិទ្ធភាពគឺ ការលាងសំអាតដៃឱ្យបានញឹកញាប់ រក្សា គំលាតពីអ្នកដទៃ អនុវត្តវិធានការពារផ្លូវដង្ហើម ជៀសវាងកន្លែងមានមនុស្សកុះករ កន្លែងមានមនុស្សប្រជ្រៀតគ្នាចង្អៀត បិទជិតពុំមានខ្យល់ចេញចូលគ្រប់គ្រាន់។ ត្រូវពាក់ម៉ាស់ពេលស្ថិតនៅកន្លែងមានមនុស្សកុះករ ចង្អៀត ដើម្បីការពារអ្នកដទៃ។ ត្រូវរៀបចំកន្លែងឱ្យមានខ្យល់ចេញចូលគ្រប់គ្រាន់និងសម្លាប់មេរោគឱ្យបានត្រឹមត្រូវ។

ថ្នាំបង្ការជំងឺកូវីដ-១៩ គឺជាវិធានការណ៍ដែលមានប្រសិទ្ធភាពខ្ពស់ក្នុងការការពារការចំលងជំងឺកូវីដ-១៩។ អង្គការសុខភាពពិភពលោកបានជូនសេចក្តីណែនាំ ស្តីពីវិធានការណ៍ការពារពេញលេញជាច្រើនដែលលោកអ្នក អាចបើកមើលបានតាមរយៈតំណរភ្ជាប់ខាងក្រោម៖
https://www.who.int/emergencies/diseases/novel-coronavirus-2019/advice-for-public.

# ជំពូកទី ៣ - ថ្នាំបង្ការជំងឺកូវីដ-១៩

ថ្នាំបង្ការជំងឺកូវីដ-១៩គឺជាថ្នាំបង្ការដែលទើបតែរកឃើញនិងផលិតថ្មីៗ សម្រាប់ការពារប្រឆាំងវីរុសកូរ៉ូណា២ (SARS-CoV-2) ដែលបង្កឱ្យមានជំងឺផ្លូវដង្ហើមធ្ងន់ធ្ងរ។ អ្នកផលិតបានប្រើប្រាស់បច្ចេកវិទ្យាជាច្រើនដើម្បី បង្កើតថ្នាំបង្ការជំងឺកូវីដ-១៩ នេះឡើងរួមមានប្រូតេអ៊ីន (protein) អាស៊ីតនុយក្លេអ៊ីក (nucleic acid) (viral vector, inactivated)។ យោងតាមឯកសារផ្សព្វផ្សាយពីលទ្ធផលសិក្សាស្រាវជ្រាវបង្ហាញថាថ្នាំបង្ការជំងឺកូវីដ-១៩ មានសុវត្ថិភាពនិងមានប្រសិទ្ធភាព។

រូបភាពទី៣៖ ដបថ្នាំបង្ការជំងឺកូវីដ-១៩

(ព័ត៌មាននិងរូបភាពជាក់ស្តែងនៃដបថ្នាំបង្ការជំងឺកូវីដ-១៩ នឹងត្រូវបានបង្ហាញ នៅពេលដែលព័ត៌មានជាក់លាក់អំពីថ្នាំបង្ការត្រូវបានបញ្ជាក់)




## ៣.១. សុវត្ថិភាពថ្នាំបង្ការ

(បច្ចុប្បន្នភាពអំពីសុវត្ថិភាពថ្នាំបង្ការជំងឺកូវីដ-១៩ នឹងត្រូវបានដាក់បញ្ចូល នៅពេលដែលព័ត៌មានជាក់លាក់អំពីថ្នាំបង្ការត្រូវបានបញ្ជាក់)

## ៣.២. ចំរាមនៃការផ្តល់ថ្នាំបង្ការ

(បច្ចុប្បន្នភាពអំពីសុវត្ថិភាពថ្នាំបង្ការជំងឺកូវីដ-១៩ នឹងត្រូវបានដាក់បញ្ចូល នៅពេលដែលព័ត៌មានជាក់លាក់អំពីថ្នាំបង្ការត្រូវបានបញ្ជាក់)

## ៣.៣. កម្រិតប្រើ របៀបចាក់និងកន្លែងចាក់ថ្នាំបង្ការជំងឺកូវីដ-១៩

ការចាក់ថ្នាំបង្ការដោយអនុវត្តតាមសេចក្តីណែនាំស្តីពីរបៀបចាក់និងកន្លែងចាក់មានសារៈសំខាន់បំផុត។

រូបភាពទី៤៖ ការចាក់សាច់ដុំថ្នាំបង្ការជំងឺកូវីដ-១៩




តារាងទី១៖ សង្ខេបលក្ខណៈសំគាល់ថ្នាំបង្ការជំងឺកូវីដ-១៩ និងបច្ចេកទេស នៃការផ្តល់

| **លក្ខណៈសំគាល់** | **បរិយាយ** |
|---|---|
| ប្រភេទថ្នាំបង្ការ | |
| ទម្រង់ (Presentation and | |
| ចំណុះក្នុង ១ ដូស | |
| ចំនួនដូសដែលត្រូវផ្តល់ | ២ ដង |
| គំលាតទៅការផ្តល់លើក | |
| របៀបផ្តល់ | ចាក់សាច់ដុំ |
| កន្លែងផ្តល់ | នៅស្មាស្តាំ |
| លក្ខខ័ណ្ឌក្នុងការរក្សាថ្នាំបង្ការ | |
| ការតាមដានវ៉ាក់សាំងខូច | |
| រយៈពេលរក្សាថ្នាំបង្ការទុក | |
| អត្រាខាតបង់ | ១៥% |
| លក្ខខណ្ឌប្រើជាមួយថ្នាំបង្ការ | |
| បំរាមក្នុងការផ្តល់ថ្នាំបង្ការ | |
| ផលរំខាន | |

ព័ត៌មានស្តីអំពីលក្ខណៈសំគាល់ថ្នាំបង្ការជំងឺកូវីដ-១៩ និងបច្ចេកទេសនៃការផ្តល់ នឹងត្រូវបានបំពេញនៅពេលដែលប្រភេទជាក់លាក់នៃថ្នាំបង្ការជំងឺកូវីដ-១៩ ត្រូវបានបញ្ជាក់។

# ជំពូកទី ៤ -  ការគ្រប់គ្រង សម្របសម្រួល និងរាយការណ៍ អំពីការផ្តល់ថ្នាំបង្ការជំងឺកូវីដ-១៩

ជោគជ័យនៃយុទ្ធនាការជាតិផ្តល់ថ្នាំបង្ការជំងឺកូវីដ-១៩ នឹងអាស្រ័យលើគុណភាពនៃការគ្រប់គ្រងសកម្មភាព និងនិតិវិធីដែលបានគ្រោង ក៏ដូចជាការរៀបចំដើម្បីគាំទ្រសកម្មភាព ចាប់តាំងពីការសម្រេចចិត្តរហូតដល់ការអនុវត្តនិងការវាយតម្លៃ។ ហេតុនេះ ការបង្កើតរចនាសម្ព័ន្ធ-យន្តការគ្រប់គ្រង និងការសម្របសម្រួលគ្រប់គ្រាន់គឺជាជំហានគន្លឹះនៃសមាសភាគនេះ។ គណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩ ដែលដឹកនាំដោយឯកឧត្តមរដ្ឋមន្ត្រីក្រសួងសុខាភិបាល ទទួលខុសត្រូវរួមក្នុងការផ្តល់ការណែនាំ និងការគ្រប់គ្រងការផ្តល់ថ្នាំបង្ការជំងឺកូវីដ-១៩។

ក្នុងទស្សនៈវិស័យនៃការអនុវត្តយុទ្ធនាការជាតិផ្តល់ថ្នាំបង្ការជំងឺកូវីដ-១៩ និងយោងតាមការណែនាំដ៏ ខ្ពង់ខ្ពស់របស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** នៃព្រះរាជាណាចក្រកម្ពុជា ក្រសួងសុខាភិបាលបានបង្កើត "ក្រុមការងារពិសេសសម្រាប់ការត្រៀមរៀបចំនិងអនុវត្តការផ្តល់ថ្នាំបង្ការជំងឺកូវីដ-១៩"។ ក្រុមការងារមានសមាជិក១៥ រូបនេះ ត្រូវបានដឹកនាំដោយឯកឧត្តមរដ្ឋមន្ត្រីក្រសួងសុខាភិបាល និងដោយមានការចូលរួមរបស់ថ្នាក់ដឹកនាំនៃក្រសួងសុខាភិបាល និងក្រសួងសេដ្ឋកិច្ច-ហិរញ្ញវត្ថុ ដើម្បីអភិបាលការអនុវត្តការផ្តល់ថ្នាំបង្ការជំងឺកូវីដ-១៩ ដោយមានភារៈកិច្ចដូចខាងក្រោម៖

- ពិនិត្យលក្ខណៈបច្ចេកទេសលើថ្នាំបង្ការជំងឺកូវីដ-១៩។
- រៀបចំផែនការ គោលនយោបាយ គោលការណ៍ប្រតិបត្តិស្តង់ដា ពិធីសារសម្រាប់ការគ្រប់គ្រង និងប្រើប្រាស់ថ្នាំបង្ការជំងឺកូវីដ-១៩។
- គ្រប់គ្រងស្ថិតិការផ្តល់ថ្នាំបង្ការជំងឺកូវីដ-១៩ នៅកម្ពុជា។
- កំណត់ក្រុមចំណុចត្រូវទទួលការផ្តល់ថ្នាំបង្ការជំងឺកូវីដ-១៩។
- ពិនិត្យ និងវាយតម្លៃការអនុវត្តគម្រោង និងប្រសិទ្ធិភាពនៃថ្នាំបង្ការជំងឺកូវីដ-១៩។
- ធ្វើរបាយការណ៍ជូនឯកឧត្តមប្រធានអំពីវឌ្ឍនភាពនៃការអនុវត្តគម្រោង។
- ចូលរួមប្រជុំ និងបំពេញការងារផ្សេងៗទៀតតាមការណែនាំរបស់ឯកឧត្តមប្រធាន។

រូបភាពទី ៥៖ យន្តការគ្រប់គ្រង សម្របសម្រួល និងរាយការពីការផ្តល់ថ្នាំបង្ការជំងឺកូវីដ-១៩




ក្រុមការងារបច្ចេកទេសសុខាភិបាល (TWGH) គឺជាវេទិកាពហុភាគីពាក់ព័ន្ធ និងបានដើរតួនាទីជាក្រុមប្រឹក្សាបច្ចេកទេសជាតិផ្តល់ថ្នាំបង្ការ (NITAG) និងជាគណៈកម្មការសម្របសម្រួលអន្តរទីភ្នាក់ងារ (ICC) សម្រាប់កម្មវិធីជាតិផ្តល់ថ្នាំបង្ការនៅកម្ពុជា។ ក្រុមអ្នកឯកទេសនេះបានពិនិត្យនិងពិភាក្សាលើផែនការជាតិស្តីអំពីការផ្តល់ថ្នាំបង្ការជំងឺកូវីដ-១៩ រួមទាំងការបញ្ចប់ការកំណត់ក្រុមចំណុចអាទិភាពនិងការរៀបតាមលំដាប់ការប្រមាណថវិកាសម្រាប់យុទ្ធនាការព្រមទាំងផ្តល់មតិយោបល់និងអនុសាសន៍។ក្រុមការងារពិសេសសម្រាប់ការត្រៀមបម្រុងនិងអនុវត្តយុទ្ធនាការផ្តល់ថ្នាំបង្ការជំងឺកូវីដ-១៩និងសម្របសម្រួលជាមួយក្រុមការងារបច្ចេកទេស សុខាភិបាល ក្នុងការអនុវត្តយុទ្ធនាការផ្តល់ថ្នាំបង្ការជំងឺកូវីដ-១៩ ចាប់ពីការធ្វើផែនការការត្រៀមជាស្រេច រហូតដល់ការវាយតម្លៃ និងស្នើសុំការគាំទ្រពីដៃគូ។

ដោយពិចារណាដល់ការអនុវត្តយុទ្ធនាការជាតិផ្តល់ថ្នាំបង្ការជំងឺកូវីដ-១៩ រចនាសម្ព័ន្ធមួយត្រូវបានបង្កើតឡើងដោយកម្មវិធីជាតិផ្តល់ថ្នាំបង្ការ ដោយមានការគាំទ្ររបស់អង្គការសុខភាពពិភពលោក និងអង្គការយូនីសេហ្វដើម្បីពង្រឹង "ក្រុមបច្ចេកទេសកម្មវិធីជាតិផ្តល់ថ្នាំបង្ការ" ដោយបញ្ចូលអនុក្រុមចំនួន ៥ ដើម្បីគាំទ្រដល់ការអនុវត្តការផ្តល់ថ្នាំបង្ការជំងឺកូវីដ-១៩។ អនុក្រុមទាំង ៥ គឺ៖១) អនុក្រុមគ្រប់គ្រងទិន្នន័យ តាមដាន និងវាយតម្លៃ២)អនុក្រុមប្រព័ន្ធផ្គត់ផ្គង់និងភស្តុភារ ៣) អនុក្រុមត្រៀមរៀបចំការផ្តល់ថ្នាំបង្ការ រួមបញ្ចូលទាំងរៀបចំគោលការណ៍ណែនាំអនុវត្ត និងការកំណត់អាទិភាព ៤) អនុក្រុមប្រាស្រ័យទាក់ទង កៀរគរការគាំទ្រ និងបង្កើតតម្រូវការ និង ៥) អនុក្រុមអង្កេតស្រាវជ្រាវនិងគ្រប់គ្រងហេតុការណ៍កើតក្រោយការផ្តល់ថ្នាំបង្ការ។ តារាងតួនាទីនិងភារៈកិច្ច (ToRs) ត្រូវបានរៀបចំរួចហើយ ដោយមានរាយសមាជិកភាពសម្រាប់អនុក្រុមទាំង ៥។ អនុក្រុមទាំង ៥ នឹងនៅបន្តការងារផ្តល់ថ្នាំបង្ការជាប្រចាំរបស់កម្មវិធីជាតិផ្តល់ថ្នាំបង្ការ និងការតាមដានស្រាវជ្រាវជំងឺដែលអាចបង្ការបានដោយវ៉ាក់សាំង។

នៅខេត្តមួយ "គណៈកម្មការថ្នាក់ខេត្តដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩" នឹងគ្រប់គ្រង ព្រមទាំងផ្តល់ការគាំទ្រដល់យុទ្ធនាការជាតិផ្តល់ថ្នាំបង្ការជំងឺកូវីដ-១៩។

មណ្ឌលសុខភាពនឹងរាយការណ៍ទៅ "គណៈកម្មការថ្នាក់ខេត្តដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩ តាមរយៈប្រធានការិយាល័យស្រុកប្រតិបត្តិ និងប្រធានមន្ទីរសុខាភិបាលខេត្ត។ "គណៈកម្មការថ្នាក់ខេត្តដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩" នឹងរាយការទៅ "គណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩" ។

ជោគជ័យនៃយុទ្ធនាការផ្តល់ថ្នាំបង្ការជំងឺកូវីដ-១៩ នឹងត្រូវការផងដែរនូវតួនាទីនិងការគាំទ្ររបស់ក្រសួង-ស្ថាប័នផ្សេងទៀត រួមបញ្ចូលទាំងក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងការធានាថាមានធនធានគ្រប់គ្រាន់ និងថាសហគមន៍និងក្រុមប្រជាជនចំណុចអាទិភាព និងប្រជាពលរដ្ឋត្រូវបានគៀរគរប្រកបដោយប្រសិទ្ធិភាព។ ក្រសួងសុខាភិបាលនឹងដឹកនាំអន្តរក្រសួងលើសម្របសម្រួលការចែកចាយនិងផ្តល់ថ្នាំបង្ការជំងឺកូវីដ-១៩ តាមរយៈគណៈកម្មការអន្តរក្រសួងប្រយុទ្ធនឹងជំងឺកូវីដ-១៩ ដែលត្រូវបានបង្កើតឡើងនៅថ្ងៃទី ២ ខែមេសា ឆ្នាំ២០២០ និងដោយមានការចូលរួមដោយក្រសួងពាក់ព័ន្ធចំនួន ១៦ ព្រមទាំងអភិបាលរាជធានីខេត្តទាំង ២៥។

# ជំពូកទី ៥ - ក្រុមចំណុចអាទិភាព

ការកំណត់និយមន័យនិងកំណត់ក្របប្រជាជនចំណុចជាអាទិភាព មានសារៈសំខាន់បំផុតសម្រាប់យុទ្ធនាការជាតិផ្តល់ថ្នាំបង្ការជំងឺកូវីដ-១៩។ កម្មវិធីជាតិផ្តល់ថ្នាំបង្ការបានជួបប្រជុំនិងពិនិត្យឡើងវិញការណែនាំរបស់ក្រសួងសុខាភិបាល អនុសាសន៍របស់ក្រុមប្រឹក្សាអ្នកឯកទេសយុទ្ធសាស្ត្រផ្តល់ថ្នាំបង្ការនៃអង្គការសុខភាពពិភពលោក និងពិចារណាលើបរិបទនៃប្រទេសកម្ពុជា និងកំណត់ក្រុមចំណុចអាទិភាពដែលគួរទទួលថ្នាំ បង្ការ។ ក្រុមចំណុចអាទិភាពទាំងនេះត្រូវបានដាក់ជូនក្រុមការងារបច្ចេកទេសសុខាភិបាល ដើម្បីពិនិត្យឡើងវិញនិងផ្តល់អនុសាសន៍។ ដោយតម្រូវការថ្នាំបង្ការមានភាពធំធេងជាសកល ពិភពលោកនឹងគ្មានថ្នាំបង្ការគ្រប់គ្រាន់ទេនៅ ដំណាក់កាលដំបូងនិងក្នុងពេលតែមួយ។ ហេតុនេះ អភិក្រមផ្តល់ថ្នាំបង្ការជាដំណាក់ៗគឺជាការចាំបាច់។

តារាងទី ២៖ ក្រុមអាទិភាព កម្រិតដូសដែលត្រូវការ និងកន្លែងផ្តល់ថ្នាំបង្ការ

| ល.រ | ក្រុមអាទិភាព | ចំនួនប្រជាជនចំណុចសរុប | ដំណាក់កាលផ្តល់ថ្នាំបង្ការ | យុទ្ធសាស្ត្រផ្តល់ថ្នាំបង្ការ |
|---|---|---|---|---|
| ១ | បុគ្គលិកថែទាំសុខភាពរួមទាំងបុគ្គលិកជំនួយ | ៣៦,៨៩៤ | ដំណាក់កាលទី១ | មណ្ឌលសុខភាព ឬមន្ទីរពេទ្យ |
| ២ | មន្ត្រីរដ្ឋាភិបាលសំខាន់ៗ រួមទាំងកងកម្លាំងប្រដាប់អាវុធ | ២៨៩,៧២១ | ដំណាក់កាលទី១ | មណ្ឌលសុខភាព ឬមន្ទីរពេទ្យ និងនៅការិយាល័យកងទ័ពនិងនគរបាល/បន្ទាយ |
| ៣ | វចនាសម្ព័ន្ធសហគមន៍ រួមទាំងអ្នកស្ម័គ្រចិត្ត | ៥០,០៧៤ | ដំណាក់កាលទី១ | មណ្ឌលសុខភាព ឬមន្ទីរពេទ្យ |
| ៤ | ប្រជាជនវ័យចំណាស់អាយុចាប់ពី ៦៥ ឆ្នាំឡើងទៅ | ៩៤៤,៩៣២ | ដំណាក់កាលទី១<br>ដំណាក់កាលទី២ | មណ្ឌលសុខភាព ឬមន្ទីរពេទ្យ និងការចុះផ្តល់សេវាដល់មូលដ្ឋាន (ភូមិ) |
| ៥ | មនុស្សពេញវ័យអាយុ ១៨-៦៤ ឆ្នាំ ដែលមានហានិភ័យខ្ពស់(មានជំងឺទឹកនោមផ្អែម ជំងឺលើសឈាម។ ល។) | ១,៥២១,៤២៦ | ដំណាក់កាលទី២ | មណ្ឌលសុខភាព ឬមន្ទីរពេទ្យ និងការចុះផ្តល់សេវាដល់មូលដ្ឋាន (ភូមិ) |
| ៦ | កម្មករ-ការនីរោងចក្រកាត់ដេរ និងកម្មករ-ការនីផ្សេងទៀត | ៦២១,២៧៥<br>៥០០,០០០* | ដំណាក់កាលទី២ | ប៉ុស្តិ៍ផ្តល់ថ្នាំបង្ការនៅតាមរោងចក្រ និងទីតាំងការដ្ឋាន |
| | **សរុប** | **៣,៩៦៤,៣២២** | | ចំនួនប៉ាន់ប្រមាណសមមូលនឹង ២៣% នៃប្រជាជនសរុប |

*១,០០០,០០០ ដូស (សម្រាប់ប្រជាជន ៥០០,០០០) នឹងត្រូវធ្វើលទ្ធកម្មដោយរាជរដ្ឋាភិបាលកម្ពុជា តាមរយៈ COVAX Facility

## ៥.១. ការពិពណ៌នាអំពីក្រុមចំណុច៖

### ៥.១.១. បុគ្គលិកថែទាំសុខភាពរួមទាំងបុគ្គលិកជំនួយ

- ក្រុមនេះរួមបញ្ចូលវេជ្ជបណ្ឌិត គិលានុបដ្ឋាក-យិកា ឆ្មប និងបុគ្គលិកជំនួយ/បុគ្គលិកគាំទ្រ ដែលកំពុងបម្រើការនៅក្នុងមន្ទីរពេទ្យរដ្ឋ និងមណ្ឌលសុខភាព។ វេជ្ជបណ្ឌិត គិលានុបដ្ឋាក-យិកា ឆ្មបនិងបុគ្គលិកជំនួយ/បុគ្គលិកគាំទ្រ នៅក្នុងមន្ទីរពេទ្យនិងគ្លីនិកមិនមែនរដ្ឋាភិបាល និងគ្លីនិកដែលបានចុះបញ្ជីជាមួយក្រសួងសុខាភិបាល

ព្រមទាំងបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល ដែលចូលរួមក្នុងការផ្តល់សេវាថែទាំសុខភាព ក៏ត្រូវបានរាប់បញ្ចូលផងដែរ។

- ការផ្តល់ថ្នាំបង្ការនឹងត្រូវធ្វើឡើងនៅមន្ទីរពេទ្យនិងមណ្ឌលសុខភាព។
- ការផ្តល់ថ្នាំបង្ការនឹងត្រូវបានធ្វើក្នុងដំណាក់កាលទី ១។

### ៥.១.២. មន្ត្រីរដ្ឋាភិបាលសំខាន់ៗ រួមទាំងកងកម្លាំងប្រដាប់អាវុធ

- ការផ្តល់ការការពារមន្ត្រីទាំងនេះមានសារៈសំខាន់ណាស់ សម្រាប់ការថែរក្សាមុខងាររដ្ឋាភិបាល សន្តិសុខច្បាប់ និងសណ្តាប់ធ្នាប់ក្នុងគ្រាអាសន្ន។
- ក្នុងករណីដែលមានការឆ្លងក្នុងសហគមន៍ទ្រង់ទ្រាយធំ មន្ត្រីរដ្ឋាភិបាលទាំងអស់នឹងត្រូវបានប្រមូល ដើម្បីគាំទ្រសកម្មភាពយុទ្ធនាការជាតិផ្តល់ថ្នាំបង្ការជំងឺកូវីដ-១៩ ហេតុនេះមន្ត្រីទាំងនេះគួរត្រូវបានការពារ។
- ការផ្តល់ថ្នាំបង្ការនឹងត្រូវផ្តល់ជូននៅតាមមន្ទីរពេទ្យនិងមណ្ឌលសុខភាព។
- ការផ្តល់ថ្នាំបង្ការដល់មន្ត្រីយោធា និងមន្ត្រីនគរបាលនឹងត្រូវធ្វើដោយនាយកដ្ឋានសុខាភិបាលនៃក្រសួងសាមីដោយមានការបណ្តុះបណ្តាលពីកម្មវិធីជាតិផ្តល់ថ្នាំបង្ការ។
- ការផ្តល់ថ្នាំបង្ការនឹងត្រូវបានធ្វើក្នុងដំណាក់កាលទី ១។

### ៥.១.៣. រចនាសម្ព័ន្ធសហគមន៍ រួមទាំងអ្នកស្ម័គ្រចិត្ត

- ក្រុមនេះរាប់បញ្ចូលទាំងសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ មេភូមិ អនុភូមិ សមាជិកភូមិ សមាជិកគណៈកម្មការគ្រប់គ្រងមណ្ឌលសុខភាព និងអ្នកស្ម័គ្រចិត្ត ដូចជាក្រុមទ្រទ្រង់សុខភាពភូមិ ភ្នាក់ងារគ្រុនចាញ់ អ្នកស្ម័គ្រចិត្តកាកបាទក្រហម។ ក្រុមនេះមានសារៈសំខាន់ណាស់ក្នុងការជួយប្រាស្រ័យទាក់ទង និងកៀងគរសហគមន៍ឱ្យទៅទទួលថ្នាំបង្ការ និងសេវាសុខភាពផ្សេងទៀត។
- ការផ្តល់ថ្នាំបង្ការនឹងត្រូវធ្វើឡើងនៅមន្ទីរពេទ្យ និងមណ្ឌលសុខភាព។
- ការផ្តល់ថ្នាំបង្ការនឹងត្រូវធ្វើក្នុងដំណាក់កាលទី ១។

### ៥.១.៤. ប្រជាជនវ័យចំណាស់អាយុចាប់ពី ៦៥ ឆ្នាំឡើងទៅ

- ភស្តុតាងដែលមានកន្លងមកបញ្ជាក់ថា ក្រុមមនុស្សដែលមានអាយុចាប់ពី ៦៥ ឆ្នាំ ឡើងទៅគឺជា ក្រុមដែលមានហានិភ័យខ្ពស់ ក្នុងការវិវត្តទៅជាផលវិបាកធ្ងន់ធ្ងរពីជំងឺកូវីដ-១៩។
- ក្រុមនេះនឹងទទួលការផ្តល់ថ្នាំបង្ការតាមរយៈការចុះផ្តល់សេវាដល់មូលដ្ឋាននៅភូមិ នៅមន្ទីរពេទ្យ និងមណ្ឌលសុខភាព។
- ការផ្តល់ថ្នាំបង្ការនឹងត្រូវធ្វើក្នុងដំណាក់កាលទី ២ លើកលែងតែនៅរាជធានីភ្នំពេញ ដែលការផ្តល់ថ្នាំបង្ការនឹងត្រូវធ្វើក្នុងដំណាក់កាលទី ១។

### ៥.១.៥. មនុស្សពេញវ័យអាយុ ១៨-៦៤ ឆ្នាំ ដែលមានហានិភ័យខ្ពស់ (មានជំងឺទឹកនោមផ្អែម ជំងឺលើសឈាម...)

- ក្រុមនេះត្រូវបានកំណត់ដល់អ្នកទាំងឡាយណាដែលមានអាយុចាប់ពី ១៨-៦៤ ឆ្នាំ ហើយដែលមានជំងឺរ៉ាំរ៉ៃប្រចាំកាយ ដូចជាជំងឺលើសឈាម ជំងឺទឹកនោមផ្អែម ជំងឺរបេងសួតសួត ជំងឺបេះដូង និងជំងឺមហារីក។ល។

- ក្រុមនេះនឹងទទួលការផ្តល់ថ្នាំបង្ការតាមរយៈការចុះផ្តល់សេវាដល់មូលដ្ឋាននៅភូមិ ឬនៅមន្ទីរពេទ្យនិងមណ្ឌលសុខភាព។
- ការផ្តល់ថ្នាំបង្ការនឹងត្រូវធ្វើក្នុងដំណាក់កាលទី ២ ។

### ៥.១.៦. កម្មករ-ការនីរោងចក្រកាត់ដេរ និងកម្មករ-កម្មការិនីផ្សេងទៀត

- ក្រុមកម្មករ-ការនីរោងចក្រកាត់ដេរ និងកម្មករ-កម្មការិនីផ្សេងទៀតត្រូវបានកំណត់ដល់កម្មករ-ការនីដែលត្រូវបានជ្រើសរើសជាផ្លូវការឱ្យបម្រើការងារនៅរោងចក្រ-ការដ្ឋាន ដែលមានអាជ្ញាប័ណ្ណរបស់ រដ្ឋាភិបាល។
- ក្រុមនេះនឹងបានទទួលថ្នាំបង្ការនៅក្នុងបរិវេណរោងចក្រ-ការដ្ឋាន ដែលពួកគេកំពុងបម្រើការងារ។
- ការផ្តល់ថ្នាំបង្ការនឹងត្រូវធ្វើក្នុងដំណាក់កាលទី ២។

### កំណត់សម្គាល់៖

ស្ត្រីមានផ្ទៃពោះនិងកុមារមិនត្រូវបានអនុសាសន៍ឱ្យទទួលថ្នាំបង្ការជំងឺកូវីដ-១៩ ទេនៅពេលនេះ។

**ស្ត្រីមានផ្ទៃពោះ**

ដោយពុំមានទិន្នន័យគ្រប់គ្រាន់ស្តីអំពីសុវត្ថិភាពនិងប្រសិទ្ធិភាពនៃថ្នាំបង្ការជំងឺកូវីដ-១៩ ក្រុមប្រឹក្សាអ្នកឯកទេសយុទ្ធសាស្រ្តផ្តល់ថ្នាំបង្ការនិងវ៉ាក់សាំង (SAGE) នៃអង្គការសុខភាពពិភពលោកពុំបានអនុសាស ចាត់បញ្ចូលស្ត្រីមានផ្ទៃពោះជាក្រុមអាទិភាពសម្រាប់ការទទួលថ្នាំបង្ការជំងឺកូវីដ-១៩ ទេនាពេលបច្ចុប្បន្ន។

**កុមារអាយុក្រោម ១៨ ឆ្នាំ**

យោងតាមសេចក្តីថ្លែងការនៃក្រុមប្រឹក្សាអ្នកឯកទេសយុទ្ធសាស្រ្តផ្តល់ថ្នាំបង្ការនិងវ៉ាក់សាំង នៃអង្គការសុខភាពពិភពលោក ទោះការរាតត្បាតសកលនៃជំងឺកូវីដ-១៩ នេះបានប៉ះពាល់ធ្ងន់ធ្ងរសុខមាលភាពកុមារក្តី កុមារមិនត្រូវបានចាត់បញ្ចូលជាក្រុមអាទិភាពចំណុចទេដោយហេតុផលពីរ៖ ទីមួយ ពុំទាន់មានការសិក្សាសាកល្បងនៃបេក្ខភាពថ្នាំបង្ការជំងឺកូវីដ-១៩ លើកុមារនៅឡើយ។ ទីពីរ កុមារពុំប្រឈមនឹងការកើតមានជំងឺធ្ងន់ធ្ងរនិងបាត់បង់ជីវិតដោយសារជំងឺកូវីដ។ ហេតុនេះកុមារអាយុក្រោម ១៨ ឆ្នាំនឹងត្រូវបញ្ចូលជាក្រុមចំណុចនៅពេលក្រោយ ពេលដែលមានភ័ស្តុតាងគ្រប់គ្រាន់ និងទៅតាមបច្ចុប្បន្នភាពនៃអនុសាសន៍របស់អង្គការសុខភាពពិភពលោក។

## ៥.២. ការធ្វើសម្រង់ក្រុមចំណុចអាទិភាព

ការធ្វើសម្រង់ក្រុមចំណុចគួរត្រូវបានធ្វើទៅដោយក្រសួង-មន្ទីរនិងស្ថាប័នសាមី ឬរដ្ឋបាលមូលដ្ឋាន។ លិខិតជូនព័ត៌មានស្តីពីការធ្វើសម្រង់ក្រុមចំណុចនឹងត្រូវបានផ្ញើរជូនទៅក្រសួង-មន្ទីរ ស្ថាប័ន និងរដ្ឋបាលមូលដ្ឋានទាំងនោះ ដោយគណៈកម្មការអន្តរក្រសួងប្រយុទ្ធនឹងជំងឺកូវីដ-១៩។

### ក. នៅថ្នាក់កណ្តាល៖

- បញ្ជីមន្ត្រីរាជការនៃទីស្តីការក្រសួង-មន្ទីរ ស្ថាប័ន នៃរាជរដ្ឋាភិបាលរួមទាំងក្រសួងសុខាភិបាល ដែលត្រូវទទួលថ្នាំបង្ការជំងឺកូវីដ-១៩ គួរត្រូវបានផ្តល់ដោយនាយកដ្ឋានបុគ្គលិកនៃទីស្តីការក្រសួង-មន្ទីរ ស្ថាប័ននោះ។

- បញ្ជីបុគ្គលិកថែទាំសុខភាពនិងបុគ្គលិកជំនួយ នៃមន្ទីរពេទ្យ-គ្លីនិកឯកជននិងអង្គការមិនមែនរដ្ឋាភិបាល ដែលបានចុះបញ្ជីជាមួយក្រសួងសុខាភិបាល គួរត្រូវបានផ្តល់ដោយមន្ទីរពេទ្យ-គ្លីនិកឯកជន និងអង្គការមិនមែនរដ្ឋាភិបាលទាំងនោះទៅក្រសួងសុខាភិបាល។
- ក្រុមអាទិភាពចំណុចនេះនឹងទទួលថ្នាំបង្ការជំងឺកូវីដ-១៩ នៅមន្ទីរពេទ្យជាតិ និងកន្លែងផ្តល់ថ្នាំបង្ការផ្សេងទៀតដែលកំណត់ដោយក្រសួងសុខាភិបាល។

## ខ. នៅថ្នាក់រាជធានី-ខេត្តៈ

- បញ្ជីមន្ត្រីរាជការនៃរដ្ឋបាលរាជធានី-ខេត្ត មន្ទីរជំនាញជុំវិញរដ្ឋបាលរាជធានី-ខេត្ត មន្ត្រីយោធា កងរាជអាវុធហត្ថ មន្ត្រីនគរបាល គួរត្រូវបានស្រង់ដោយការិយាល័យបុគ្គលិកនៃរដ្ឋបាលរាជធានី-ខេត្ត ឬមន្ទីរជំនាញទាំងនោះ និងផ្តល់ជូនទៅមន្ទីរសុខាភិបាលរាជធានី-ខេត្ត តាមរយៈទីចាត់ការរដ្ឋបាលសាលារាជធានី-ខេត្ត ។
- ក្រុមអាទិភាពចំណុចនេះនឹងទទួលថ្នាំបង្ការជំងឺកូវីដ-១៩ កន្លែងផ្តល់ថ្នាំបង្ការដែលបានកំណត់ដោយក្រសួងសុខាភិបាល ដូចខាងក្រោមៈ
  - ក្រុមអាទិភាពចំណុចនៅរាជធានីភ្នំពេញ នឹងទទួលថ្នាំបង្ការជំងឺកូវីដ-១៩ នៅមន្ទីរពេទ្យជាតិ។
  - ក្រុមអាទិភាពចំណុចនៅថ្នាក់ខេត្ត នឹងទទួលថ្នាំបង្ការជំងឺកូវីដ-១៩ នៅមន្ទីរពេទ្យខេត្ត ឬនិងកន្លែងផ្តល់ថ្នាំបង្ការផ្សេងទៀតដែលកំណត់ដោយក្រសួងសុខាភិបាល។

## គ. នៅថ្នាក់ខណ្ឌ-ក្រុង-ស្រុកៈ

១. *មន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលខណ្ឌ-ក្រុង-ស្រុក ការិយាល័យជំនាញជុំវិញរដ្ឋបាលខណ្ឌ-ក្រុង-ស្រុក មន្ត្រីយោធា កងរាជអាវុធហត្ថ និងនគរបាល*

- បញ្ជីនៃក្រុមអាទិភាពចំណុចនេះគួរត្រូវបានស្រង់ដោយរដ្ឋបាលសាលាខណ្ឌ-ក្រុង-ស្រុក ការិយាល័យជំនាញជុំវិញរដ្ឋបាលសាលាខណ្ឌ-ក្រុង-ស្រុក និងស្ថាប័នផ្សេងទៀត និងផ្តល់ជូនទៅការិយាល័យស្រុកប្រតិបត្តិតាមរយៈទីចាត់ការរដ្ឋបាលសាលាខណ្ឌ-ក្រុង-ស្រុក ។
- ក្រុមអាទិភាពចំណុចនេះនឹងទទួលថ្នាំបង្ការជំងឺកូវីដ-១៩ នៅកន្លែងផ្តល់ថ្នាំបង្ការដែលបានកំណត់ដោយក្រសួងសុខាភិបាល ដូចខាងក្រោមៈ
  - នៅមន្ទីរពេទ្យជាតិ សម្រាប់ក្រុមអាទិភាពចំណុចនៃរដ្ឋបាលខណ្ឌ។
  - នៅមន្ទីរពេទ្យខេត្ត សម្រាប់ក្រុមអាទិភាពចំណុចនៃរដ្ឋបាលក្រុង។
  - នៅមន្ទីរពេទ្យបង្អែកស្រុកប្រតិបត្តិ សម្រាប់ក្រុមអាទិភាពចំណុចនៃរដ្ឋបាលស្រុក។

២. *កម្មករ-ការិនី*

- បញ្ជីកម្មករ-ការិនីរោងចក្រកាត់ដេរ និងរោងចក្រ-សហគ្រាស ឬការដ្ឋានសំណង់ នៅក្នុងខណ្ឌ-ក្រុង-ស្រុកមួយ គួរត្រូវបានស្រង់ដោយការិយាល័យការងារខណ្ឌ-ក្រុង-ស្រុក និងផ្តល់ជូនទៅការិយាល័យស្រុកប្រតិបត្តិតាមរយៈទីចាត់ការរដ្ឋបាលសាលាខណ្ឌ-ក្រុង-ស្រុក។

### ឃ. នៅថ្នាក់ឃុំ-សង្កាត់៖

១. *បុគ្គលិកមណ្ឌលសុខភាព គណៈកម្មការគ្រប់គ្រងមណ្ឌលសុខភាព មនុស្សពេញវ័យ អាយុ ១៨-៦៤ ឆ្នាំ ហានិភ័យខ្ពស់*
   - បញ្ជីបុគ្គលិកមណ្ឌលសុខភាព សមាជិកគណៈកម្មការគ្រប់គ្រងមណ្ឌលសុខភាព មនុស្សពេញវ័យ អាយុ ១៨-៦៤ ឆ្នាំ ដែលមានហានិភ័យខ្ពស់ (មានជំងឺទឹកនោមផ្អែម ជំងឺលើសឈាម...) គួរត្រូវបានស្រង់ដោយមណ្ឌលសុខភាពសម្រាប់តំបន់គ្របដណ្តប់របស់ខ្លួន។
   - ក្រុមអាទិភាពចំណុចនេះនឹងទទួលថ្នាំបង្ការជំងឺកូវីដ-១៩ នៅមណ្ឌលសុខភាព។

២. *មន្ត្រីរដ្ឋបាលស៊ីវិលនិងនគរបាលនៃរដ្ឋបាលឃុំ-សង្កាត់*
   - បញ្ជីក្រុមប្រឹក្សាឃុំ-សង្កាត់ មន្ត្រីរដ្ឋបាលឃុំ-សង្កាត់ មន្ត្រីប៉ុស្តិ៍នគរបាលឃុំ-សង្កាត់ មេភូមិ អនុភូមិ សមាជិកភូមិ ក្រុមប្រជាការពារ ក្រុមទ្រទ្រង់សុខភាពភូមិ អ្នកស្ម័គ្រចិត្តសុខភាពផ្សេងទៀត និងប្រជាជនវ័យចំណាស់អាយុចាប់ពី ៦៥ ឆ្នាំឡើងទៅ ដែលរស់នៅក្នុងតំបន់គ្របដណ្តប់របស់មណ្ឌលសុខភាព គួរត្រូវស្រង់ដោយរដ្ឋបាលសាលាឃុំ-សង្កាត់ និងប្រគល់ទៅមណ្ឌលសុខភាពដែលគ្របដណ្តប់ឃុំ-សង្កាត់នោះ។
   - ក្រុមប្រឹក្សាឃុំ-សង្កាត់ មន្ត្រីរដ្ឋបាលឃុំ-សង្កាត់ មន្ត្រីប៉ុស្តិ៍នគរបាលឃុំ-សង្កាត់ មេភូមិ អនុភូមិ សមាជិកភូមិ ក្រុមប្រជាការពារ ក្រុមទ្រទ្រង់សុខភាពភូមិ អ្នកស្ម័គ្រចិត្តសុខភាពផ្សេងទៀតនឹងទទួលថ្នាំបង្ការជំងឺកូវីដ-១៩ នៅមណ្ឌលសុខភាព។
   - ប្រជាជនវ័យចំណាស់អាយុចាប់ពី ៦៥ ឆ្នាំឡើងទៅ នឹងទទួលថ្នាំបង្ការជំងឺកូវីដ-១៩ តាមការចុះផ្តល់សេវាដល់មូលដ្ឋាន។

### វិធីសាស្ត្រធ្វើសម្រង់ក្រុមមនុស្សពេញវ័យ អាយុ ១៨-៦៤ ឆ្នាំ មានហានិភ័យខ្ពស់

1. មណ្ឌលសុខភាព ដោយមានការគាំទ្រពីសហគមន៍នឹងធ្វើការលើកទឹកចិត្តការចុះឈ្មោះរបស់ក្រុមមនុស្សពេញវ័យ អាយុ ១៨-៦៤ ឆ្នាំ ដែលមានហានិភ័យខ្ពស់ នៅនឹងមណ្ឌលសុខភាព។
2. ការធ្វើសម្រង់ក្រុមអាទិភាពចំណុចនេះ ត្រូវធ្វើឡើងទៅតាមលក្ខខ័ណ្ឌខាងក្រោម៖
   - សួររកវេជ្ជបញ្ជាឬឯកសារវេជ្ជសាស្ត្រ សម្រាប់អ្នកដែលដឹងថាខ្លួនមានជំងឺបេះដូង-សរសៃឈាម ជំងឺទឹកនោមផ្អែម ជំងឺសួត ជំងឺមហារីក ជំងឺប្រព័ន្ធភាពស៊ាំ ជំងឺផ្លូវចិត្ត ជំងឺរ៉ាំរ៉ៃ ឬមានពិការភាព។
   - ពិនិត្យរកកំណត់ត្រានៅមូលដ្ឋានសុខាភិបាល (មជ្ឈមណ្ឌលទឹកនោមផ្អែម មណ្ឌលសុខភាព...)
   - ពិនិត្យនៅនឹងមូលដ្ឋានសុខាភិបាល៖

| ជំងឺ | ការធ្វើតេស្ត | មានហានិភ័យខ្ពស់? |
|---|---|---|
| មានជំងឺលើសសម្ពាធឈាម | • វាស់សម្ពាធឈាម ដោយវាស់ ២ ដង ចន្លោះពី ១៥-៣០ នាទី | បើសម្ពាធស៊ីស្តូលីកលើសពី ១៤០មមបារ៉ត ក្នុងការវាស់ទាំង ២ លើក |
| មានជំងឺទឹកនោមផ្អែម | • ជោះពេលព្រឹក មុនទទួលទានអាហារ (ពេលពោះទទេរ) | បើកម្រិតជាតិស្ករក្នុងឈាម ១២៣ មីល្លីក្រាម ក្នុង ១ ដេស៊ីលីត្រ ឬលើស |

# ជំពូកទី ៦ -  ការធ្វើផែនការ និងការបណ្តុះបណ្តាល

យុទ្ធនាការផ្តល់ថ្នាំបង្ការជំងឺកូវីដ-១៩ នឹងត្រូវការការគាំទ្រដ៏សម្បើមផ្នែកធនធានមនុស្ស ចាប់ពីថ្នាក់ជាតិ រហូតដល់ថ្នាក់មណ្ឌលសុខភាព។ លើសពីបទពិសោធន៍របស់ខ្លួននៅក្នុងសេវាផ្តល់ថ្នាំបង្ការនិងយុទ្ធនាការផ្តល់ថ្នាំបង្ការ កម្ពុជាគឺជាឧទាហរណ៍ដ៏ល្អ នៃការអនុវត្តប្រកបដោយជោគជ័យក្នុងយុទ្ធនាការផ្តល់ថ្នាំបង្ការជំងឺផ្តាសាយធំ (H1N1) នៅក្នុងតំបន់ប៉ាស៊ីហ្វិកខាងលិច នាឆ្នាំ ២០១០។

ក្នុងអំឡុងដំណើរការធ្វើផែនការ ក្រសួងសុខាភិបាលបានកំណត់គោលការណ៍ដូចខាងក្រោម សម្រាប់ការផ្តល់ថ្នាំបង្ការជំងឺកូវីដ-១៩៖

- សុវត្ថិភាពនិងប្រសិទ្ធិភាពនៃថ្នាំបង្ការជាឧបករណ៍ដ៏មានសក្តានុពល ក្នុងការបង្ការជំងឺកូវីដ-១៩ និងបញ្ចប់ការរាតត្បាតសកល។
- ភាពជាអ្នកដឹកនាំរបស់រដ្ឋាភិបាល និងភាពជាម្ចាស់នៃប្រទេស ព្រមទាំងការគាំទ្រដោយមានការសម្របសម្រួលនៃដៃគូនានា។
- បរិបទនៃប្រទេស ជាមួយនឹងអភិក្រមអនុវត្ត។
- ការប្រើប្រាស់ប្រព័ន្ធ យន្តការ ធនធាន សមត្ថភាព និងរចនាសម្ព័ន្ធដែលមានស្រាប់។
- កំណត់រកសមត្ថភាពនិងធនធានបន្ថែមដែលត្រូវការ សម្រាប់ស្ថានភាពដែលមិនច្បាស់លាស់ និងការអនុវត្តន៍ដោយជោគជ័យ។
- ការប្រើប្រាស់ការផ្តល់ថ្នាំបង្ការជំងឺកូវីដ-១៩ ជាកាលានុវត្តភាពសម្រាប់ការធ្វើឱ្យប្រសើរឡើង និងការជម្រុញវឌ្ឍនភាពនៃកម្មវិធីផ្តល់ថ្នាំបង្ការ និងប្រព័ន្ធសុខាភិបាល សម្រាប់អនាគត។
- ការប្រើប្រាស់ថ្នាំបង្ការជំងឺកូវីដ-១៩ ជាឧបករណ៍និងវិធានការណ៍សុខភាពសាធារណៈ។

ផែនការលម្អិតជាឧបករណ៍ដែលនឹងធានាថា ថ្នាំបង្ការជំងឺកូវីដ-១៩ នឹងទៅដល់ប្រជាជនចំណុច។ នេះគឺជាដំណើរការធ្វើផែនការពីថ្នាក់ក្រោមមកលើដែលជួយក្នុងការកំណត់ថវិកាតាមរយៈការធ្វើផែនការលម្អិតអំពីធនធានមនុស្ស និងសម្ភារៈបរិក្ខាដែលត្រូវការសម្រាប់ការផ្តល់ថ្នាំបង្ការជំងឺកូវីដ-១៩ និងជួយដល់ការកំណត់រកឧបសគ្គ និងសកម្មភាពសមស្របដែលអាចមាន។ ឆន្ទៈនិងការចូលរួមរបស់សហគមន៍ និងអ្នកដែលពាក់ព័ន្ធផ្សេងទៀត និងការកំណត់រកប្រភពធនធាន គឺជាកត្តាដ៏មានសារៈសំខាន់ដែលត្រូវមានជាមុន សម្រាប់ការធ្វើផែនការលម្អិតប្រកបដោយប្រសិទ្ធិភាព។

ផែនការលម្អិតនឹងត្រូវបានធ្វើដោយមណ្ឌលសុខភាព ស្រុកប្រតិបត្តិ និងមន្ទីរសុខាភិបាល (ឧបសម្ព័ន្ធទី៣ ៤ និង៥)។ ផែនការលម្អិតរបស់មណ្ឌលសុខភាពនឹងត្រូវបានពិនិត្យផ្ទៀងផ្ទាត់និងអនុមតិដោយស្រុកប្រតិបត្តិ។ ផែនការលម្អិតរបស់ស្រុកប្រតិបត្តិនឹងត្រូវបានពិនិត្យផ្ទៀងផ្ទាត់និងអនុមតិដោយមន្ទីរសុខាភិបាល។ គំរូផែនការលម្អិតត្រូវបានរៀបចំដោយកម្មវិធីជាតិផ្តល់ថ្នាំបង្ការ។ នៅថ្នាក់ជាតិនឹងមានផែនការរួមដែលសង្ខេបផែនការលម្អិតពីគ្រប់លំដាប់ថ្នាក់។

កម្មវិធីជាតិផ្តល់ថ្នាំបង្ការត្រូវបានបំពាក់សមត្ថភាពផ្នែកធនធានមនុស្ស តាំងពីថ្នាក់ជាតិរហូតដល់ថ្នាក់មណ្ឌលសុខភាព។ ទោះជាយ៉ាងនេះក្តី មន្ត្រីកម្មវិធីជាតិមួយចំនួនត្រូវបានចូលនិវត្តន៍ ហើយបុគ្គលិកកិច្ចសន្យាត្រូវបានជ្រើសរើស

ឱ្យបម្រើការនៅក្នុងមណ្ឌលសុខភាពមួយចំនួន។ ក្នុងករណីដែលធនធានមនុស្សពុំមានគ្រប់គ្រាន់នៅក្នុងស្រុកប្រតិបត្តិឬមណ្ឌលសុខភាពមួយចំនួន ការចល័តមន្ត្រីសុខាភិបាលពីស្រុកប្រតិបត្តិជិតខាងនឹងត្រូវបានធ្វើដើម្បីជំរុញការអនុវត្តយុទ្ធនាការផ្តល់ថ្នាំបង្ការជំងឺកូវីដ-១៩។ ជាអន្តរកាល នឹងមានការកៀរគរឱ្យមានការចូលរួមរបស់និស្សិតនៃសកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល ឬសកលវិទ្យាល័យវេជ្ជសាស្ត្រផ្សេងទៀត សមាជិកកាកបាទក្រហម ព្រមទាំងគិលានុបដ្ឋាក-យិកា/ឆ្មបពីគ្លីនិកឯកជន។ ស្រុកប្រតិបត្តិទាំងអស់នឹងបញ្ជូនបញ្ជីឈ្មោះបុគ្គលិកឬអ្នកផ្តល់សេវា ទៅមន្ទីរសុខាភិបាលខេត្ត ហើយមន្ទីរសុខាភិបាលខេត្តនឹងដាក់ជូនទៅថ្នាក់ជាតិ យ៉ាងហោចណាស់ក្នុងអំឡុងរយៈពេលពីរខែមុនពេលធ្វើយុទ្ធនាការផ្តល់ថ្នាំបង្ការ។

មន្ត្រីកម្មវិធីជាតិផ្តល់ថ្នាំបង្ការ មន្ត្រីមន្ទីរសុខាភិបាលខេត្ត និងស្រុកប្រតិបត្តិទទួលខុសត្រូវក្នុងការធ្វើផែនការ ការត្រៀមរៀបចំ និងការអនុវត្តយុទ្ធនាការផ្តល់ថ្នាំបង្ការជំងឺកូវីដ-១៩ ការបណ្តុះបណ្តាលដល់បុគ្គលិកដែលចូលរួមក្នុងយុទ្ធនាការ និងការអភិបាលនិងតាមដានយុទ្ធនាការ។ កម្មវិធីជាតិផ្តល់ថ្នាំបង្ការ ដោយមានការគាំទ្រពីដៃគូនេះនឹងរៀបចំធ្វើផែនការនិងសិក្ខាសាលាបណ្តុះបណ្តាលនៅថ្នាក់ជាតិ សម្រាប់មន្ត្រីមន្ទីរសុខាភិបាលខេត្តនិងស្រុកប្រតិបត្តិដែលចូលរួមក្នុងយុទ្ធនាការជាតិផ្តល់ថ្នាំបង្ការជំងឺកូវីដ-១៩។ បន្ទាប់មកកម្មវិធីជាតិផ្តល់ថ្នាំបង្ការ រួមនឹងមន្ទីរសុខាភិបាលខេត្តនិងដៃគូនឹងជួយស្រុកប្រតិបត្តិ ក្នុងការរៀបចំធ្វើផែនការ និងការបណ្តុះបណ្តាលនៅថ្នាក់ស្រុកប្រតិបត្តិសម្រាប់មណ្ឌលសុខភាព។ មណ្ឌលសុខភាពនឹងធ្វើការតម្រង់ទិសខ្លី សម្រាប់ក្រុមអ្នកស្ម័គ្រចិត្ត និងបណ្តាញសហគមន៍ភ្លាម។

ក្នុងអំឡុងពេលនៃការបណ្តុះបណ្តាល តួនាទីនិងការទទួលខុសត្រូវរបស់មន្ត្រីនៅគ្រប់លំដាប់ថ្នាក់នឹងត្រូវបានផ្សព្វផ្សាយ។ កម្មវិធីជាតិផ្តល់ថ្នាំបង្ការទទួលបន្ទុករៀបចំផែនការបណ្តុះបណ្តាល។ អ្នកពាក់ព័ន្ធទាំងអស់និងអ្នកចូលរួមនៅគ្រប់លំដាប់ថ្នាក់ត្រូវគិតគូ និងយកចិត្តទុកដាក់កម្រិតខ្ពស់ថា យុទ្ធនាការផ្តល់ថ្នាំបង្ការជំងឺកូវីដ-១៩ នឹងមិនរារាំងដល់សេវាផ្តល់ថ្នាំបង្ការជាប្រចាំទេ។

## ៦.១. ការបណ្តុះបណ្តាល ការតម្រង់ទិស និងការរៀបចំផែនការលម្អិត

យោងតាមគោលការណ៍ណែនាំប្រតិបត្តិនេះ ការបណ្តុះបណ្តាល ការតម្រង់ទិស និងផែនការលម្អិតនឹងត្រូវបានបង្កើតឡើង។ ផែនការបណ្តុះបណ្តាលនឹងត្រូវរៀបចំឡើងដោយវិស័យសុខាភិបាល ចាប់តាំងពីថ្នាក់ជាតិរហូតដល់មណ្ឌលសុខភាព ដោយប្រើប្រាស់ទម្រង់ (ឧបសម្ព័ន្ធទី៦។) ។

សកម្មភាពបណ្តុះបណ្តាលនិងតម្រង់ទិស៖

- វគ្គបណ្តុះបណ្តាលរយៈពេល ៣ ថ្ងៃសម្រាប់គ្រូបង្គោល មកពីមន្ទីរសុខាភិបាលរាជធានី-ខេត្តនិងស្រុកប្រតិបត្តិ ស្តីពីយុទ្ធនាការផ្តល់ថ្នាំបង្ការជំងឺកូវីដ-១៩។
- វគ្គបណ្តុះបណ្តាលរយៈពេល ២ ថ្ងៃសម្រាប់បុគ្គលិកមណ្ឌលសុខភាព នៅការិយាល័យស្រុកប្រតិបត្តិ ស្តីពីយុទ្ធនាការផ្តល់ថ្នាំបង្ការជំងឺកូវីដ-១៩។
- ការតម្រង់ទិសរយៈពេល ១ ថ្ងៃសម្រាប់រចនាសម្ព័ន្ធសហគមន៍ រួមទាំងក្រុមប្រឹក្សាឃុំ-សង្កាត់ និង មេភូមិ អនុភូមិ សមាជិកភូមិ ក្រុមទ្រទ្រង់សុខភាពភូមិ ស្តីពីយុទ្ធនាការផ្តល់ថ្នាំបង្ការជំងឺកូវីដ-១៩។

### ៦.១.១. ការបណ្តុះបណ្តាលគ្រូបង្គោល និងផែនការលម្អិត

កម្មវិធីជាតិផ្តល់ថ្នាំបង្ការនឹងរៀបចំវគ្គបណ្តុះបណ្តាលគ្រូបង្គោល ស្តីអំពីយុទ្ធនាការផ្តល់ថ្នាំបង្ការជំងឺកូវីដ-១៩ និងការធ្វើផែនការលម្អិត (microplanning) ដែលមានរយៈពេល ៣ ថ្ងៃ សម្រាប់ប្រធានមន្ទីរ និងប្រធានកម្មវិធីផ្តល់ថ្នាំបង្ការនៃមន្ទីរសុខាភិបាលរាជធានី-ខេត្ត និងប្រធានការិយល័យស្រុកប្រតិបត្តិនិងប្រធានកម្មវិធីផ្តល់ថ្នាំបង្ការនៃស្រុកប្រតិបត្តិ ។

ខ្លឹមសារនៃវគ្គបណ្តុះបណ្តាលរួមមាន៖

1. ការធ្វើផែនការលម្អិត
2. ក្រុមចំណុចអាទិភាព
3. សម្រង់ក្រុមចំណុចអាទិភាព
4. ផែនការយុទ្ធសាស្ត្រសម្រាប់យុទ្ធនាការផ្តល់ថ្នាំបង្ការជំងឺកូវីដ-១៩ និងការប្រាស្រ័យទាក់ទងនិងការកៀរគរសហគមន៍
5. ការអភិបាលយុទ្ធនាការផ្តល់ថ្នាំបង្ការជំងឺកូវីដ-១៩
6. ការតាមដាន និងការគ្រប់គ្រងទិន្នន័យ
7. ការរាយការ។

### ៦.១.២. ការបណ្តុះបណ្តាល និងការធ្វើផែនការលម្អិតរបស់ស្រុកប្រតិបត្តិ

គ្រូបង្គោលនៃមន្ទីរសុខាភិបាលរាជធានី-ខេត្ត និងការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ ដែលបានទទួលការបណ្តុះបណ្តាលជាគ្រូបង្គោលនឹងធ្វើការបណ្តុះបណ្តាលអំពីយុទ្ធនាការផ្តល់ថ្នាំបង្ការជំងឺកូវីដ-១៩ និងការធ្វើផែនការលម្អិត ដល់អ្នកផ្តល់ថ្នាំបង្ការមកពីមណ្ឌលសុខភាពនិងមន្ទីរពេទ្យ ដែលមានរយៈពេល ២ ថ្ងៃ នៅការិយាល័យស្រុកប្រតិបត្តិ។

ខ្លឹមសារនៃវគ្គបណ្តុះបណ្តាលរួមមាន៖

1. ក្រុមអាទិភាពចំណុច
2. សម្រង់ក្រុមអាទិភាពចំណុច
3. យុទ្ធនាការផ្តល់ថ្នាំបង្ការជំងឺកូវីដ-១៩
4. របៀបផ្តល់ថ្នាំបង្ការជំងឺកូវីដ-១៩
5. ការកត់ត្រា និងរបាយការណ៍
6. ការគ្រប់គ្រងភស្តុភារ និងការស្នើសុំនិងផ្គត់ផ្គង់វ៉ាក់សាំង
7. ការគ្រប់គ្រងសំណល់ និង
8. ការប្រាស្រ័យទាក់ទង និងការកៀរគរសហគមន៍។

### ៦.១.៣. ការតម្រង់ទិសដល់រចនាសម្ព័ន្ធសហគមន៍

រចនាសម្ព័ន្ធសហគមន៍រួមបញ្ចូលទាំងអ្នកស្ម័គ្រចិត្តសុខភាព នឹងត្រូវបានតម្រង់ទិសអំពីយុទ្ធនាការផ្តល់ថ្នាំបង្ការជំងឺកូវីដ-១៩ និងការរួមចំណែករបស់ពួកគេ។ មន្ត្រីមណ្ឌលសុខភាពនឹងរៀបចំ-ដឹកនាំការតម្រង់ទិស ២ សប្តាហ៍

មុនយុទ្ធនាការ។ មេភូមិ អនុភូមិ សមាជិកភូមិ ក្រុមទ្រទ្រង់សុខភាពភូមិ និងអ្នកស្ម័គ្រចិត្តផ្សេងទៀត គួរត្រូវបានរាប់បញ្ចូលជាអ្នកស្ម័គ្រចិត្ត។

ខ្លឹមសារនៃការតម្រង់ទិសរួមមានៈ

1. ការជូនព័ត៌មានអំពីយុទ្ធនាការផ្តល់ថ្នាំបង្ការជំងឺកូវីដ-១៩
2. ការគាំទ្ររបស់សហគមន៍ដល់យុទ្ធនាការផ្តល់ថ្នាំបង្ការជំងឺកូវីដ-១៩៖
    a. ការកំណត់រកក្រុមអាទិភាពចំណុច
    b. ការកៀរគរ និងការចូលរួមរបស់សហគមន៍
    c. ការរាយការពីហេតុការណ៍ដែលកើតមានក្រោយការផ្តល់ថ្នាំបង្ការ។

## ៦.១.៤. ការរៀបចំផែនការលម្អិត

ផែនការលម្អិតគួរត្រូវបានអភិវឌ្ឍពីក្រោមមកលើ គឺពីមណ្ឌលសុខភាពទៅស្រុកប្រតិបត្តិ និងទៅមន្ទីរសុខាភិបាលរាជធានី-ខេត្ត (ឧបសម្ព័ន្ធ ៣ ៤ ៥)។ ផែនការលម្អិតទាំងអស់នឹងត្រូវបានពិនិត្យ-សម្រេច និងផ្ញើរបន្តដោយថ្នាក់លើបន្ទាប់។ គម្រូនៃផែនការលម្អិតត្រូវបានរៀបចំរួចជាស្រេចដោយកម្មវិធីជាតិផ្តល់ថ្នាំបង្ការ។ នៅថ្នាក់ជាតិ មានផែនការយុទ្ធនាការផ្តល់ថ្នាំបង្ការជំងឺកូវីដ-១៩ រួមដែលមានរួមបញ្ចូលផែនការលម្អិតរបស់គ្រប់លំដាប់ថ្នាក់។

អភិក្រមនៃការអភិវឌ្ឍន៍ផែនការលម្អិតគួរត្រូវបានលំអានដូចខាងក្រោមៈ

- បន្ទាប់ពីទទួលបានការបណ្តុះបណ្តាលជាគ្រូបង្គោល អំពីយុទ្ធនាការផ្តល់ថ្នាំបង្ការជំងឺកូវីដ-១៩ និងការធ្វើផែនការលម្អិត ថ្នាក់ស្រុកប្រតិបត្តិនឹងរៀបចំវគ្គតម្រង់ទិសការអភិវឌ្ឍន៍ផែនការលម្អិតជាមួយប្រធានមណ្ឌលសុខភាពនិងមន្ត្រីផ្តល់ថ្នាំបង្ការនៃមណ្ឌលសុខភាព និងនៃមន្ទីរពេទ្យ។
- មន្ត្រីមណ្ឌលសុខភាពដោយមានជំនួយពីស្រុកប្រតិបត្តិនឹង៖
    - កំណត់ក្រុមអាទិភាពចំណុច (សូមមើលជំពូកទី ៥ ផ្នែក ៥.២ ស្តីអំពីសម្រង់ក្រុមអាទិភាពចំណុច)
    - គូសផែនទីតំបន់គ្រប់ដណ្តប់នៃមណ្ឌលសុខភាព
    - ធ្វើការប៉ាន់ប្រមាណភ័ស្តុភារ និងការផ្គត់ផ្គង់ដែលត្រូវការ រួមទាំងការកំណត់រកក្រុមអ្នកផ្តល់ថ្នាំបង្ការនៃមណ្ឌលសុខភាព ចំនួនប៉ុស្តិ៍ផ្តល់ថ្នាំបង្ការដែលអាចមាន គម្រោងពេលវេលានៃយុទ្ធនាការផ្តល់ថ្នាំបង្ការជំងឺកូវីដ-១៩ ចំនួនដូសថ្នាំបង្ការជំងឺកូវីដ-១៩ និងទឹកលាយដែលត្រូវការ សម្ភារៈ-បរិក្ខាសម្រាប់ផ្តល់ព័ត៌មាន អប់រំ និងប្រាស្រ័យទាក់ទង ព្រមទាំងការផ្គត់ផ្គង់ផ្សេងទៀត។
- មន្ត្រីមណ្ឌលសុខភាពត្រូវបំពេញគម្រូផែនការលម្អិតរបស់មណ្ឌល (ឧបសម្ព័ន្ធទី ៣) និងផ្ញើរទៅស្រុកប្រតិបត្តិ ដើម្បីបញ្ចូលទៅក្នុងផែនការលម្អិតរបស់ស្រុកប្រតិបត្តិ។
- ស្រុកប្រតិបត្តិផ្តុំផែនការលម្អិតរបស់មណ្ឌលសុខភាពទៅក្នុងផែនការលម្អិតរបស់ស្រុកប្រតិបត្តិ (ឧបសម្ព័ន្ធទី ៤) រួចផ្ញើរទៅមន្ទីរសុខាភិបាល។
- មន្ទីរសុខាភិបាលផ្តុំផែនការលម្អិតរបស់ស្រុកប្រតិបត្តិទាំងអស់ ទៅក្នុងផែនការលម្អិតនៃមន្ទីរសុខាភិបាល (ឧបសម្ព័ន្ធទី ៥) រួចផ្ញើរទៅកម្មវិធីជាតិផ្តល់ថ្នាំបង្ការក្នុងអំឡុង ២ សប្តាហ៍ បន្ទាប់ពីទទួលបានការបណ្តុះបណ្តាលដោយកម្មវិធីជាតិ ។

## ៦.២. ក្រុមអ្នកអភិបាលថ្នាក់ជាតិ ថ្នាក់រាជធានី-ខេត្ត និងថ្នាក់ស្រុកប្រតិបត្តិ

ក្រុមអ្នកអភិបាលថ្នាក់ជាតិនឹងត្រូវបានជ្រើសរើសពីកម្មវិធីជាតិផ្តល់ថ្នាំបង្ការ ដៃគូនានា និងពីនាយកដ្ឋានដែលពាក់ព័ន្ធទៅតាមតម្រូវការ។ ក្រុមអ្នកអភិបាលត្រូវធ្វើការអភិបាលដល់ការត្រៀមរៀបចំ និងការអនុវត្តយុទ្ធនាការផ្តល់ថ្នាំបង្ការជំងឺកូវីដ-១៩ នៅគ្រប់លំដាប់ថ្នាក់។

ក្រុមអ្នកអភិបាលថ្នាក់ខេត្តនិងស្រុកប្រតិបត្តិនឹងត្រូវបានបង្កើតឡើងនៅគ្រប់មន្ទីរសុខាភិបាលខេត្ត និងស្រុកប្រតិបត្តិ ដើម្បីអភិបាលនិងតាមដានយុទ្ធនាការផ្តល់ថ្នាំបង្ការជំងឺកូវីដ-១៩ នៅតាមកន្លែងផ្តល់ថ្នាំបង្ការ ទាំងនៅមូលដ្ឋានសុខាភិបាល និងការចុះផ្តល់សេវាដល់មូលដ្ឋាន។

អ្នកអភិបាលស្រុកប្រតិបត្តិម្នាក់ ឬហៅថា អ្នកអភិបាលក្រុម នឹងត្រូវបានចាត់ឱ្យគ្រប់គ្រងក្រុមផ្តល់ថ្នាំបង្ការចំនួន ២-៥ ក្រុម។ អ្នកអភិបាលក្រុមនេះត្រូវចល័ត និងអភិបាលគ្រប់ក្រុមផ្តល់ថ្នាំបង្ការទាំងអស់ដែលខ្លួនទទួលខុសត្រូវក្នុងថ្ងៃនិមួយៗ។

## ៦.៣. សុវត្ថិភាពរបស់មន្ត្រីថែទាំសុខភាពនិងអតិថិជន

សុវត្ថិភាពរបស់មន្ត្រីថែទាំសុខភាព និងប្រជាជនចំណុចនៅនឹងកន្លែងផ្តល់ថ្នាំបង្ការមានសារៈសំខាន់ណាស់។ រាល់មន្ត្រីថែទាំសុខភាពទាំងអស់ចាប់ពីថ្នាក់ជាតិរហូតដល់ថ្នាក់មណ្ឌលសុខភាពដែលចូលរួមក្នុងយុទ្ធនាការផ្តល់ថ្នាំបង្ការជំងឺកូវីដ-១៩ ត្រូវអនុវត្តតាមវិធានការការពារដែលបានណែនាំដោយក្រសួងសុខាភិបាល រួមទាំងវិធានការការពារដែលមានចែងក្នុង "គោលការណ៍ណែនាំអន្តរកាលនៃកម្មវិធីជាតិផ្តល់ថ្នាំបង្ការ ក្នុងអំឡុងពេលនិងក្រោយការរាលដាលជាសកលនៃជំងឺកូវីដ-១៩"។ កម្មវិធីជាតិផ្តល់ថ្នាំបង្ការនឹងផ្តល់សម្ភារៈការពារបុគ្គលមួយចំនួនដូចជាម៉ាស់ អាល់កុល/ជែលលាងសម្អាតដៃ និងស្រោមដៃសម្រាប់មន្ត្រីសុខាភិបាលដែលចូលរួមក្នុងយុទ្ធនាការផ្តល់ថ្នាំបង្ការជំងឺកូវីដ-១៩ ជាផ្នែកនៃវិធានការណ៍ការពារ។

- មន្ត្រីថែទាំសុខភាពត្រូវប្រកាន់ខ្ជាប់ និងអនុវត្តវិធានការណ៍ដើម្បីបង្ការការឆ្លងរោគ (IPC) ស្តង់ដា មុនពេល ក្នុងអំឡុងពេល និងក្រោយពេលផ្តល់ថ្នាំបង្ការ។ នេះរាប់បញ្ចូលទាំងអនាម័យដៃញឹកញាប់ ការអនុវត្តបច្ចេកទេសលាងដៃ ការរក្សាគម្លាតសមស្រប ការប្រើប្រាស់សម្ភារៈការពារបុគ្គលសមស្រប ការសម្អាតនិងការរម្ងាប់មេរោគនៅលើផ្ទៃរាបញឹកញាប់ ព្រមទាំងការទុកដាក់សំណល់ឱ្យបានត្រឹមត្រូវ។
- ក្រុមផ្តល់ថ្នាំបង្ការគួរពិនិត្យជាមុនរាល់អតិថិជន/អ្នកទទួលថ្នាំបង្ការ និងអ្នកមកជាមួយទាំងអស់ ដែលចូលមកដល់កន្លែងផ្តល់ថ្នាំបង្ការមុនពេលផ្តល់ថ្នាំបង្ការដើម្បីបង្ការការចម្លងរោគ។ ការពិនិត្យជាមុនរាប់បញ្ចូលទាំងការវាយតម្លៃពីការប្រឈមជាមួយអ្នកដែលមាន ឬដែលសង្ស័យថាមានជំងឺកូវីដ-១៩ តាមរយៈការពិនិត្យរកសញ្ញា និងរោគសញ្ញា និងការស្ទង់សីតុណ្ហភាព។
- ក្រុមផ្តល់ថ្នាំបង្ការត្រូវតែធានាឱ្យបាននូវគម្លាតសុវត្ថិភាពយ៉ាងតិចមួយម៉ែត្រកន្លះ រវាងអតិថិជនម្នាក់ទៅអតិថិជនម្នាក់ទៀត។

**ការប្រើម៉ាស់៖** ក្រុមផ្តល់ថ្នាំបង្ការគួរប្រើម៉ាស់វេជ្ជសាស្ត្រ/សល្យសាស្ត្រ ក្នុងអំឡុងថ្ងៃផ្តល់ថ្នាំបង្ការដោយប្រើម៉ាស់ ១ ឬ២សម្រាប់យុទ្ធនាការពេញមួយថ្ងៃ។ក្រុមផ្តល់ថ្នាំបង្ការត្រូវប្រកាន់ខ្ជាប់នូវពិធីសារជាតិសម្រាប់ការប្រើប្រាស់ម៉ាស់

**ការប្រើស្រោមដៃ៖** ក្រុមផ្តល់ថ្នាំបង្ការជំងឺកូវីដ-១៩ មិនចាំបាច់ប្រើស្រោមដៃ ពិសេសបើអ្នកផ្តល់ថ្នាំបង្ការមានរបួសនៅនឹងដៃ។ ទោះយ៉ាងនេះក្តី ក្រុមផ្តល់ថ្នាំបង្ការទាំងអស់គួរតែអនុវត្តការលាងដៃញឹកញាប់ និងអនាម័យដៃឱ្យបានត្រឹមត្រូវពេញមួយយុទ្ធនាការ។

**ការប្រើរបាំងការពារមុខ៖** ក្រុមផ្តល់ថ្នាំបង្ការជំងឺកូវីដ-១៩ មិនចាំចាប់ប្រើរបាំងមុខក្នុងអំឡុងពេលផ្តល់ថ្នាំបង្ការជំងឺកូវីដ-១៩។

ក្រសួងសុខាភិបាលនិងកម្មវិធីជាតិផ្តល់ថ្នាំបង្ការ លើកទឹកចិត្តឱ្យមន្ទីរសុខាភិបាលរាជធានី-ខេត្ត និងស្រុកប្រតិបត្តិឱ្យដាក់បញ្ចូលនូវអន្តរាគមន៍សុខភាពផ្សេងទៀតទៅក្នុងការដំណាក់កាលទី ២ នៃយុទ្ធនាការផ្តល់ថ្នាំបង្ការជំងឺកូវីដ-១៩ ។

# ជំពូកទី ៧ - យុទ្ធសាស្ត្រ និងការអនុវត្តផ្តល់ថ្នាំបង្ការ

យុទ្ធសាស្ត្រដែលប្រកបដោយប្រសិទ្ធភាពនិងប្រសិទ្ធផល គឺជាគន្លឹះនៃភាពជោគជ័យរបស់យុទ្ធនាការផ្តល់ថ្នាំបង្ការជំងឺកូវីដ-១៩។ យុទ្ធសាស្ត្រផ្តល់ថ្នាំបង្ការអាស្រ័យលើកត្តាជាច្រើនរួមបញ្ចូលទាំងក្រុមចំណុចដែលបានកំណត់ ចំនួនដូសនៃថ្នាំបង្ការដែលបានទទួល ចំនួនលើកនៃការនាំចូល និងចំនួននៃការដឹកជញ្ជូននៅក្នុងប្រទេស។ ចំនួនដូសថ្នាំបង្ការដែលត្រូវការសរុបនឹងមិនអាចមានក្នុងពេលតែមួយទេនៅកម្ពុជា ដោយថ្នាំបង្ការនឹងមកដល់ជាដំណាក់កាល និងតាមរយៈការដឹកជញ្ជូនច្រើនដើង។

កម្មវិធីជាតិផ្តល់ថ្នាំបង្ការ ដោយមានការគាំទ្រពីដៃគូ បានពិភាក្សានិងពិចារណាលើគ្រប់ទិដ្ឋភាពដែលពាក់ព័ន្ធព្រមទាំងបានបង្កើតយុទ្ធសាស្ត្រផ្តល់ថ្នាំបង្ការ។ ដូច្នេះយុទ្ធនាការផ្តល់ថ្នាំបង្ការជំងឺកូវីដ-១៩ នឹងត្រូវបានអនុវត្តជាពីរដំណាក់កាលនៅកម្ពុជា៖

## ៧.១. កាលវិភាគផ្តល់ថ្នាំបង្ការ

- ដំណាក់កាលទី ១៖ ការផ្តល់ថ្នាំបង្ការដល់ក្រុមអាទិភាពទី ១-៣ រួមទាំងមន្ត្រីថែទាំសុខភាពទាំងអស់ និងមន្ត្រីផ្តល់សេវាសង្គមសំខាន់ៗ ផ្សេងទៀតទូទាំងប្រទេស (សូមអានជំពូកទី ៥ តារាងទី ២ អំពីក្រុមអាទិភាព កម្រិតដូសដែលត្រូវការ និងកន្លែងផ្តល់ថ្នាំបង្ការ)។ សម្រាប់រាជធានីភ្នំពេញ ក្រុមចំណុចទី ៤ (ប្រជាពលរដ្ឋមានវ័យចំណាស់) ត្រូវបានដាក់បញ្ចូលក្នុងដំណាក់កាលទី ១។ ការផ្តល់ថ្នាំបង្ការនឹងត្រូវធ្វើឡើងនៅមណ្ឌលសុខភាពនិងមន្ទីរពេទ្យ។
  <u>កំណត់ពេលវេលា៖ ខែមីនាដល់ខែមេសាឆ្នាំ ២០២១ (ដូសទីមួយ និងដូសទីពីរ)</u>

- ដំណាក់កាលទី ២៖ យុទ្ធនាការផ្តល់ថ្នាំបង្ការសម្រាប់ក្រុមអាទិភាពចំណុចដែលនៅសល់ (ខេត្តដែលនៅសល់ក្រុមចំណុចទី ៤ ក្រុមចំណុចទី ៥ និងទី ៦) ទូទាំងប្រទេស។ ការផ្តល់ថ្នាំបង្ការនឹងត្រូវធ្វើឡើងនៅមណ្ឌលសុខភាពនិងមន្ទីរពេទ្យ និងនៅតាមការចុះផ្តល់សេវាដល់មូលដ្ឋាន។
  <u>កំណត់ពេលវេលា៖ ខែមិថុនាដល់ខែកក្កដាឆ្នាំ ២០២១ (ដូសទីមួយ និងដូសទីពីរ)</u>

## ៧.២. យុទ្ធសាស្ត្រផ្តល់ថ្នាំបង្ការ

### ៧.២.១. ដំណាក់កាលទី ១៖ យុទ្ធសាស្ត្រផ្តល់ថ្នាំបង្ការនៅនឹងមណ្ឌលសុខភាពនិងមន្ទីរពេទ្យ

សេវាផ្តល់ថ្នាំបង្ការនឹងត្រូវបានផ្តល់ជូនតាមរយៈយុទ្ធសាស្ត្រផ្តល់ថ្នាំបង្ការនៅនឹងកន្លែង (មណ្ឌលសុខភាព/មន្ទីរពេទ្យ) សម្រាប់ក្រុមចំណុចអាទិភាពចំនួន ៣ ដំបូង (ក្រុមចំណុចអាទិភាពទី ១-៣) ក្នុងដំណាក់កាលទី ១។ សម្រាប់មន្ត្រីយោធា និងនគរបាលនៅក្នុងបន្ទាយ ថ្នាំបង្ការនឹងត្រូវបញ្ជូនទៅទីនោះ ហើយការផ្តល់ថ្នាំបង្ការនឹងត្រូវបានធ្វើដោយបុគ្គលិកសុខាភិបាលយោធានិងនគរបាល។

សម្រាប់រាជធានីភ្នំពេញ ប្រជាជនមានវ័យចំណាស់ត្រូវបានដាក់បញ្ចូលក្នុងដំណាក់កាលទី១ ហើយការផ្តល់ថ្នាំបង្ការនឹងត្រូវធ្វើឡើងនៅមណ្ឌលសុខភាពនិងមន្ទីរពេទ្យនិងនៅតាមការចុះផ្តល់សេវាដល់មូលដ្ឋាន។

- មណ្ឌលសុខភាពនិងមន្ទីរពេទ្យនឹងផ្តល់ថ្នាំបង្ការដល់ក្រុមចំណុចរាល់ថ្ងៃ ចាប់ពីម៉ោង ០៧ ព្រឹកដល់ម៉ោង ០៥ រសៀល ហើយការផ្តល់ថ្នាំបង្ការនេះនឹងត្រូវបញ្ចប់ក្នុងរយៈពេល ៥ ទៅ៧ ថ្ងៃ។
- សេវាផ្តល់ថ្នាំបង្ការជាប្រចាំនឹងនៅដំណើរការដូចធម្មតា។ មណ្ឌលសុខភាពនិងមន្ទីរពេទ្យនឹងបន្តផ្តល់ថ្នាំបង្ការផ្សេងទៀតទៅតាមកាលវិភាគផ្តល់ថ្នាំបង្ការជាប្រចាំ។
- អ្នកផ្តល់ថ្នាំបង្ការគួរផ្តល់ថ្នាំបង្ការដល់ក្រុមចំណុចដែលមិនបានដឹងអំពីការផ្តល់ថ្នាំបង្ការ ឬមិនបានចុះឈ្មោះ តែបានមកដើម្បីពិគ្រោះជំងឺ ឬទើបបានដឹងតាមរយៈអ្នកផ្សេងទៀត។
- អ្នកផ្តល់ថ្នាំបង្ការគួរផ្តល់ថ្នាំបង្ការដល់ក្រុមចំណុច ដែលកំពុងសម្រាកព្យាបាលក្នុងមន្ទីរពេទ្យដោយសារជំងឺបេះដូង-សរសៃឈាម ជំងឺទឹកនោមផ្អែម ជំងឺសួត ជំងឺមហារីក ជំងឺប្រព័ន្ធភាពស៊ាំ ជំងឺផ្លូវចិត្ត និងអ្នកដែលមានជំងឺរ៉ាំរ៉ៃ ឬមានពិការភាព ។

### ៧.២.២. ដំណាក់កាលទី ២៖ យុទ្ធសាស្ត្រផ្តល់ថ្នាំបង្ការនៅមណ្ឌលសុខភាព-មន្ទីរពេទ្យ និងការចុះផ្តល់ថ្នាំបង្ការដល់មូលដ្ឋាន

នៅដំណាក់កាលទី ២ យុទ្ធនាការនឹងប្រើយុទ្ធសាស្ត្រផ្តល់ថ្នាំបង្ការនៅមណ្ឌលសុខភាព-មន្ទីរពេទ្យ និងតាមការចុះផ្តល់សេវាដល់មូលដ្ឋាន។ ក្រុមចំណុចដែលមិនបានទទួលថ្នាំបង្ការនៅភូមិអាចទៅទទួលថ្នាំបង្ការនៅមណ្ឌលសុខភាពឬមន្ទីរពេទ្យក្នុងអំឡុងពេលផ្តល់ថ្នាំបង្ការ។ ភូមិនិមួយៗនឹងមានការចុះផ្តល់ថ្នាំបង្ការដល់ភូមិយ៉ាងតិចម្តង (លើកលែងភូមិដែលមណ្ឌលសុខភាពតាំងនៅ)។ កន្លែងផ្តល់ថ្នាំបង្ការនឹងបើកដំណើរការពីម៉ោង ០៧ ព្រឹកដល់ ០៥ រសៀល។

- ក្នុងអំឡុងពេលផ្តល់ថ្នាំបង្ការ ក្រុមត្រូវក្រើនរំលឹកដល់អ្នកទទួលឱ្យរក្សាប័ណ្ណថ្នាំបង្ការ និងត្រឡប់មកទទួលថ្នាំបង្ការលើកទី ២ ដោយយកប័ណ្ណថ្នាំបង្ការមកជាមួយ។

### ៧.២.៣. ជម្រើសជាយុទ្ធសាស្ត្រដែលអាចមាន

ដោយពិចារណាដល់ភាពមិនជាក់លាក់នៃចំនួនប្រភេទថ្នាំបង្ការជំងឺកូវីដ-១៩ ដែលកម្ពុជានឹងបានទទួល ចំនួនជើងនៃការដឹកជញ្ជូនថ្នាំបង្ការ បរិមាណថ្នាំបង្ការដែលនឹងទទួលបានក្នុងការដឹកជញ្ជូនមួយជើងៗ ក៏ដូចជាពេលវេលាដែលថ្នាំបង្ការនឹងមកដល់ កម្ពុជានឹងធ្វើបច្ចុប្បន្នភាពព្រមទាំងសម្របតម្រូវយុទ្ធសាស្ត្រផ្តល់ថ្នាំបង្ការទៅតាមចំនួនដូសជាក់ស្តែង ចំនួននៃប្រភេទថ្នាំបង្ការដែលបានទទួល និងតាមចំនួនជើងនៃការដឹកជញ្ជូន និងតាមក្រុមអាទិភាពចំណុច។

អាស្រ័យដោយភាពមានកម្រិតនៃការផ្គត់ផ្គង់សកល កម្ពុជាទំនងជានឹងទទួលបានថ្នាំបង្ការជំងឺកូវីដ-១៩ ច្រើនជាងមួយប្រភេទ ដើម្បីពង្រីកការគ្របដណ្តប់នៃថ្នាំបង្ការដល់ប្រជាជនអាទិភាពចំណុចកាន់តែច្រើន។ បើកម្ពុជាទទួលបានថ្នាំបង្ការជំងឺកូវីដ-១៩ ច្រើនជាងមួយប្រភេទ នោះយុទ្ធសាស្ត្រផ្តល់ថ្នាំបង្ការនឹងត្រូវបានសម្របតម្រូវទៅតាមជម្រើសដែលអាចមានដូចខាងក្រោម៖

<u>ជម្រើសទី ១៖ ទៅតាមតំបន់ភូមិសាស្ត្រ</u>

- ដើម្បីសម្រួលការផ្គត់ផ្គង់ភ័ស្តុភារដល់មន្ត្រីសុខាភិបាលជួរមុខជាអ្នកផ្តល់ថ្នាំបង្ការ យុទ្ធនាការផ្តល់ថ្នាំបង្ការគួរត្រូវបានធ្វើជាដំណាក់កាល ដោយពង្រីកតំបន់ភូមិសាស្ត្រដើម្បីគ្របដណ្តប់រាល់ក្រុមអាទិភាពចំណុច។ ក្រសួងសុខាភិបាលនឹងបែងចែកថ្នាំបង្ការជំងឺកូវីដ-១៩ ទៅតំបន់ភូមិសាស្ត្រផ្សេងៗ (ឧទាហរណ៍ ខេត្តមួយគួរទទួលបានថ្នាំបង្ការជំងឺកូវីដ-១៩ តែមួយប្រភេទប៉ុណ្ណោះ) ដើម្បីចៀសវាងការលាយឡំថ្នាំបង្ការច្រើនប្រភេទជាមួយគ្នានៅក្នុងប្រព័ន្ធផ្គត់ផ្គង់ និងនៅកន្លែងផ្តល់ថ្នាំបង្ការ។

- តំបន់ដែលមានប្រជាពលរដ្ឋកុះករដូចជានៅរាជធានីភ្នំពេញ ប្រហែលជាត្រូវការថ្នាំបង្ការជំងឺកូវីដ-១៩ ច្រើនជាងមួយប្រភេទដើម្បីគ្របដណ្តប់ក្រុមប្រជាជនអាទិភាព តែឃុំ-សង្កាត់ឬទីតាំងផ្តល់ថ្នាំបង្ការដែលបានកំណត់មួយគួរទទួលបានថ្នាំបង្ការជំងឺកូវីដ-១៩ តែមួយប្រភេទប៉ុណ្ណោះ។
- ការបែងចែកដែលធានាថាទីតាំងផ្តល់ថ្នាំបង្ការមួយនឹងប្រើថ្នាំបង្ការតែមួយប្រភេទប៉ុណ្ណោះ នឹងសម្រួលដល់តាមដានហេតុការណ៍កើតមានក្រោយការផ្តល់ថ្នាំបង្ការ ដល់ចរន្តនៃការដឹកជញ្ជូន និងដល់ការរក្សាទុក ក៏ដូចជាការប្រាស្រ័យទាក់ទងអំពីថ្នាំបង្ការដល់ប្រជាពលរដ្ឋ។

ជម្រើសទី ២៖ ទៅតាមក្រុមប្រជាជនអាទិភាព

- ការបែងចែកថ្នាំបង្ការជំងឺកូវីដ-១៩ គួរធ្វើទៅតាមក្រុមប្រជាជនអាទិភាពទូទាំងប្រទេស។ ការធ្វើបែបនេះទំនងជាសមស្របបើកម្ពុជានឹងទទួលបានថ្នាំបង្ការជំងឺកូវីដ-១៩ មួយប្រភេទក្នុងចំនួនច្រើនលើសលុប ហើយថ្នាំបង្ការជំងឺកូវីដ-១៩ ប្រភេទផ្សេងទៀតក្នុងចំនួនតិចជាង។ ក្នុងករណីនេះ ប្រភេទថ្នាំបង្ការជំងឺកូវីដ-១៩ ដែលមានចំនួនច្រើនលើសលុបអាចត្រូវបានបែងចែកទៅក្រុមប្រជាជនអាទិភាពផ្សេងៗ ក្នុងប្រទេស ហើយប្រភេទថ្នាំបង្ការជំងឺកូវីដ-១៩ ដែលមានចំនួនតិចជាងនឹងត្រូវបានបែងចែកទៅក្រុមប្រជាជនជាក់លាក់ផ្សេងទៀត។
- ក្រសួងសុខាភិបាលនឹងស្វែងរកផ្នែកសេវាឯកជន អំពីលទ្ធភាពនៃការប្រើបច្ចេកវិទ្យា ដើម្បីតាមដានប្រភេទថ្នាំបង្ការជំងឺកូវីដ-១៩ នៅទូទាំងប្រទេស ក៏ដូចជាដើម្បីប្រយុទ្ធនឹងថ្នាំបង្ការក្លែងក្លាយ និងពង្រឹងការតាមដានថ្នាំបង្ការ ដែលការងារទាំងនេះមានសារៈសំខាន់ជាអាយុជីវិតសម្រាប់សុវត្ថិភាព ប្រសិទ្ធភាព និងជោគជ័យនៃយុទ្ធនាការផ្តល់ថ្នាំបង្ការជំងឺកូវីដ-១៩។

## ៧.៣. សមាសភាពក្រុមផ្តល់ថ្នាំបង្ការ

### ៧.៣.១. សមាសភាពក្រុមផ្តល់ថ្នាំបង្ការនៅមណ្ឌលសុខភាព-មន្ទីរពេទ្យ

- យុទ្ធសាស្ត្រផ្តល់ថ្នាំបង្ការនៅនឹងមណ្ឌលសុខភាព-មន្ទីរពេទ្យ៖ អ្នកផ្តល់ថ្នាំបង្ការមានជំនាញម្នាក់ និងអ្នកកត់ត្រា-ចុះបញ្ជីម្នាក់
- សម្រាប់បន្ទាយយោធានិងស្នាក់ការនគរបាល៖ អ្នកផ្តល់ថ្នាំបង្ការមានជំនាញម្នាក់ និងអ្នកកត់ត្រា-ចុះបញ្ជីម្នាក់។

### ៧.៣.២. សមាសភាពក្រុមផ្តល់ថ្នាំបង្ការតាមរយៈការចុះផ្តល់សេវាដល់មូលដ្ឋាន

- ក្រុមផ្តល់ថ្នាំបង្ការគួរមានយ៉ាងហោចណាស់ ៣ នាក់៖ អ្នកផ្តល់ថ្នាំបង្ការជំនាញម្នាក់ អ្នកកត់ត្រា-ចុះបញ្ជីម្នាក់ ក្រុមទ្រទ្រង់សុខភាពភូមិឬមេភូមិ។ក្រុមចុះផ្តល់សេវាដល់មូលដ្ឋានមួយអាចផ្តល់ថ្នាំបង្ការដល់ក្រុមចំណុច ១០០ - ១៥០ នាក់ក្នុងមួយថ្ងៃ។
- នឹងមានអ្នកអភិបាលម្នាក់ ដែលនឹងត្រូវបានចាត់ឱ្យផ្តល់ការគាំទ្រដល់ក្រុមផ្តល់ថ្នាំបង្ការតាមរយៈតាមការចុះផ្តល់សេវាដល់មូលដ្ឋានចំនួន ៥ ក្រុម។

## ៧.៤. តួនាទី និងការទទួលខុសត្រូវ

### ៧.៤.១. តួនាទី និងការទទួលខុសត្រូវរបស់ក្រុមផ្តល់ថ្នាំបង្ការមុនធ្វើយុទ្ធនាការ (សកម្មភាពត្រៀមរៀបចំ) សម្រាប់ដំណាក់កាលទី ១ និងដំណាក់កាលទី ២៖

សមាជិកក្រុមផ្តល់ថ្នាំបង្ការត្រូវអនុវត្តទៅតាមគោលការណ៍ណែនាំសម្រាប់ស្រុកប្រតិបត្តិ-មណ្ឌលសុខភាព។

- អ្នកផ្តល់ថ្នាំបង្ការគួរចុះឈ្មោះនិងព័ត៌មានក្រុមចំណុច ។
- អ្នកអភិបាល និងអ្នកផ្តល់ថ្នាំបង្ការនឹងត្រូវចូលរួមសិក្ខាសាលារៀបចំផែនការលម្អិត នៅមណ្ឌលសុខភាពរបស់ខ្លួន។ ពួកគេត្រូវបានរំពឹងថានឹងបញ្ជូនផែនការលម្អិតទៅប្រធានមណ្ឌលសុខភាពតាមកាលបរិច្ឆេទដែលបានកំណត់ ដើម្បីឱ្យប្រធានមណ្ឌលសុខភាពដាក់ជូនទៅស្រុកប្រតិបត្តិ។
- អ្នកអភិបាលនិងអ្នកផ្តល់ថ្នាំបង្ការ នឹងចូលរួមក្នុងវគ្គបណ្តុះបណ្តាលសម្រាប់យុទ្ធនាការជាតិផ្តល់ថ្នាំបង្ការជំងឺកូវីដ-១៩។
- អ្នកផ្តល់ថ្នាំបង្ការ រួមនឹងអ្នកអភិបាលនឹងរៀបចំការតម្រង់ទិសខ្លីមួយសម្រាប់ក្រុមអ្នកស្ម័ចិត្តនៅមណ្ឌលសុខភាព។
- សមាជិកក្រុមទាំងអស់ (អ្នកអភិបាល អ្នកផ្តល់ថ្នាំបង្ការ អ្នកកត់ត្រា និងអ្នកស្ម័គ្រចិត្ត) គួរធ្វើការកៀរគរ/ប្រាស្រ័យទាក់ទងសង្គម ក្នុងអំឡុងដំណាក់កាលត្រៀមរៀបចំសម្រាប់យុទ្ធនាការជាតិផ្តល់ថ្នាំបង្ការជំងឺកូវីដ-១៩។
- អ្នកស្ម័គ្រចិត្តគួរតាំងផ្ទាំងបដាសម្រាប់ការចុះផ្តល់សេវាថ្នាំបង្ការដល់មូលដ្ឋាន និងសម្ភារៈព័ត៌មាន អប់រំ និងប្រាស្រ័យទាក់ទង នៅក្នុងដំណាក់កាលត្រៀមរៀបចំសម្រាប់យុទ្ធនាការជាតិផ្តល់ថ្នាំបង្ការជំងឺកូវីដ-១៩។
- ត្រៀមរៀបចំវិធានការណ៍បង្ការក្នុងយុទ្ធនាការជាតិផ្តល់ថ្នាំបង្ការជំងឺកូវីដ-១៩ (ម៉ាស់ ការរក្សាគម្លាត អាល់កុល/ជែលសម្រាប់សម្អាតដៃ) ដើម្បីសុវត្ថិភាពអ្នកផ្តល់ថ្នាំបង្ការនិងអតិថិជន ។

**៧.៤.២. តួនាទីនិងការទទួលខុសត្រូវនៃក្រុមផ្តល់ថ្នាំបង្ការ - ការផ្តល់ថ្នាំបង្ការក្នុងដំណាក់កាលទី 1៖ ក្នុងអំឡុងយុទ្ធនាការជាតិផ្តល់ថ្នាំបង្ការជំងឺកូវីដ-១៩**

**អ្នកផ្តល់ថ្នាំបង្ការ និងអ្នកកត់ត្រា-ចុះបញ្ជី**

- ប្រមូលថ្នាំបង្ការដែលត្រូវការប្រចាំថ្ងៃ និងការផ្គត់ផ្គង់ភ័ស្តុភារឱ្យបានទាន់ពេលវេលាសម្រាប់ផ្តល់ផ្តល់ថ្នាំបង្ការនៅនឹងមណ្ឌលសុខភាព-មន្ទីរពេទ្យ។
- ធានាដល់ការរៀបចំកន្លែងផ្តល់ថ្នាំបង្ការឱ្យបានត្រឹមត្រូវនៅក្នុងមូលដ្ឋានសុខាភិបាល (មណ្ឌលសុខភាព-មន្ទីរពេទ្យ) ទៅតាមគោលការណ៍ណែនាំ។
- ធានាថា រាល់វិធានការណ៍ការពារជាមុន (ម៉ាស់ ការរក្សាគម្លាត អាល់កុល/ជែលសម្រាប់សម្អាតដៃ) នឹងត្រូវបានអនុវត្តក្នុងអំឡុងពេលយុទ្ធនាការជាតិផ្តល់ថ្នាំបង្ការជំងឺកូវីដ-១៩។
- ធានាឱ្យបាននូវសុវត្ថិភាពក្នុងការផ្តល់ថ្នាំបង្ការ។
- ពិនិត្យឈ្មោះនៅក្នុងបញ្ជីឈ្មោះ។
- ធ្វើការពិនិត្យជាមុន (ផ្ទៀងផ្ទាត់សីតុណ្ហភាព ពិនិត្យរកសញ្ញាដូចជាក្អក ឬពិបាកដកដង្ហើម)។
- ផ្តល់ថ្នាំបង្ការដល់ប្រជាជនចំណុច។
- ធានាថាតារាងកត់ត្រាក្បាលមនុស្សត្រូវបានគូសសម្គាល់យ៉ាងត្រឹមត្រូវ បន្ទាប់ពីបានផ្តល់ថ្នាំបង្ការដល់បុគ្គលម្នាក់ៗ។
- ទាក់ទងជាមួយក្រុមចំណុច ដើម្បីស្រាវជ្រាវរកហេតុការកើតមានក្រោយការផ្តល់ថ្នាំបង្ការនិងព័ត៌មានទាក់ទងនឹងការបញ្ជូន។

- ផ្ដល់ប័ណ្ណចាក់ថ្នាំបង្ការជំងឺកូវីដ-១៩ រំលឹកគាត់ឱ្យរក្សាទុកប័ណ្ណកុំឱ្យខូចខាតបាត់បង់ និងត្រូវវិលត្រឡប់មកវិញជាមួយប័ណ្ណនេះសម្រាប់ការទទួលថ្នាំបង្ការលើកទី ២ តាមកាលបរិច្ឆេទកំណត់។
- ប្រមូលថ្នាំបង្ការនិងការផ្គត់ផ្គង់ ប្រសិនបើមានកង្វះខាតថ្នាំបង្ការនិងការផ្គត់ផ្គង់។
- ស្រាវជ្រាវរក និងរាយការណ៍ហេតុការកើតមានក្រោយការផ្តល់ថ្នាំបង្ការជាបន្ទាន់ គ្រប់គ្រងករណីប្រសិនបើស្រាល ឬបញ្ជូនទៅកាន់មន្ទីរពេទ្យ។
- ធានារក្សាភាពស្អាតបាតនៃកន្លែងផ្ដល់ថ្នាំបង្ការ។
- ធានាការបង្វិលសងវិញថ្នាំបង្ការ ភ័ស្តុភារ តារាងកត់ត្រាក្បាលមនុស្ស និងបញ្ជីចុះឈ្មោះនៅថ្ងៃចុងក្រោយនៃយុទ្ធនាការ។
- ផ្ញើតារាងកត់ត្រាក្បាលមនុស្ស និងរបាយការណ៍ប្រចាំថ្ងៃទៅប្រធានក្រុម។

**អ្នកអភិបាលក្រុមផ្តល់ថ្នាំបង្ការ**

- ធានាការប្រមូលថ្នាំបង្ការនិងភ័ស្តុភារឱ្យបានទាន់ពេលវេលាដើម្បីឱ្យការផ្តល់ថ្នាំបង្ការនៅមណ្ឌលសុខភាព-មន្ទីរពេទ្យអាចចាប់ផ្តើមបានទាន់ពេលវេលា។
- ធានាថារាល់វិធានការណ៍ការពារទាំងអស់ត្រូវបានអនុវត្តនៅក្នុងមណ្ឌលសុខភាព-មន្ទីរពេទ្យ។
- ធ្វើការអភិបាលគាំទ្រ។
- ធានាការបង្វិលសងវិញថ្នាំបង្ការ ភ័ស្តុភារ តារាងកត់ត្រាក្បាលមនុស្ស បញ្ជីចុះឈ្មោះ កំណត់ត្រា និងរបាយការណ៍ប្រចាំថ្ងៃ។
- ពិនិត្យ កែសម្រួលឡើងវិញ(បើចាំបាច់)និងចងក្រងឯកសារទាំងអស់របស់ក្រុមនៅចុងបញ្ចប់នៃថ្ងៃ និមួយៗ និងរាយការជូនប្រធានមណ្ឌលសុខភាពត្រឹមម៉ោង ៥ រសៀល (ឧបសម្ព័ន្ធទី១០)។

### ៧.៤.៣. តួនាទីនិងការទទួលខុសត្រូវនៃក្រុមផ្តល់ថ្នាំបង្ការ - នៅដំណាក់កាលទី ២ (ក្នុងអំឡុងយុទ្ធនាការ)

**អ្នកផ្តល់ថ្នាំបង្ការ និងអ្នកកត់ត្រា-ចុះបញ្ជី**

- ប្រមូលថ្នាំបង្ការនិងការផ្គត់ផ្គង់ភ័ស្តុភារប្រចាំថ្ងៃឱ្យបានទាន់ពេល សម្រាប់យុទ្ធនាការផ្តល់ថ្នាំបង្ការទៅតាមផែនការលម្អិត។
- ធានាដល់ការរៀបចំបានត្រឹមត្រូវ ទាំងកន្លែងផ្តល់ថ្នាំបង្ការនៅនឹងមណ្ឌលសុខភាពនិងមន្ទីរពេទ្យ និងតាមការចុះផ្ដល់សេវាដល់មូលដ្ឋាន។
- ធានាថារាល់វិធានការណ៍ការពារ (ម៉ាស់មុខ ការរក្សាគម្លាតពីគ្នា អាល់កុល-ជែលសម្រាប់សម្អាតដៃ...) ត្រូវបានអនុវត្ត។
- ធានាឱ្យបាននូវការអនុវត្តប្រកបដោយសុវត្ថិភាពនៃការផ្តល់ថ្នាំបង្ការ។
- ផ្តល់ការទទួលខុសត្រូវដល់អ្នកស្ម័គ្រចិត្តក្នុងអំឡុងទិវា (ក្នុងការចុះផ្ដល់សេវាដល់មូលដ្ឋាន)។
- ផ្ទៀងផ្ទាត់ឈ្មោះនិងព័ត៌មានលំអិតផ្សេងទៀតនៃប្រជាជនចំណុច នៅក្នុងបញ្ជីឈ្មោះ។
- ផ្ដល់ថ្នាំបង្ការដល់ក្រុមចំណុចបន្ទាប់ពីបានពិនិត្យជាមុន។
- ធានាថា តារាងកត់ត្រាក្បាលមនុស្សត្រូវបានគូសសម្គាល់ត្រឹមត្រូវ បន្ទាប់ពីផ្តល់ថ្នាំបង្ការដល់ប្រជាពលរដ្ឋចំណុចម្នាក់ម្តងៗ។
- ប្រាស្រ័យទាក់ទងជាមួយក្រុមចំណុច ស្រាវជ្រាវរក និងរាយការណ៍ហេតុការដែលកើតមានក្រោយទទួលថ្នាំបង្ការ និងព័ត៌មាននៃបញ្ជូនទៅកាន់មន្ទីរពេទ្យ។

- ផ្តល់ប័ណ្ណទទួលថ្នាំបង្ការជំងឺកូវីដ-១៩ រំលឹកគាត់ឱ្យរក្សាទុកប័ណ្ណកុំឱ្យខូចខាតបាត់បង់ និងត្រូវត្រឡប់មកវិញជាមួយប័ណ្ណនេះសម្រាប់ការទទួលថ្នាំបង្ការលើកទី ២ តាមកាលបរិច្ឆេទកំណត់។
- ទាក់ទងជាមួយអ្នកអភិបាលក្រុមអំពីកង្វះខាតថ្នាំបង្ការសម្រាប់ការបំពេញបន្ថែម។
- ប្រមូលបញ្ជីនៃប្រជាជនចំណុចដែលមិនបានទទួលថ្នាំបង្ការ និងប្រគល់ទៅអ្នកអភិបាលដើម្បីប្រាកដថាពួកគេអាចទៅទទួលថ្នាំបង្ការនៅមណ្ឌលសុខភាព-មន្ទីរពេទ្យ នៅក្នុងថ្ងៃផ្តល់ថ្នាំបង្ការ។
- ធានាថា កន្លែងផ្តល់ថ្នាំបង្ការស្អាតល្អ ថ្លែងអំណរគុណដល់ម្ចាស់គេហដ្ឋានមុនចាកចេញពីប៉ុស្តិ៍។
- ធានាថា ថ្នាំបង្ការ ការផ្គត់ផ្គង់ភ័ស្តុភារ តារាងកត់ត្រាក្បាលម្នុល និងបញ្ជីចុះឈ្មោះ ត្រូវបានប្រគល់ត្រឡប់ទៅវិញនៅថ្ងៃចុងក្រោយនៃយុទ្ធនាការ។
- ផ្ញើរបាយការណ៍សង្ខេបប្រចាំថ្ងៃទៅកម្រិតបន្ទាប់ (ឧទាហរណ៍ ប៉ុស្តិ៍ផ្តល់ថ្នាំបង្ការផ្ញើរបាយការណ៍ទៅមណ្ឌលសុខភាព មណ្ឌលសុខភាពផ្ញើរបាយការណ៍ទៅស្រុកប្រតិបត្តិ)។

**អ្នកស្ម័គ្រចិត្ត**

- ត្រូវបំពេញការងារតាមតួនាទីរបស់ខ្លួនដែលចាត់ដោយអ្នកផ្តល់ថ្នាំបង្ការ ឬអ្នកអភិបាលក្រុម។
- គ្រប់គ្រងហ្វូងមនុស្សកុំឱ្យកកកុញ ធានាថាបានពាក់ម៉ាស់មុខ រក្សាគម្លាតសុវត្ថិភាពយ៉ាងតិចមួយម៉ែត្រកន្លះពីម្នាក់ទៅម្នាក់ និងប្រើអាល់កុល-ជែលលាងសម្អាតដៃមុនទៅជួបអ្នកផ្តល់ថ្នាំបង្ការ។
- ត្រូវប្រមូលក្រុមចំណុចពីភូមិទៅកន្លែងផ្តល់ថ្នាំបង្ការតាមរយៈការចុះផ្តល់សេវាដល់មូលដ្ឋាន ឬការផ្តល់សេវានៅនឹងកន្លែង (មណ្ឌលសុខភាពនិងមន្ទីរពេទ្យ)។

**អ្នកអភិបាលក្រុម**

- ធានាថាការប្រមូលថ្នាំបង្ការនិងការផ្គត់ផ្គង់ភ័ស្តុភារបានទាន់ពេល ដើម្បីឱ្យយុទ្ធនាការផ្តល់ថ្នាំបង្ការអាចចាប់ផ្តើមបានទាន់ពេលវេលា។
- ធានាថារាល់វិធានការណ៍ការពារ (ម៉ាស់មុខ ការរក្សាគម្លាតពីគ្នា អាល់កុល-ជែលសម្រាប់សម្អាតដៃ...) ត្រូវបានអនុវត្តនៅកន្លែងផ្តល់ថ្នាំបង្ការ ទាំងនៅតាមការចុះផ្តល់សេវាដល់មូលដ្ឋាន និងការផ្តល់ថ្នាំបង្ការនៅនឹងកន្លែង។
- ធានាសុវត្ថិភាពដល់ក្រុមផ្តល់ថ្នាំបង្ការ ដល់ថ្នាំបង្ការ និងការផ្គត់ផ្គង់ភស្តុភារ។ ល។
- ធានាដល់ការអភិបាលគាំទ្រដល់គ្រប់ក្រុមផ្តល់ថ្នាំបង្ការទាំងអស់ ដោយប្រើបញ្ជីផ្ទៀងផ្ទាត់សម្រាប់ការអភិបាល (ឧបសម្ព័ន្ធ៨)។
- យកថ្នាំបង្ការទៅជាមួយ (១០ ដប) ដើម្បីបំពេញការប្រើប្រាស់របស់ក្រុម បើមានការខ្វះខាតថ្នាំបង្ការ។
- ធានាបង្វិលសងវិញថ្នាំបង្ការនិងការផ្គត់ផ្គង់ភ័ស្តុភារដែលនៅសល់ ពីក្រុមទាំងអស់។
- ពិនិត្យឡើងវិញ និងកែសម្រួល (បើចាំបាច់) និងផ្ដុំកំណត់ត្រាពីគ្រប់ក្រុមនៅចុងបញ្ចប់ថ្ងៃនិមួយៗ ព្រមទាំងរាយការណ៍ទៅប្រធានមណ្ឌលសុខភាពយ៉ាងយូរត្រឹមម៉ោង ៥រសៀល (ឧបសម្ព័ន្ធ ១០)។

# ជំពូកទី ៨- ការគ្រប់គ្រងសំភារៈ-បរិក្ខានៃកម្មវិធីជាតិផ្តល់ថ្នាំបង្ការ

ប្រទេសកម្ពុជាមានប្រព័ន្ធគ្រប់គ្រងសំភារបរិក្ខាសម្រាប់កម្មវិធីផ្តល់ថ្នាំបង្ការ ដែលដំណើរការយ៉ាងល្អ រួមទាំងបទពិសោធន៍ក្នុងការគ្រប់គ្រងយុទ្ធនាការផ្តល់ថ្នាំបង្ការ តាំងពីកំឡុងពេលលុបបំបាត់កញ្ជ្រឹលមក។ តាំងពីឆ្នាំ ២០១០ មក កម្ពុជាបន្តបញ្ចូលបន្ថែមថ្នាំបង្ការប្រភេទថ្មីៗជាច្រើន ហេតុនេះ សមត្ថភាពរក្សាទុកថ្នាំបង្ការមានការកើនឡើងជាលំដាប់។ ថ្មីៗនេះ សម្ភារប្រព័ន្ធត្រជាក់ថ្មីៗជាច្រើនត្រូវបានបញ្ជាទិញ និងកំពុងបន្តទិញជាបន្តបន្ទាប់នៅចុងឆ្នាំ ២០២០។

## ៨.១. គន្លឹះសំខាន់ៗក្នុងការរក្សាទុកថ្នាំបង្ការជំងឺកូវីដ-១៩

យោងតាមការវាយតម្លៃរបស់កម្មវិធីជាតិផ្តល់ថ្នាំបង្ការ ដែលមានការចូលរួមពីអង្គការដៃគូអភិវឌ្ឍន៍ បង្ហាញថា នៅតាមមូលដ្ឋានសុខាភិបាលគ្រប់លំដាប់ថ្នាក់ មានសមត្ថភាពគ្រប់គ្រាន់ក្នុងការរក្សារទុកថ្នាំបង្ការជំងឺកូវីដ-១៩។ ទោះយ៉ាងណាក្តី ថ្នាំបង្ការជំងឺកូវីដ-១៩ ត្រូវរក្សាទុកក្នុងកន្លែងត្រជាក់ដែលមានទំហំធំគ្រប់គ្រាន់។ ដូចនេះ មន្ទីរសុខាភិបាល ការិយាល័យស្រុកប្រតិបត្តិ និងមណ្ឌលសុខភាពគួរធ្វើការវាយតម្លៃសមត្ថភាពស្តុកដែលមានសម្រាប់រក្សាទុកថ្នាំបង្ការនេះ។ បើមានបញ្ហាពីសមត្ថភាពស្តុក ឬទូរទឹកកកខូចភ្លាមៗ មណ្ឌលសុខភាព និងការិយាល័យស្រុកប្រតិបត្តិ ត្រូវជូនព័ត៌មានដល់ថ្នាក់លើភ្លាម និងលៃលកករកកន្លែងផ្សេងដើម្បីរក្សាទុកឱ្យបានឆាប់រហ័ស។

ប្រអប់កកដែលត្រូវការសម្រាប់យុទ្ធនាការផ្តល់ថ្នាំបង្ការត្រូវបានគណនាចំនួន និងរៀបចំឱ្យបានគ្រប់គ្រាន់ជាមុន។ ពិនិត្យប្រអប់កក (ក្រែងមានលេច-ជ្រាបឬប្រេះបែកគំរប) ជ្រើសរើសតែប្រអប់កកដែលល្អមកប្រើ។ ស្រុកប្រតិបត្តិ/មណ្ឌលសុខភាពគួរបង្កកប្រអប់កកដែលទទួលស្គាល់ដោយអង្គការសុខភាពពិភពលោក ដែលមានស្រាប់មុនថ្ងៃចុះយុទ្ធនាការ។

ថ្នាំបង្ការជំងឺកូវីដ-១៩ គួររក្សាទុក ទាំងក្នុងឃ្លាំងនិងនៅពេលពេលដឹកជញ្ជូន នៅសីតុណ្ហភាពសមស្របទៅតាមប្រភេទនៃថ្នាំបង្ការជំងឺកូវីដ-១៩។ ជាទូទៅ សីតុណ្ហភាពគួរនៅចន្លោះ +២ ទៅ +៨ អង្សាសេ។ ថ្នាំបង្ការជំងឺកូវីដ-១៩ ជាថ្នាំបង្ការរាវ និងមិនអាចកកបានទេ ព្រោះបើកក ថ្នាំបង្ការនឹងបាត់បង់ប្រសិទ្ធិភាពនិងមិនអាចផ្តល់ភាពស៊ាំទល់នឹងជំងឺបានទេ។ ថ្នាំបង្ការដែលកកអាចបណ្តាលឱ្យមានការបង្កធាតុ។ បើសង្ស័យ ត្រូវធ្វើតេស្តក្រឡុកដើម្បីពិនិត្យថា តើមានថ្នាំបង្ការណាដែលកក។

## ៨.២. ការបែងចែក-ការផ្គត់ផ្គង់ថ្នាំបង្ការជំងឺកូវីដ-១៩

កម្មវិធីជាតិផ្តល់ថ្នាំបង្ការនឹងអភិវឌ្ឍផែនការបែងចែក-ការផ្គត់ផ្គង់ថ្នាំបង្ការជំងឺកូវីដ-១៩ រួមទាំងការគូសផែនទីចំណុចឃ្លាំងរក្សាទុកថ្នាំបង្ការ និងសមត្ថភាពដឹកជញ្ជូនថ្នាំបង្ការនិងសម្ភារៈ-បរិក្ខាផ្តល់ថ្នាំបង្ការផ្សេងទៀត និងធានាថា សមត្ថភាពធនធានមនុស្សដែលត្រូវការមាននៅនឹងកន្លែង។

ការបែងចែកថ្នាំបង្ការជំងឺកូវីដ-១៩ ពីឃ្លាំងឱសថកណ្តាលអាស្រ័យនឹងប្រភេទនៃថ្នាំបង្ការដែលកម្ពុជានឹងទទួលបាន។ បរិមាណនៃថ្នាំបង្ការដែលត្រូវបានបែងចែកទៅមូលដ្ឋានសុខាភិបាលនិមួយៗ អាស្រ័យទៅនឹងទិន្នន័យដែលបានទទួលពីការធ្វើសម្រង់មុនយុទ្ធនាការផ្តល់ថ្នាំបង្ការ និងកាលវិភាគនៃការផ្តល់ថ្នាំបង្ការដែលត្រូវបានអភិវឌ្ឍក្នុងអំឡុងការធ្វើផែនការលម្អិត។

បើកម្ពុជាទទួលបានថ្នាំបង្ការជំងឺកូវីដ-១៩ ច្រើនជាមួយប្រភេទ នោះកម្មវិធីជាតិផ្តល់ថ្នាំបង្ការនឹងផ្តល់ព័ត៌មានដែលចាំបាច់ស្តីអំពីថ្នាំបង្ការ និងយុទ្ធសាស្រ្តជាជម្រើសដែលនឹងត្រូវអនុវត្ត។

## ៨.៣. សម្ភារប្រព័ន្ធត្រជាក់

សម្ភារប្រព័ន្ធត្រជាក់ដែលត្រូវការសម្រាប់រក្សាទុកនិងដឹកជញ្ជូនថ្នាំបង្ការជំងឺកូវីដ-១៩ រួមមាន៖

- បន្ទប់ត្រជាក់នៅឃ្លាំងឱសថកណ្តាល (ធ្វើការផ្លាស់ប្តូរ ក្នុងករណីមានតម្រូវការត្រជាក់ខ្លាំង UCC)
- ទូទឹកកកនៅឃ្លាំងមន្ទីរសុខាភិបាល ការិយាល័យស្រុកប្រតិបត្តិ និងមណ្ឌលសុខភាព-មន្ទីរពេទ្យ
- ក្លាសៀនៅមន្ទីរសុខាភិបាល ការិយាល័យស្រុកប្រតិបត្តិ មណ្ឌលសុខភាព និងមន្ទីរពេទ្យ
- ធុងដាក់ថ្នាំបង្ការដើម្បីផ្តល់សេវានៅមណ្ឌលសុខភាព
- ប្រអប់កក និងឧបករណ៍តាមដានសីតុណ្ហភាពនៅគ្រប់កម្រិត

គួររួមបញ្ចូលសម្ភារប្រព័ន្ធត្រជាក់ដែលត្រូវការសម្រាប់ការផ្តល់ថ្នាំបង្ការជំងឺកូវីដ-១៩ នៅដំណាក់កាលទី ១ និងទី ២ ទៅក្នុងផែនការលំអិតតាមលំដាប់ថ្នាក់ (របស់មណ្ឌលសុខភាព ការិយាល័យស្រុកប្រតិបត្តិ និងមន្ទីរសុខាភិបាល)

## ៨.៤. ការបំពេញរបាយការណ៍ស្តុក ឬ សលាកប័ត្រឃ្លាំង

បុគ្គលិកទទួលខុសត្រូវឃ្លាំងថ្នាំបង្ការនៅថ្នាក់ខេត្ត និងស្រុកប្រតិបត្តិ ត្រូវបំពេញសាលាប័ត្រឃ្លាំងគ្រប់ពេលដែលបានទទួលសម្ភារ/ថ្នាំបង្ការ ពេលបញ្ចេញ និងពេលរាប់ស្តុក។ បុគ្គលិកទទួលខុសត្រូវឃ្លាំងត្រូវគូសបន្ថែមជួរឈរ នៅក្នុងសាលាប័ត្រឃ្លាំង និងត្រូវបំពេញរាល់ព័ត៌មាន។

## ៨.៥. ការកត់ត្រាសីតុណ្ហភាព

សីតុណ្ហភាពនៅក្នុងទូររក្សាថ្នាំបង្ការគួរត្រូវបានកត់ត្រាយ៉ាងតិច ២ ដងក្នុងមួយថ្ងៃ (ព្រឹក និងល្ងាច) ៧ ថ្ងៃក្នុងមួយសប្តាហ៍ ដោយមិនលើកលែងថ្ងៃឈប់សម្រាកទេ។

តារាងទី៣៖ ការរក្សាទុកថ្នាំបង្ការនៅឃ្លាំងខេត្ត ស្រុកប្រតិបត្តិ និងមណ្ឌលសុខភាព (សម្រាប់ថ្នាំបង្ការគ្រប់មុខ)

| ឈ្មោះថ្នាំបង្ការ | សីតុណ្ហភាព | ខូចដោយកក | ខូចដោយកម្តៅ | ប៉ះនឹងកម្តៅ ឬ រស្មីព្រះអាទិត្យ | គោល នយោបាយដប ថ្នាំបង្ការមាន ច្រើនដូស |
|---|---|---|---|---|---|
| កូវីដ-១៩ | +2°C ទៅ +8°C | | | | |

## ៨.៦. កំឡុងពេលយុទ្ធនាការផ្តល់ថ្នាំបង្ការ

### តម្រូវការប្រអប់កក

- ដាក់ប្រអប់កកក្នុងទូបង្កកមួយយប់មុន រួចយកដាក់ក្នុងធុងថ្នាំបង្ការសម្រាប់យកទៅផ្តល់សេវានៅព្រឹកថ្ងៃផ្តល់ថ្នាំបង្ការ។ នៅពេលត្រឡប់មកពីផ្តល់ថ្នាំបង្ការពេលរសៀល ត្រូវប្រមូលប្រអប់កកយកទៅដាក់ក្នុងទូបង្កកវិញ។ នៅកន្លែងដែលខ្វះខាតប្រអប់កក គួរមានការរៀបចំដើម្បីធានាថាមានប្រអប់កកគ្រប់គ្រាន់សម្រាប់ផ្តល់សេវាថ្ងៃបន្ទាប់។

### នៅទីតាំងផ្តល់សេវាតាមរយៈការចុះផ្តល់ដល់មូលដ្ឋាន

- រក្សាធុងដាក់ថ្នាំបង្ការនៅទីកន្លែងម្លប់ បិទគម្របឱ្យជិតល្អជានិច្ច និងត្រូវមានអេប៉ុងនៅខាងក្នុង។
- ពេលព្រឹក កុំយកដបថ្នាំបង្ការចេញក្រៅ លុះត្រាមានប្រជាជនចំណុចមកដល់ដើម្បីទទួលថ្នាំបង្ការ។
- ក្នុងអំឡុងការចុះផ្តល់សេវាដល់មូលដ្ឋាន បើពុំមានប្រជាជនចំណុចដែលត្រូវផ្តល់ថ្នាំបង្ការទេ ត្រូវទុកដបថ្នាំបង្ការនៅក្នុងអេប៉ុង ក្នុងធុងដាក់ថ្នាំបង្ការជានិច្ច។
- ទោះជាមានប្រជាជនចំណុចតែម្នាក់មកទទួលថ្នាំបង្ការក្តី ក្រុមផ្តល់ថ្នាំបង្ការត្រូវបើកដបថ្នាំបង្ការ (បើចាំបាច់) ដើម្បីផ្តល់ថ្នាំបង្ការដល់គាត់។
- ពេលរសៀល ក្រុមផ្តល់ថ្នាំបង្ការគួរបោសសម្អាតទីតាំងផ្តល់ថ្នាំបង្ការ ប្រមូលទុកដាក់សំណល់ដែលមិនមុតស្រួច ថ្លែងអំណរគុណម្ចាស់ផ្ទះដែលផ្តល់ទីកន្លែង និងត្រលប់ទៅវិញ។

## ៨.៧. ស្លាកសញ្ញាសម្គាល់គុណភាពថ្នាំបង្ការ (VVM)

ស្លាកសញ្ញាសម្គាល់គុណភាពថ្នាំបង្ការ (VVM) បិទជាប់នៅជាមួយដបថ្នាំបង្ការការពារជំងឺកូវីដ១៩។ មុនពេលចែកចាយ និងកំឡុងពេលផ្តល់ថ្នាំបង្ការ នៅគ្រប់កម្រិតទាំងអស់ត្រូវត្រួតពិនិត្យស្លាកសញ្ញាសម្គាល់គុណភាពថ្នាំបង្ការ (VVM) នេះជាមុន។

រូបភាពទី៩៖ ស្លាកសញ្ញាសម្គាល់គុណភាពថ្នាំបង្ការ

សញ្ញាតាមដានគុណភាពវ៉ាក់សាំង



## ៨.៨. ការធ្វើតេស្តក្រឡុក

ថ្នាំបង្ការអាចបាត់បង់ប្រសិទ្ធិភាព និងមិនអាចប្រើបានទេ ប្រសិនបើមានថ្នាំបង្ការកករួមទាំងថ្នាំបង្ការការពារជំងឺកូវីដ១៩។ ដើម្បីកំនត់ថាថ្នាំបង្ការនោះកកឬ អត់ ត្រូវធ្វើតេស្តក្រឡុក។

**ជំហានទី ១**: យកដប ថ្នាំបង្ការមួយពីក្រុមហ៊ុនផលិតតែមួយ ដែលមានប្រភេទ និងលេខឡូត៍ដូចគ្នា ដែលអ្នកចង់ធ្វើតេស្តក្រឡុក។ ទុកដបនេះក្នុងទូបង្កករហូតដល់វាកករឹង។ ដាក់ស្លាកថា "កក" ឲ្យបានច្បាស់លាស់ ហើយកុំប្រើវា។

**ជំហានទី ២**: ជ្រើសរើសគំរូតេស្ត: ប្រមូលដប "សង្ស័យ" ណាដែលអ្នកចង់ធ្វើតេស្តក្រឡុក។

**ជំហានទី ៣**: ក្រឡុកដបទាំងពីរឲ្យញាប់ (១០ - ១៥ វិនាទី) ដបដែលអ្នកបង្កក និងដប "សង្ស័យ" ។

**ជំហានទី ៤**: ដាក់ដបថ្នាំបង្ការទាំងនោះនៅស្ងៀម នៅលើផ្ទៃដែលមានស្ថេរភាពហើយមើលការធ្លាក់ចុះនៃល្បាយថ្នាំបង្ការរហូតដល់ចប់ការពិនិត្យ។

អំណាន៖

- បើសិនជាកករនៅក្នុងដបថ្នាំបង្ការដែលសង្ស័យធ្លាប់កក ធ្លាក់ចុះយឺតជាងកករក្នុងដបថ្នាំបង្ការដែលយើងដាក់ឲ្យកកនោះគឺ អាចប្រើបាន ។
- តែបើសិនកករនៅក្នុងដបថ្នាំបង្ការដែលសង្ស័យធ្លាប់កក ធ្លាក់ដូចគ្នា ឬលឿនជាង កករក្នុងដបថ្នាំបង្ការដែលយើងដាក់ឲ្យកកនោះគឺ មិនត្រូវប្រើទេត្រូវបោះចោល ។

រូបភាពទី៦៖ ការធ្វើតេស្តក្រឡុក




## ៨.៩. របាយការណ៍ថ្នាំបង្ការ និងសម្ភារៈ

បុគ្គលិកទទួលខុសត្រូវឃ្លាំងថ្នាំបង្ការនៅ ស្រុកប្រតិបត្តិ និងមណ្ឌលសុខភាព ត្រូវធ្វើរបាយការណ៍សម្ភារ (ទាំងថ្នាំបង្ការ និងសម្ភារ)ឱ្យបានត្រឹមត្រូវ និងទៀងទាត់។ មណ្ឌលសុខភាព និង មន្ទីរពេទ្យគួរតែប្រើប្រាស់ទម្រង់របាយការណ៍ដែលបង្កើតថ្មីសម្រាប់ថ្នាំបង្ការការពារជំងឺកូវីដ១៩ (ឧបសម្ព័ន្ធទី១១ )។ របាយការណ៍ត្រូវផ្ញើរពីមណ្ឌលសុខភាពទៅ ការិយាល័យស្រុកប្រតិបត្តិក្នុងកំឡុងពេល ៣ថ្ងៃបន្ទាប់ពីបញ្ចប់យុទ្ធនាការ (សូមមើល

ជំពូក ការកត់ត្រា និងតាមដាន)។ ការិយាល័យស្រុកប្រតិបត្តិ នឹងធ្វើការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់របាយការណ៍ រួចផ្ញើរទៅមន្ទីរសុខាភិបាល នៅ ៥ថ្ងៃ ក្រោយបញ្ចប់យុទ្ធនាការ។ មន្ទីរសុខាភិបាល នឹងធ្វើការត្រួតពិនិត្យ និងបូកសរុបបាយការណ៍ពីការិយាល័យស្រុកប្រតិបត្តិទាំងអស់ រួចផ្ញើរទៅកម្មវិធីជាតិផ្តល់ថ្នាំបង្ការ ក្នុងរយៈពេល៧ថ្ងៃ ក្រោយបញ្ចប់យុទ្ធនាការ។

# ជំពូកទី ៩ - ការផ្តល់ថ្នាំបង្ការប្រកបដោយសុវត្ថិភាព

គឺជាការផ្តល់ថ្នាំបង្ការដែលមានសុវត្ថិភាពដល់អ្នកទទួលសេវា រួមទាំង ការគ្រប់គ្រងកាកសំណល់មុតស្រួច ដែលមិនបណ្តាលឲ្យមានមានគ្រោះថ្នាក់ដល់សហគមន៍។ យោងតាមសេចក្តីថ្លែងការណ៍រួមរបស់អង្គការសុខភាពពិភពលោក អង្គការយូនីសេហ្វ និងអង្គការយូអិនអែហ្វភីអេ ក្នុងឆ្នាំ ១៩៩៩ ក្នុងការប្រើប្រាស់សឺរ៉ាំងប្រភេទ AD (auto-disable syringes) សម្រាប់កម្មវិធីជាតិផ្តល់ថ្នាំបង្ការ ប្រទេសកម្ពុជាបានបញ្ចូលការប្រើប្រាស់សឺរ៉ាំងប្រភេទ AD និងប្រអប់សុវត្ថិភាព សម្រាប់ការងារផ្តល់ថ្នាំបង្ការជាប្រចាំ និងសម្រាប់យុទ្ធនាការផ្តល់ថ្នាំបង្ការដោយជោគជ័យ។ ក្នុងន័យនេះក្រសួងសុខាភិបាលបានបង្កើតគោលនយោបាយសុវត្ថិភាព ក្នុងការផ្តល់ថ្នាំបង្ការនិងឱសថរួចហើយនិងកំពុង បានអនុវត្តតាម។

## ៩.១. សឺរ៉ាំងប្រភេទ AD ( auto-disable syringes )

សឺរ៉ាំងប្រភេទ AD បង្កើតឡើងដោយមានបច្ចេកវិទ្យាពិសេសនៅខាងក្នុងតួសឺរ៉ាំង ដែលអាចធានាបានសម្រាប់ការប្រើប្រាស់តែម្តងគត់ គឺមិនអាចប្រើប្រាស់ជាលើកទីពីរបានឡើយ ។

កម្មវិធីជាតិផ្តល់ថ្នាំបង្ការ ប្រទេសកម្ពុជាបានបញ្ចូលការប្រើប្រាស់សឺរ៉ាំងប្រភេទ AD ចាប់តាំងពីឆ្នាំ ២០០០ មកម្លេះ ហើយបុគ្គលិកសុខាភិបាលមានជំនាញ និងបទពិសោធន៍ក្នុងការប្រើប្រាស់សឺរ៉ាំងប្រភេទ AD នោះ ។ ក្នុងការផ្តល់ថ្នាំបង្ការជំងឺកូវីដ-១៩ ខាងមុខ រ៉ាំងប្រភេទ AD ចំណុះ ០.៥ ម.ល នឹងត្រូវប្រើប្រាស់ ។ អត្រាខាតបង់សឺរ៉ាំង មានប្រហែល ១០ ភាគរយ សម្រាប់ការធ្វើផែនការលំអិត ។

រូបភាព ទី៧៖ សឺរ៉ាំងប្រភេទ AD (auto-disable syringes)






## ៩.២. ប្រអប់សុវត្ថិភាព

ប្រអប់សុវត្ថិភាពត្រូវបានធ្វើពីក្រដាសកាតុងដ៏រឹងមាំហើយត្រូវបានប្រើដើម្បីសម្រាប់ការដាក់រ៉ាំងប្រភេទ AD ដែលបានប្រើរួចសម្រាប់កម្មវិធីផ្តល់ថ្នាំបង្ការ។ ប្រអប់សុវត្ថិភាពគឺស្រាលហើយអាចយកតាមខ្លួនបានយ៉ាងងាយហើយម្ជុលដែលមុតស្រួចមិនអាចបុកធ្លាយបានទេ។ កម្មវិធីផ្តល់ថ្នាំបង្ការ មានអនុសាសន៍ថាប្រអប់សុវត្ថិភាព ត្រូវបានប្រើគ្រប់ពេលនៅពេលអនុវត្តសកម្មភាពផ្តល់ថ្នាំបង្ការ។ កម្មវិធីផ្តល់ថ្នាំបង្ការ បានប្រើប្រាស់ប្រអប់សុវត្ថិភាពនៅក្នុងប្រទេសកម្ពុជាចាប់តាំងពីឆ្នាំ ២០០០ ហើយបុគ្គលិកផ្តល់ថ្នាំបង្ការ មានជំនាញ និងបទពិសោធន៍ក្នុងការប្រើប្រាស់ប្រអប់សុវត្ថិភាព។ ក្នុងការផ្តល់ថ្នាំបង្ការជំងឺកូវីដ-១៩ ខាងមុខ ប្រអប់សុវត្ថិភាពនឹងត្រូវប្រើប្រាស់។

ក្រុមទទួលថ្នាំបង្ការត្រូវតែមានប្រអប់សុវត្ថិភាពគ្រប់គ្រាន់សម្រាប់ចំនួនសីរ៉ាំង AD (១ ប្រអប់សុវត្ថិភាពសម្រាប់រាល់សីរ៉ាំង AD ចំនួន១០០) ។ អត្រាខាតបង់ប្រអប់សុវត្ថិភាព មានប្រហែល ៥ ភាគរយ សម្រាប់ការធ្វើផែនការលំអិត ។

រូបភាព ទី៨៖ ប្រអប់សុវត្ថិភាព







នៅក្រោយការបញ្ចប់ទិវាផ្តល់ថ្នាំបង្ការ ប្រអប់សុវត្ថិភាពចាំបាច់ត្រូវរក្សាទុកក្នុងកន្លែងដែលបានកំណត់នៅមណ្ឌលសុខភាព និងមន្ទីរពេទ្យ។ កន្លែងដែលបានកំណត់គួរមានសុវត្ថិភាពនិងការពារពីភាពសើម។ នៅពេលដែលទិវាផ្តល់ថ្នាំបង្ការ ឬយុទ្ធនាការផ្តល់ថ្នាំបង្ការបានបញ្ចប់ប្រអប់សុវត្ថិភាពទាំងអស់ដែលមាននៅកន្លែងរក្សាទុក ត្រូវយកទៅឡដុតកំទេចោលនៅកន្លែងឡបានកំណត់បានត្រឹមត្រូវ។

### ចំនុចសំខាន់ៗសម្រាប់ធានាបាននូវសុវត្ថិភាពក្នុងការផ្តល់ថ្នាំបង្ការ៖

- ធានាថាមានសីរ៉ាំង AD គ្រប់គ្រាន់និងប្រអប់សុវត្ថិភាពរួមជាមួយថ្នាំបង្ការ។
- មិនត្រូវប៉ះគម្របជ័រនៃដបថ្នាំបង្ការទេ ក្រៅពីចុងម្ជុលដែលបើកថ្មីនិងមិនត្រូវប៉ះជាមួយវត្ថុអ្វីផ្សេងទៀត (បើប៉ះជាមួយវត្ថុផ្សេងទៀត ត្រូវចោលដបថ្នាំបង្ការនោះ) ។
- គួរបូមថ្នាំបង្ការដោយប្រើសីរ៉ាំង AD ពេលដែលអ្នកទទួលនៅទីនោះ ហាមបូមទុកក្នុងសីរ៉ាំង AD ជាមុន។

- ទម្លាក់សឺរ៉ាំង AD និងគម្របម្ជុលក្នុងអប់សុវត្ថិភាពភ្លាម បន្ទាប់ពីផ្តល់ថ្នាំបង្ការរួច ហាមការគ្របម្ជុល ជាមួយគម្របម្ជុល។
- ពេលប្រអប់សុវត្ថិភាពជិតពេញ (ប្រហែលបីភាគបួន) ត្រូវបិទប្រអប់សុវត្ថិភាព ហើយយកប្រអប់សុវត្ថិភាពថ្មីមកប្រើ។
- ធានាឱ្យបាននូវការផ្តល់ថ្នាំបង្ការធ្វើតាមបច្ចេកទេសក្នុងកាតចាក់ ត្រឹមត្រូវ។
- ត្រូវអនុវត្តកាមការការពារនិងការត្រួតពិនិត្យការឆ្លង ដោយប្រើឧបករណ៍ការពារផ្ទាល់ខ្លួន

# ជំពូកទី ១០ - ការកត់ត្រា និងការធ្វើរបាយការណ៍

ការគ្រប់គ្រងទិន្នន័យបានត្រឹមត្រូវនៅក្នុងការផ្តល់ថ្នាំបង្ការជំងឺកូវីដ-១៩ គឺចាំបាច់ត្រូវមានការតាមដានវឌ្ឍនភាពបានហ្មត់ចត់។ កម្មវិធីជាតិផ្តល់ថ្នាំបង្ការថ្នាក់កណ្តាលត្រូវបង្កើតប័ណ្ណផ្តល់ថ្នាំបង្ការ របាយការណ៍សម្រាប់គូសក្បាលម្ហូល បញ្ជីរសម្រាប់កត់ត្រាឈ្មោះអ្នកបានទទួលថ្នាំបង្ការនិងទម្រង់របាយការណ៍ ។

មណ្ឌលសុខភាពត្រូវធ្វើរបាយការណ៍ពីការផ្តល់ថ្នាំបង្ការជារៀងរាល់ថ្ងៃ ដោយមានការគាំទ្រពីថ្នាក់ស្រុកប្រតិបត្តិ និងថ្នាក់ខេត្ត ។ ឧបករណ៍សម្រាប់ការកត់ត្រានិងធ្វើតបាយការណ៍សំខាន់ៗដែលនឹងត្រូវប្រើសម្រាប់យុទ្ធនាការ ផ្តល់ថ្នាំបង្ការជំងឺកូវីដ-១៩ នៅថ្នាក់ផ្តល់សេវា រួមមាន៖

1. បញ្ជីរសម្រាប់កត់ត្រាឈ្មោះអ្នកបានទទួលថ្នាំបង្ការ
2. របាយការណ៍សម្រាប់គូសក្បាលម្ហូល
3. ប័ណ្ណផ្តល់ថ្នាំបង្ការ
4. ទម្រង់របាយការណ៍
5. បញ្ជីផ្ទៀងផ្ទាត់
6. សម្រាប់សលាកប័ត្រស្តុកថ្នាំបង្ការជំងឺកូវីដ-១៩ និងសម្ភារៈ គ្រប់ថ្នាក់នឹងប្រើទម្រង់ដែលមានស្រាប់ ។

## ១០.១. បញ្ជីរសម្រាប់កត់ត្រាឈ្មោះអ្នកបានទទួលថ្នាំបង្ការ

កម្មវិធីជាតិផ្តល់ថ្នាំបង្ការថ្នាក់កណ្តាលនឹងបង្កើត បែងចែក បញ្ជីរសម្រាប់កត់ត្រាឈ្មោះអ្នកបានទទួលថ្នាំបង្ការ (ឧបសម្ព័ន្ធទី១) សម្រាប់កត់ត្រាឈ្មោះអ្នកបានទទួលថ្នាំបង្ការជំងឺកូវីដ-១៩ ម្នាក់ៗនៅក្នុងយុទ្ធនាការ ។ ក្រុមអ្នកផ្តល់សេវាគួរបំពេញគ្រប់ព័ត៌មានឲ្យបានត្រឹមត្រូវហើយប្រគល់ជូនទៅអ្នកអភិបាល ឬមណ្ឌលសុខភាព និងមន្ទីរពេទ្យ ។

## ១០.២. របាយការណ៍សម្រាប់គូសក្បាលម្ហូល

របាយការណ៍សម្រាប់គូសក្បាលម្ហូល មានសារៈសំខាន់សម្រាប់ធ្វើរបាយការលទ្ធផល និង ជាឯកសារយោង។ កម្មវិធីជាតិផ្តល់ថ្នាំបង្ការថ្នាក់កណ្តាលនឹងបង្កើត បោះពុម្ព និងបែងចែករបាយការណ៍សម្រាប់គូសក្បាលម្ហូល (ឧបសម្ព័ន្ធទី ៩) សម្រាប់យុទ្ធនាការ កូវីដ-១៩ ។ ក្រុមអ្នកផ្តល់សេវាគួរបំពេញគ្រប់ព័ត៌មានក្នុងរបាយការណ៍សម្រាប់គូសក្បាលម្ហូល ឲ្យបានត្រឹមត្រូវហើយប្រគល់ជូនទៅអ្នកអភិបាល ឬមណ្ឌលសុខភាព និងមន្ទីរពេទ្យ ។

## ១០.៣. ប័ណ្ណផ្តល់ថ្នាំបង្ការ

បន្ទាប់ពីទទួលថ្នាំបង្ការជំងឺកូវីដ-១៩ប្រជាជនចំណុចម្នាក់ៗនឹងត្រូវបានផ្តល់ប័ណ្ណផ្តល់ថ្នាំបង្ការ(ឧបសម្ព័ន្ធទី២) ក្រុមអ្នកផ្តល់សេវាគួរបំពេញគ្រប់ព័ត៌មានក្នុងប័ណ្ណផ្តល់ថ្នាំបង្ការ។

ប័ណ្ណផ្តល់ថ្នាំបង្ការជំងឺកូវីដ-១៩ មានសារៈសំខាន់ណាស់សម្រាប់ទាំងបុគ្គលិកសុខាភិបាលនិងប្រជាពលរដ្ឋ ចំណុច ហើយក្រុមផ្តល់ថ្នាំបង្ការគួរតែក្រើនរំលឹកដល់គាត់ឲ្យរក្សាទុកប័ណ្ណនោះ ហើយយកត្រឡប់មកវិញសម្រាប់លើកទី ២ ។ ប័ណ្ណផ្តល់ថ្នាំបង្ការអាចមិនត្រឹមតែសម្រាប់គោលបំណងត្រួតពិនិត្យប៉ុណ្ណោះទេ ប៉ុន្តែក៏មានគោលបំណងផ្សេងទៀតនាពេលអនាគតផងដែរ។

### ប័ណ្ណចាក់ថ្នាំបង្ការជំងឺកូវីដ-១៩ ត្រូវមានព័ត៌មានដូចខាងក្រោម៖

| | |
|---|---|
| ឈ្មោះអ្នកទទួលថ្នាំបង្ការ៖ | ទាំងនាម និងនាមត្រកូល |
| លេខប័ណ្ណចាក់ថ្នាំបង្ការ៖ | លេខប័ណ្ណចាក់ថ្នាំបង្ការនិងលេខនៅក្នុងបញ្ជីសម្រង់ត្រូវដូចគ្នា |
| ដូសដែលបានទទួល៖ | គូសធីកប្រអប់សម្រាប់ដូសដែលបានទទួល (ដូសទី ១ □ ដូសទី ២ □) |
| ភេទអ្នកទទួលថ្នាំបង្ការ៖ | គូសធីកប្រអប់សម្រាប់ភេទអ្នកទទួលថ្នាំបង្ការ (ប្រុស □ ស្រី □) |
| ថ្ងៃ-ខែ-ឆ្នាំ កំណើត៖ | កាលបរិច្ឆេទកើត (ថ្ងៃ/ខែ/ឆ្នាំ កំណើត) |
| អាស័យដ្ឋាន៖ | លេខផ្ទះ លេខផ្លូវ ភូមិ ឃុំ-សង្កាត់ ខណ្ឌ-ក្រុង-ស្រុក រាជធានី-ខេត្ត |
| កាលបរិច្ឆេទផ្តល់ថ្នាំបង្ការ៖ | កាលបរិច្ឆេទ (ថ្ងៃ/ខែ/ឆ្នាំ ផ្តល់ថ្នាំបង្ការ) |

## ១០.៤. កំណត់ត្រា និង ទម្រង់របាយការណ៍

កម្មវិធីជាតិផ្តល់ថ្នាំបង្ការនឹងបង្កើត បោះពុម្ព និងបែងចែកទម្រង់របាយការណ៍ថ្នាំបង្ការជំងឺកូវីដ-១៩។ ក្រុមផ្តល់ថ្នាំបង្ការត្រូវផ្តល់របាយការណ៍ពីចំនួនដែលចាក់បាន ថ្នាំបង្ការនិងសម្ភារៈដែលបានប្រើ ហើយប្រគល់ជូនទៅអ្នកអភិបាល ឬមណ្ឌលសុខភាព។ សម្រាប់ដំនាក់កាលទីមួយ មណ្ឌលសុខភាពត្រូវបូកសរុបទម្រង់របាយការណ៍ប្រចាំថ្ងៃពីគ្រប់ក្រុមចាក់ទាំងអស់(ឧបសម្ព័ន្ធទី១១) ហើយធ្វើរបាយការណ៍ប្រចាំថ្ងៃជូនស្រុកប្រតិបត្តិ ។ ថ្នាក់ស្រុកប្រតិបត្តិនិងបូកសរុបរបាយការណ៍ប្រចាំថ្ងៃពីគ្រប់មណ្ឌលសុខភាព ដើម្បីរាយការណ៍ជូនមន្ទីរសុខភិបាលខេត្ត ដែលនឹងធ្វើរបាយការប្រចាំថ្ងៃជូនកម្មវិធីជាតិផ្តល់ថ្នាំបង្ការថ្នាក់កណ្តាល នៅពេលយប់ ឬព្រឹកបន្ទាប់។

*សម្រាប់យុទ្ធនាការផ្តល់ថ្នាំបង្ការនៅនឹងមណ្ឌលសុខភាព-មន្ទីរពេទ្យ និងនៅតាមការចុះផ្តល់សេវាដល់មូលដ្ឋានតាមភូមិ សម្រាប់វគ្គទី ២*

- ចំនួនថ្នាំបង្ការជំងឺកូវីដ-១៩ ដែលបានផ្តល់ត្រូវបានកត់ត្រានៅលើរបាយការណ៍សម្រាប់គូសក្បាលម្ពុល សម្រាប់ការចាក់នៅនឹងកន្លែង និងនៅតាមភូមិ ។
- នៅចុងថ្ងៃនិមួយៗ អ្នកអភិបាលក្រុមត្រូវពិនិត្យរបាយការណ៍សម្រាប់គូសក្បាលម្ពុល នៅចំពោះមុខក្រុមចាក់ដើម្បើរកមើលភាពមិនត្រឹមត្រូវ ។
- អ្នកអភិបាលក្រុមត្រូវបូកសរុបរបាយការណ៍សម្រាប់គូសក្បាលម្ពុលពីគ្រប់ក្រុមទាំងអស់ចូលទៅក្នុងរបាយការណ៍ប្រចាំថ្ងៃ(ឧបសម្ព័ន្ធទី១០)ហើយបញ្ជូនទៅប្រធានមណ្ឌលសុខភាព នៅប្រហែល ម៉ោង ៥ល្ងាចរាល់ថ្ងៃ ។ ប្រធានមណ្ឌលសុខភាព ត្រូវបូកសរុបរបាយការណ៍ប្រចាំថ្ងៃ ពីគ្រប់អ្នកអភិបាលក្រុមទាំងអស់ (ឧបសម្ព័ន្ធទី១១) ដើម្បីបញ្ជូនទៅប្រធានកម្មវិធីជាតិផ្តល់ថ្នាំបង្ការថ្នាក់ស្រុក ប្រតិបត្តិ នៅ ប្រហែលម៉ោង ៦ល្ងាចរាល់ថ្ងៃ ។

- ប្រធានកម្មវិធីជាតិផ្តល់ថ្នាំបង្ការថ្នាក់ស្រុកប្រតិបត្តិ នឹងប្រមូលរបាយការណ៍ប្រចាំថ្ងៃពីមណ្ឌលសុខភាព ទាំងអស់ ហើយចងក្រងហើយបញ្ជូនសារមន្ទីរសុខាភិបាលទៅម៉ោង ៨ កន្លះយប់
- មន្ទីរសុខាភិបាលខេត្តនឹងរៀបចំចងក្រងរបាយការណ៍ទាំងអស់ហើយផ្ញើទៅ កម្មវិធីជាតិផ្តល់ថ្នាំបង្ការថ្នាក់ កណ្ដាល នៅម៉ោង ៩ កន្លះយប់រៀងរាល់ថ្ងៃ។
- បុគ្គលិករបស់កម្មវិធីជាតិផ្តល់ថ្នាំបង្ការ នៅគ្រប់កម្រិតមានបទពិសោធន៍យ៉ាងល្អក្នុង ការគណនាអត្រាខាតបង់ថ្នាំបង្ការនិងសម្ភារៈ សម្រាប់ការងារផ្តល់ថ្នាំបង្ការជាប្រចាំ ដូច្នេះសម្រាប់យុទ្ធនាការ កម្មផ្តល់ថ្នាំបង្ការជំងឺកូវីដ-១៩ ការគណនាអត្រាខាតបង់ថ្នាំបង្ការនិងសម្ភារៈ នឹងត្រូវធ្វើឡើងតាមរបៀបស្រដៀងគ្នា។

### នៅខាងចុងយុទ្ធនាការវគ្គទី១

នៅចុងបញ្ចប់នៃយុទ្ធនាការ មណ្ឌលសុខភាពត្រូវចងក្រងរបាយការណ៍លទ្ធផលគ្របដណ្តប់និងការផ្គត់ផ្គង់ប្រើប្រាស់ថ្នាំបង្ការនិងសម្ភារដែលត្រូវបានប្រើក្នុងទម្រង់របាយការណ៍ (ឧបសម្ព័ន្ធទី១១) ហើយផ្ញើទៅថ្នាក់ស្រុកប្រតិបត្តិ (ក្នុងរយៈពេលបីថ្ងៃបន្ទាប់ពីការបញ្ចប់) ។ ថ្នាក់ស្រុកប្រតិបត្តិត្រូវចងក្រងរបាយការណ៍លទ្ធផលគ្របដណ្តប់ និងការផ្គត់ផ្គង់ប្រើប្រាស់ថ្នាំបង្ការនិងសម្ភារដែលត្រូវបានប្រើក្នុងទម្រង់របាយការណ៍(ឧបសម្ព័ន្ធទី១១) ហើយផ្ញើទៅថ្នាក់មន្ទីរសុខាភិបាលខេត្ត (ក្នុងរយៈពេលប្រាំថ្ងៃបន្ទាប់ពីបញ្ចប់) ហើយមន្ទីរសុខាភិបាលខេត្តត្រូវចងក្រងរបាយការណ៍លទ្ធផលគ្របដណ្តប់និងការផ្គត់ផ្គង់ប្រើប្រាស់ថ្នាំបង្ការនិងសម្ភារ (ក្នុងរយៈពេល ៧ ថ្ងៃនៃការបញ្ចប់) ដោយប្រើទម្រង់បែបបទនៃការរាយការណ៍ (ឧបសម្ព័ន្ធទី១១) ។

### នៅខាងចុងយុទ្ធនាការវគ្គទី២

នៅខាងចុងយុទ្ធនាការវគ្គទី២ មណ្ឌលសុខភាព ត្រូវចងក្រងរបាយការណ៍លទ្ធផលគ្របដណ្តប់និងការផ្គត់ផ្គង់ប្រើប្រាស់ថ្នាំបង្ការនិងសម្ភារដែលត្រូវបានប្រើក្នុងទម្រង់របាយការណ៍(ឧបសម្ព័ន្ធទី១១) ហើយផ្ញើទៅថ្នាក់ស្រុកប្រតិបត្តិ (ក្នុងរយៈពេលបីថ្ងៃបន្ទាប់ពីការបញ្ចប់) ។ ថ្នាក់ស្រុកប្រតិបត្តិ ត្រូវចងក្រងរបាយការណ៍លទ្ធផលគ្របដណ្តប់និងការផ្គត់ផ្គង់ប្រើប្រាស់ថ្នាំបង្ការនិងសម្ភារដែលត្រូវបានប្រើក្នុងទម្រង់របាយការណ៍(ឧបសម្ព័ន្ធទី១១ ) ហើយផ្ញើទៅថ្នាក់មន្ទីរសុខាភិបាលខេត្ត (ក្នុងរយៈពេលប្រាំថ្ងៃបន្ទាប់ពីបញ្ចប់) ហើយមន្ទីរសុខាភិបាលខេត្ត ត្រូវចងក្រងរបាយការណ៍ លទ្ធផលគ្របដណ្តប់និងការផ្គត់ផ្គង់ប្រើប្រាស់ថ្នាំបង្ការនិងសម្ភារ (ក្នុងរយៈពេល ៧ ថ្ងៃនៃការបញ្ចប់) ដោយប្រើទម្រង់បែបបទនៃការរាយការណ៍ (ឧបសម្ព័ន្ធទី១១ ) ។

# ជំពូកទី ១១- ការតស៊ូមតិ ការប្រាស្រ័យទាក់ទង និងការកៀរគរសង្គម

ការតស៊ូមតិប្រកបដោយប្រសិទ្ធភាព ការប្រាស្រ័យទាក់ទងសង្គម រួមទាំងការប្រាស្រ័យទាក់ទងអន្តរបុគ្គល និងការកៀងគរសង្គម មានសារៈសំខាន់ក្នុងការធានាថាប្រជាជនចំណុចមិនត្រូវបានខកខានក្នុងកំឡុងពេលយុទ្ធនាការផ្តល់ថ្នាំបង្ការជំងឺកូវីដ-១៩។ ទន្ទឹមគ្នានេះដែរការប្រាស្រ័យទាក់ទងនិងការបញ្ជូនសារ នៅតាមលំដាប់ថ្នាក់ គឺមានសារៈសំខាន់សម្រាប់ទទួលបានជោគជ័យក្នុងការផ្តល់ថ្នាំបង្ការជំងឺកូវីដ-១៩ ។ ចាប់ពីពេលវេលានៃការមកដល់របស់ថ្នាំបង្ការនៅឃ្លាំងឱសថកណ្តាល ហើយកម្មវិធីជាតិផ្តល់ថ្នាំបង្ការ ទទួលខុសត្រូវក្នុងការពិនិត្យនិងតាមដានការគ្រប់គ្រងស្តុក និងការបែងចែកថ្នាំបង្ការ។

ក្នុងអំឡុងពេលការផ្តល់ថ្នាំបង្ការជំងឺកូវីដ-១៩ កម្មវិធីជាតិផ្តល់ថ្នាំបង្ការ ទទួលខុសត្រូវនិងពិនិត្យឡើងវិញនូវលំហូររបាយការណ៍អត្រាគ្របដណ្តប់ការផ្តល់ថ្នាំបង្ការ ករណីហេតុការណ៍មិនល្អដែលកើតមានក្រោយផ្តល់ថ្នាំបង្ការនិងការគ្រប់គ្រងកាកសំណល់។ នៅប្រទេសកម្ពុជាទូរស័ព្ទចល័តគឺជាមធ្យោបាយទំនាក់ទំនងល្អបំផុត។ ទោះជាយ៉ាងណាក៏ដោយសម្រាប់ការប្រាស្រ័យទាក់ទងក្នុងការងារ ប្រព័ន្ធទំនាក់ទំនងសង្គមដូចជា Telegram, Facebook គឺជាជម្រើសល្អបំផុតហើយ ដែលពួកគេនឹងប្រើប្រព័ន្ធទំនាក់ទំនងសង្គមទំនាក់ទំនងទាំងនោះ។

ការផ្តល់ថ្នាំបង្ការដល់ក្រុមអាទិភាពចំនួន ៣ ដំបូងក្នុងដំណាក់កាលទី ១ នឹងត្រូវធ្វើឡើងនៅមណ្ឌលសុខភាព និង មន្ទីរពេទ្យ។ កម្មវិធីជាតិផ្តល់ថ្នាំបង្ការ បានបង្កើតយុទ្ធសាស្ត្រទំនាក់ទំនងជាក់លាក់សម្រាប់ ក្រុមអាទិភាពទាំងអស់។ លិខិតពីក្រសួងសុខាភិបាលនឹងផ្ញើជូនក្រសួងពាក់ព័ន្ធទាំងអស់ រួមទាំងកាលបរិច្ឆេទ ពេលវេលានិងទីកន្លែងផ្តល់ថ្នាំបង្ការ។ លើសពីនេះទៅទៀត ថ្នាក់ជាតិ ថ្នាក់ខេត្ត ស្រុកប្រតិបត្តិ និងមណ្ឌលសុខភាពនឹងរៀបចំការប្រជុំដើម្បីផ្តល់ព័ត៌មានដល់ក្រុមចំណុចឱ្យបានគ្រប់គ្រាន់និងលើកទឹកចិត្តពួកគាត់ទៅទទួលថ្នាំបង្ការនៅ មណ្ឌលសុខភាពនិងមន្ទីរពេទ្យ។ ទន្ទឹមនឹងនេះ សន្និសីទសារព័ត៌មាន មួយនឹងត្រូវបានរៀបចំឡើងនៅថ្នាក់កណ្តាល ដើម្បីផ្សព្វផ្សាយសារការផ្តល់ថ្នាំបង្ការជំងឺកូវីដ-១៩ តាមរយៈប្រព័ន្ធផ្សព្វផ្សាយ។

ទោះយ៉ាងណាក្តី យុទ្ធនាការផ្តល់ថ្នាំបង្ការនៅកន្លែង (មណ្ឌលសុខភាពនិងមន្ទីរពេទ្យ) និងនៅតាមភូមិ សម្រាប់ដំណាក់កាលទី ២ នឹងត្រូវកការផ្សព្វផ្សាយជាប្រចាំ ។

## ១១.១. មុនពេល និងអំឡុងពេលយុទ្ធនាការ កូវីដ-១៩

- យុទ្ធនាការផ្សព្វផ្សាយថ្នាក់ជាតិ៖ នឹងមានយុទ្ធនាការឃោសនាតាមទូរទស្សន៍ និងវិទ្យុមុនពេល និងក្នុងអំឡុងពេលយុទ្ធនាការផ្តល់ថ្នាំបង្ការ ដើម្បីជូនដំណឹងដល់ប្រជាជនចំណុចដើម្បីមកទទួលថ្នាំបង្ការ។
- សន្និសីទសារព័ត៌មានថ្នាក់ជាតិ៖ ដើម្បីផ្សព្វផ្សាយសារស្តីពីការផ្តល់ថ្នាំបង្ការជំងឺកូវីដ-១៩ តាមរយៈសន្និសីទសារព័ត៌មានជាមួយប្រព័ន្ធផ្សព្វផ្សាយនឹងត្រូវរៀបចំឡើងនៅពេលចាប់ផ្តើមយុទ្ធនាការ។

- ការប្រជុំតស៊ូមតិថ្នាក់ជាតិជាមួយស្ថាប័នជំនាញ៖ អ្នកជំនាញផ្នែកសុខភាពនិងការគាំទ្រពីអ្នកជំនាញផ្នែកនេះ គឺចាំបាច់សម្រាប់ជោគជ័យនៃការផ្តល់ថ្នាំបង្ការជំងឺកូវីដ-១៩ ។ ការប្រជុំតស៊ូមតិនេះនឹងជូនដំណឹងដល់អ្នកជំនាញអំពីព្រឹត្តិការណ៍នេះនិងជួយឱ្យពួកគេផ្សព្វផ្សាយសារដល់ប្រជាជនក្រុមចំណុច។
- ពិធីបើកយុទ្ធនាចាប់ផ្តើមថ្នាក់ជាតិ៖ ពិធីបើកការផ្តល់ថ្នាំបង្ការជំងឺកូវីដ-១៩ ផ្លូវការ នឹងត្រូវធ្វើឡើងនៅមុន ឬនៅថ្ងៃចាប់ផ្តើមការផ្តល់ថ្នាំបង្ការជំងឺកូវីដ-១៩ ។
- ការតស៊ូមតិនៅតាមខេត្តដោយអភិបាលខេត្ត ក្រុង៖ បន្ទាប់ពីទទួលលិខិតជាផ្លូវការពីក្រសួងសុខាភិបាល ប្រធានមន្ទីរសុខាភិបាលត្រូវទាក់ទងជាមួយអភិបាលខេត្ត ដើម្បីរៀបចំកិច្ចប្រជុំជាមួយគណៈកម្មការប្រយុទ្ធនឹងកូវីដ-១៩ ឬគណកម្មការការផ្តល់ថ្នាំបង្ការជំងឺកូវីដ-១៩ ។ អភិបាលខេត្តនឹងផ្ញើលិខិតជូនអភិបាលក្រុងស្រុកក្រុមប្រឹក្សាឃុំ និងអ្នកដទៃទៀតនិងស្វែងរកកិច្ចសហប្រតិបត្តិការនិងសហការគ្នា។ អភិបាលខេត្ត ក្រុង ត្រូវធ្វើលិខិតផ្ញើជូនដល់អភិបាលស្រុក ដើម្បីស្វែងរកការគាំទ្រ និងផ្តល់កិច្ចសហការ ។
- ការតស៊ូមតិនៅតាមខេត្តដោយអភិបាលស្រុក៖ អភិបាលស្រុកនឹងសរសេរលិខិតផ្ញើជូនក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីស្វែងរកការគាំទ្រ និងផ្តល់កិច្ចសហការ។
- ការតស៊ូមតិជាមួយក្រុមប្រឹក្សាឃុំ៖ ប្រធានមណ្ឌលសុខភាពគួរចូលរួមប្រជុំជាមួយក្រុមប្រឹក្សាឃុំសង្កាត់និងធ្វើការរួមគ្នាដើម្បីរៀបចំផែនការនិងការអនុវត្តយុទ្ធនាការផ្តល់ថ្នាំបង្ការថ្នាំបង្ការជំងឺកូវីដ-១៩ដោយជោគជ័យ។
- ការប្រើប្រាស់ផ្ទាំងបដានិងផ្ទាំងរូបភាព៖ NIP កណ្តាលនឹងបង្កើតបដានិងផ្ទាំងរូបភាពហើយចែកចាយដល់គ្រប់កម្រិត។ ប័ណ្ណប្រកាសនិងបដាទាំងនេះត្រូវបានបង្ហាញនៅតាមភូមិមុនថ្ងៃផ្តល់ថ្នាំបង្ការដើម្បីបញ្ជូនសារសំខាន់ៗទៅដល់ប្រជាជនចំណុច។
- ការប្រាស្រ័យទាក់ទងអន្តរបុគ្គល និងការប្រាស្រ័យទាក់ទងសង្គម៖ បុគ្គលិកសុខាភិបាល និងក្រុមទ្រទង់សុខភាពភូមិត្រូវជួបនិងជូនព័ត៌មានដល់សហគមន៍អំពីប្រជាជនចំណុចពេលវេលានិងបញ្ហាដែលពាក់ព័ន្ធផ្សេងទៀត
- ការផ្សព្វផ្សាយតាមឧបករណ៍បំពងសម្លេង៖ មួយថ្ងៃមុន និងនៅថ្ងៃផ្តល់ថ្នាំបង្ការ ការប្រកាសអំពីយុទ្ធនាការផ្តល់ថ្នាំបង្ការគួរតែត្រូវបានអនុវត្តដោយផ្សព្វផ្សាយតាមរយៈឧបករណ៍បំពងសម្លេង នៅក្នុងភូមិនីមួយៗ ដើម្បីលើកទឹកចិត្តប្រជាជនចំណុចឱ្យមកកន្លែងផ្តល់ថ្នាំបង្ការនៅក្នុងភូមិ ឬនៅមណ្ឌលសុខភាព។
- អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក៖ ក្នុងករណីដែលអាចធ្វើទៅបាន អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក ដែលធ្វើការផ្នែកសុខភាពគួរតែចូលរួមសម្រាប់ការកៀងគរសង្គម ក្នុងយុទ្ធនាការផ្តល់ថ្នាំបង្ការ។ យន្តការនេះគួរត្រូវបានសំរបសំរួលតាមរយៈ មន្ទីរសុខាភិបាល និង ស្រុកប្រតិបត្តិ ។

ត្រូវផ្តល់ជូនសាធារណៈជននូវព័ត៌មានត្រឹមត្រូវ ទាន់ពេលវេលាដើម្បីធានាថាសាធារណជនយល់ដឹងនិងគាំទ្រការផ្តល់ថ្នាំបង្ការជំងឺកូវីដ-១៩ ។ មន្ទីរសុខាភិបាល ស្រុកប្រតិបត្តិ និងមណ្ឌលសុខភាព ត្រូវរាយការណ៍ពីការយល់ឃើញអវិជ្ជមានចំពោះថ្នាំបង្ការនិងពាក្យចចាមអារ៉ាមដល់ថ្នាក់ជាតិ។ បុគ្គលិកមណ្ឌលសុខភាពនឹងជូនដំណឹងជាទៀងទាត់ដល់សហគមន៍អំពីថ្នាំបង្ការជំងឺកូវីដ-១៩ ពេលវេលាត្រូវផ្តល់ថ្នាំបង្ការនៅតាមទីតាំងនិមួយៗ។

អ្នកនាំពាក្យក្រសួងសុខាភិបាលនឹងជាអ្នកផ្តល់ព័ត៌មាន ដល់សារព័ត៌មាន និងសាធារណជន ជាប្រចាំរួមទាំងគោលនយោបាយសម្រាប់កំណត់ក្រុមអាទិភាពនានា ដោយផ្សព្វផ្សាយជាសាធារណៈ មុនយុទ្ធនាការផ្តល់ថ្នាំបង្ការនិងមាន

លក្ខណទូលាយ។ ក្នុងកំឡុងពេលយុទ្ធនាការផ្ដល់ថ្នាំបង្ការព័ត៌មាន ដែលទទួលបានពីគ្រប់កម្រិត ទាក់ទងនឹងការព្រួយបារម្ភ ករណីហេតុការណ៍មិនល្អដែលកើតមានក្រោយផ្ដល់ថ្នាំបង្ការ ដើម្បីផ្ដល់ជូនប្រព័ន្ធផ្សព្វផ្សាយនិងសាធារណជន។

បញ្ជាការដ្ឋានទទួលបន្ទុក ក្រុមការងារត្រៀមរៀបចំនិងអនុវត្តន៍គម្រោងផ្ដល់ថ្នាំបង្ការជំងឺកូវីដ-១៩ របស់ក្រសួងសុខាភិបាលនឹងធ្វើបទបង្ហាញ សង្ខេបដល់នាយកដ្ឋាននានានៃក្រសួងសុខាភិបាល ថ្នាក់ក្រោមជាតិ ដៃគូអ្នកពាក់ព័ន្ធដទៃទៀត អំពីផែនការសម្រាប់អនុវត្តការផ្ដល់ថ្នាំបង្ការជំងឺកូវីដ-១៩ ជាពិសេសផ្ដោតទៅលើគោលនយោបាយ ផែនការ និងសកម្មភាព។ ស្រដៀងគ្នានេះដែរគណៈកម្មាធិការអន្តរក្រសួងដើម្បីប្រយុទ្ធប្រឆាំងនឹង កូវីដ-១៩ នឹងធ្វើបទបង្ហាញសង្ខេបជូនក្រសួងទាំងអស់នៅក្នុងគណៈកម្មាធិការជាតិនេះ។ នៅចុងបញ្ចប់នៃយុទ្ធនាការអ្នកនាំពាក្យអ្នកនាំពាក្យ នៃបញ្ជាការដ្ឋានទទួលបន្ទុក សម្រាប់គ្រប់គ្រងនិងត្រួតពិនិត្យការផ្ដល់ថ្នាំបង្ការជំងឺកូវីដ-១៩ នឹងធ្វើសេចក្ដីរាយការណ៍សង្ខេប និងជាសារធារណៈស្ដីពីអត្រាគ្របដណ្ដប់ការផ្ដល់ថ្នាំបង្ការ និងករណីហេតុការណ៍មិនល្អដែលកើត មានក្រោយផ្ដល់ថ្នាំបង្ការ នៅក្នុងប្រទេស។

## ចំណុចគន្លឹះ

- សម្រាប់ការប្រាស្រ័យទាក់ទងតាមកម្រិតក្នុងប្រព័ន្ធសុខាភិបាល ប្រព័ន្ធផ្សព្វផ្សាយសង្គមដូចជា Telegram, Facebook-គឺជាជម្រើសល្អបំផុតព្ធ ដែលគេនឹងប្រើប្រព័ន្ធទំនាក់ទំនងសង្គមទំនាក់ទំនងទាំងនោះ។
- សេវាផ្ដល់ថ្នាំបង្ការជំងឺកូវីដ-១៩ ដល់ក្រុមអាទិភាពបីដំបូងក្នុងដំណាក់កាលទី ១ នឹងត្រូវធ្វើឡើងនៅមណ្ឌលសុខភាព និងនៅមន្ទីរពេទ្យ។ ក្រសួងសុខាភិបាលនឹងធ្វើលិខិតជូនក្រសួងនានា និងអ្នកពាក់ព័ន្ធទាំងអស់ ពីកាលបរិច្ឆេទ ពេលវេលា និងទីកន្លែងផ្ដល់ថ្នាំបង្ការជំងឺកូវីដ-១៩ ។
- ទោះយ៉ាងណា យុទ្ធនាការផ្ដល់ថ្នាំបង្ការនៅកន្លែង (មណ្ឌលសុខភាព និងមន្ទីរពេទ្យ) និងនៅតាមភូមិ សម្រាប់ដំណាក់កាលទី ២ នឹងត្រូវការខិតខំប្រឹងប្រែងជាខ្លាំង។
- មន្ទីរសុខាភិបាល ស្រុកប្រតិបត្តិ និងមណ្ឌលសុខភាព ត្រូវរាយការណ៍ពីការយល់ឃើញអំពីថ្នាំបង្ការពាក្យចចាមរាម មកល្ខាក់កណ្ដាល ។
- បុគ្គលិកមណ្ឌលសុខភាព នឹងជូនដំណឹងជាទៀងទាត់ដល់សហគមន៍អំពីថ្នាំបង្ការជំងឺកូវីដ-១៩ ទីកន្លែង និងពេលវេលាសម្រាប់លារផ្ដល់ថ្នាំបង្ការទៅតាមផែនការរបស់យុទ្ធនាការ។
- អ្នកនាំពាក្យក្រសួងសុខាភិបាលនឹងជាអ្នកផ្ដល់ព័ត៌មានដល់សារពត៌មាននិងសាធារណជន ជាប្រចាំ រួមទាំងគោលនយោបាយសម្រាប់កំណត់ក្រុមអាទិភាពនានា ដោយផ្សព្វផ្សាយជាសាធារណៈ រួមមានគោលនយោបាយប្រជាជនចំណុចជាអាទិភាព មុនពេលយុទ្ធនាការផ្ដល់ថ្នាំបង្ការនិងមានលក្ខណទូលាយ។

# ជំពូកទី ១២- ការតាមដាន និងវាយតម្លៃយុទ្ធនាការផ្តល់ ថ្នាំបង្ការ ជំងឺកូវីដ-១៩

ការតាមដានត្រូវធ្វើទៅតាមប្រព័ន្ធនិងជាប់ជាបន្តដើម្បីវាស់វែងវឌ្ឍនភាព កំណត់រកបញ្ហា បង្កើតដំណោះស្រាយ និងដឹកនាំគោលនយោបាយនិងកិច្ចអន្តរាគមន៍។ ការតាមដាន គឺជាសមាសធាតុសំខាន់សម្រាប់ យុទ្ធនាការផ្តល់ថ្នាំបង្ការ ការពារជំងឺកូវីដ-១៩ ហើយនឹងដើម្បីជួយលើកកម្ពស់ ការអនុវត្តប្រកបដោយគុណភាព។

កម្មវិធីជាតិផ្តល់ថ្នាំបង្ការ (NIP), មន្ទីរសុខាភិបាល (PHD) និងដៃគូទាំងអស់ ចូលរួមគាំទ្រដល់ ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ(OD) និងមណ្ឌលសុខភាពផងដែរ ក្នុងការរៀបចំ យុទ្ធនាការផ្តល់ថ្នាំបង្ការ និង សកម្មភាពអភិបាល ក្នុងកំឡុង ពេលជាមួយគ្នានោះ។ ដៃគូពាក់ព័ន្ធ នៅគ្រប់កម្រិតទាំងអស់ គួរតែចាត់ទុក យុទ្ធនាការ ផ្តល់ថ្នាំបង្ការការពារជំងឺកូវីដ១៩ មិនរារាំងដល់ការផ្តល់ថ្នាំបង្ការទូទៅទេ។

## ១២.១. អ្នកអភិបាលថ្នាក់ជាតិ ថ្នាក់ខេត្ត និងការិយាល័យប្រតិបត្តិ

ក្រុមអ្នកអភិបាលនឹងត្រូវបានជ្រើសរើសពីកម្មវិធីជាតិផ្តល់ថ្នាំបង្ការ ដៃគូនានា និងនាយកដ្ឋានសំខាន់ៗ ទៅតាមតម្រូវការ និងការកំណត់របស់ក្រសួងសុខាភិបាល កម្មវិធីជាតិផ្តល់ថ្នាំបង្ការថ្នាក់ខេត្ត និងថ្នាក់ស្រុកប្រតិបត្តិ។ មានក្រុមអ្នកអភិបាលបីប្រភេទ: **ក្រុមអ្នកអភិបាលបច្ចេកទេស ក្រុមអ្នកអភិបាលថ្នាក់ខេត្ត** និង **ក្រុមអ្នកអភិបាលក្រុមផ្តល់ថ្នាំបង្ការ** (សូមមើលជំពូក ៧ ផ្នែក ៧.៤.៣)។

<u>សម្រាប់ការផ្តល់ថ្នាំបង្ការ នៅមូលដ្ឋានសុខាភិបាលក្នុងដំណាក់កាលទី ១៖</u>

ក្រុមអ្នកអភិបាលមួយដែលមានសមាជិក ៥នាក់ នឹងត្រូវបង្កើតនៅតាមខេត្ត និងស្រុកប្រតិបត្តិនីមួយៗ ដើម្បីអភិបាល និងតាមដាន។ ហើយក្រុមនិមួយៗ នឹងចាត់តាំងទៅតាម មណ្ឌលសុខភាពឬមន្ទីរពេទ្យ។ ក្រុមអ្នកអភិបាលថ្នាក់ជាតិចំនួន ២៥នាក់ នឹងត្រូវបានបង្កើត និងចាត់តាំងទៅតាមមណ្ឌលសុខភាព ឬ មន្ទីរពេទ្យនៃស្រុកប្រតិបត្តិផ្សេងៗគ្នា។

<u>សម្រាប់យុទ្ធនាផ្តល់ថ្នាំបង្ការ នៅសេវាមូលដ្ឋាន និងនៅមូលដ្ឋានសុខាភិបាលក្នុងដំណាក់កាលទី ២៖</u>

នៅតាមការិយាល័យស្រុកប្រតិបត្តិនីមួយៗ នឹងមានក្រុមមួយដែលមានសមាជិក ១០ នាក់ សម្រាប់ ចុះអភិបាល និងតាមដាន ហើយ សមាជិកម្នាក់ៗ នឹងចាត់តាំងឱ្យកាន់មណ្ឌលសុខភាពមួយ ក្នុងកំឡុងពេលនៃយុទ្ធនាការផ្តល់ថ្នាំបង្កាការពារជំងឺកូវីដ ១៩ ។

ដូចគ្នានេះដែរ ក្រុមដែលមានសមាជិក ២៥ នាក់ នៅថ្នាក់ជាតិ និង ក្រុមដែលមានសមាជិក ១០ នាក់ នៅតាមបណ្តាខេត្តនិមួយៗ នឹងបង្កើតឡើង ដើម្បីអភិបាល និងតាមដាន នៅតាមមណ្ឌលសុខភាពកំឡុងពេលរៀបចំ និងអនុវត្តយុទ្ធនាការ។ អ្នកអភិបាលគ្រប់កម្រិត នឹងប្រើប្រាស់បញ្ជីផ្ទៀងផ្ទាត់ កំឡុងពេលយុទ្ធនាការ ផ្តល់ថ្នាំបង្ការនេះ។

#### ការវាយតម្លៃរហ័សការគ្របដណ្ដប់នៃការផ្ដល់ថ្នាំបង្ការកូវីដ-១៩

ការវាយតម្លៃរហ័សការគ្របដណ្ដប់នៃការផ្ដល់ថ្នាំបង្ការកូវីដ-១៩ មានវត្ថុបំណង៖

- ធានានាដល់ការទទួលថ្នាំបង្ការក្នុងចំណោមប្រជាជនចំណុច
- ប្រមូលព័ត៌មានទាក់ទងនឹងប្រភពព័ត៌មានដែលពួកគេបានទទួល
- យល់ដឹងពីហេតុផលដែលពួកគេមិនបានទទួលថ្នាំបង្ការ។

ក្នុងអំឡុងយុទ្ធនាការ អ្នកអភិបាលថ្នាក់ជាតិនិងថ្នាក់ខេត្តនឹងប្រើរបកគំហើញនៃការវាយតម្លៃរហ័ស ដើម្បីអនុវត្តសម្មភាពកែតម្រូវដែលចាំបាច់ ដើម្បីទទួលបានការគ្របដណ្តប់ខ្ពស់។ ការវាយតម្លៃរហ័សការគ្របដណ្តប់គួរត្រូវបានធ្វើបើការផ្តល់ថ្នាំបង្ការសម្រាប់ភូមិមួយត្រូវបានបញ្ចប់។

អ្នកអភិបាលដែលនឹងត្រូវធ្វើការវាយតម្លៃរហ័សការគ្របដណ្តប់គួរត្រូវបានបណ្តុះបណ្តាលសមស្រប។

- ការវាយតម្លៃរហ័សការគ្របដណ្តប់នៅសហគមន៍ តម្រូវឱ្យអ្នកវាយតម្លៃធ្វើដំណើរពីផ្ទះមួយទៅផ្ទះមួយ ដើម្បីរកប្រជាជនចំណុច ១០ នាក់ក្នុងមួយភូមិ។
- ការវាយតម្លៃរហ័សការគ្របដណ្តប់នៅស្ថាប័ន ក្រសួង-មន្ទីរ រោងចក្រ-សហគ្រាស ការដ្ឋាន មានលក្ខណៈដោយឡែក។ ការជ្រើសរើសដោយព្រាវអាចត្រូវបានធ្វើពីក្នុងបញ្ជីសម្រង់ប្រជាជនចំណុចសម្រាប់ការផ្តល់ថ្នាំបង្ការ ហើយការវាយតម្លៃតាមរយៈទូរស័ព្ទអាចត្រូវបានប្រើ។

សម្រាប់ប្រជាជនចំណុចដែលបានជ្រើសរើស សាកសួរពួកគេនូវសំណួរមួយចំនួនដូចជា៖

- ឈ្មោះ មុខរបរ លេខទូរស័ព្ទ
- តើអ្នកបានទទួលថ្នាំបង្ការជំងឺកូវីដ-១៩ ឬទេ?
- បើបានទទួល សួរពីប្រភពព័ត៌មានដែលគាត់បានទទួលអំពីថ្នាំបង្ការជំងឺកូវីដ-១៩។
- បើទេ សួរពីមូលហេតុដែលធ្វើឱ្យគាត់មិនបានទទួលថ្នាំបង្ការជំងឺកូវីដ-១៩។

អ្នកវាយតម្លៃរហ័សគួរលើកចិត្តដល់បុគ្គលដែលខកខានមិនបានទទួលថ្នាំបង្ការជំងឺកូវីដ-១៩ ឱ្យទៅទទួលនៅមូលដ្ឋានសុខាភិបាល ក្នុងអំឡុងពេលនៃយុទ្ធនាការផ្តល់ថ្នាំបង្ការជំងឺកូវីដ-១៩។

## ១២.២. ក្រុមអភិបាលក្នុងអំឡុងពេលយុទ្ធនាការដំណាក់កាលទី ២

អ្នកអភិបាលម្នាក់ ត្រូវគ្រប់គ្រង ៥ក្រុម។ អ្នកអភិបាលត្រូវចល័តដើម្បីត្រួតពិនិត្យគ្រប់ក្រុមទាំងអស់រៀងរាល់ថ្ងៃ (ពត៌មានលំអិតពីការទទួលខុសត្រូវ មានចែងក្នុងជំពូក យុទ្ធសាស្ត្រផ្តល់ថ្នាំបង្ការ) ។

## ១២.៣. ការគ្រប់គ្រងទិន្នន័យ

ការគ្រប់គ្រងទិន្នន័យនៅតែមានសារៈសំខាន់។ មណ្ឌលសុខភាពធ្វើការគ្រប់គ្រងទិន្នន័យផ្តល់ថ្នាំបង្ការ និង ធ្វើរបាយការណ៍ប្រចាំថ្ងៃ ដោយមានការជួយគាំទ្រ ពីការិយាល័យស្រុកប្រតិបត្តិ(OD) និងមន្ទីសុខាភិបាល (PHD) ។ បង្កើត

ឧបករណ៍សម្រាប់គ្រប់គ្រងទិន្នន័យមានដូចជាកាតចាក់ថ្នាំបង្ការ តារាងបូកសរុប បញ្ជីចុះឈ្មោះ និងរបាយការណ៍ នឹងត្រូវបានបង្កើត និង ដាក់ឱ្យប្រើប្រាស់ (ព័ត៌មានលម្អិតសូមមើលក្នុងជំពូកការកត់ត្រានិងរបាយការណ៍) ។

## ១២.៤. សូចនាករតាមដានយុទ្ធនាការ

1. ចំនួន ឬ សមាមាត្រប្រជាជនចំនុចដែលបានទទួលថ្នាំបង្ការដូសទី ១
2. ចំនួន ឬ សមាមាត្រប្រជាជនចំនុចដែលបានទទួលថ្នាំបង្ការដូសទី ២
3. ចំនួន ឬ សមាមាត្រប្រជាជនចំនុចដែលបានទទួលថ្នាំបង្ការដូសទី ១ តែមិនបានទទួលគ្រប់ដូស
4. ចំនួន ឬ សមាមាត្រប្រជាជនចំនុចដែលបានទទួលថ្នាំបង្ការគ្រប់ដូសទៅតាមខេត្ត-ស្រុកប្រតិបត្តិ
5. ចំនួន ឬ សមាមាត្រប្រជាជនចំនុចជាស្ត្រីដែលបានទទួលថ្នាំបង្ការគ្រប់ដូស

# ជំពូកទី ១៣- ហេតុការណ៍កើតក្រោយការផ្ដល់ថ្នាំបង្ការ

ថ្នាំបង្ការបង្ការជំងឺកូវីដ-១៩ គឺជាថ្នាំបង្ការដែលបង្កើតថ្មី ហើយមិនដែលប្រើចំពោះមនុស្សឡើយលើកលែងតែការធ្វើតេស្តសាកល្បងគ្លីនិក។ ថ្នាំបង្ការបង្ការជំងឺកូវីដ-១៩ គឺជាថ្នាំបង្ការដែលមានសុវត្ថិភាព។ គ្រុនក្តៅនិងកន្ទួលរមាស់...... បន្ទាប់ពីចាក់ថ្នាំបង្ការរួច។ ក្រុមការងារចាក់ថ្នាំបង្ការ និងអ្នកអភិបាលគួរតែធានាចំពោះការរកឱ្យឃើញ ការកត់ត្រាត្រឹមត្រូវ ការរាយការណ៍អំពីហេតុការណ៍កើតមានក្រោយផ្ដល់ថ្នាំបង្ការ និងណែនាំការព្យាបាលដល់អ្នកចម្ងឺ។ ថ្នាំបង្ការបង្ការជំងឺកូវីដ-១៩ ក៏ដូចថ្នាំបង្ការដទៃទៀតដែរ ដោយអាចបណ្តាលឱ្យ...... ហើយវាក៏កម្រមានប្រតិកម្មធ្ងន់ធ្ងរដែរ ... ។ ដូច្នេះការសង្កេតតាមដានរយៈពេល ១៥-៣០ នាទីបន្ទាប់ពីការចាក់ថ្នាំបង្ការបង្ការជំងឺកូវីដ-១៩ គឺការចាំបាច់ និងសំខាន់បំផុត។

## ១៣.១. និយមន័យនៃហេតុការណ៍កើតមានក្រោយផ្តល់ថ្នាំបង្ការ

ហេតុការណ៍កើតមានក្រោយផ្តល់ថ្នាំបង្ការ គឺជាហេតុការណ៍វេជ្ជសាស្ត្រណាមួយកើតឡើងបន្ទាប់ពីការផ្តល់ថ្នាំបង្ការ ដោយមូលហេតុរបស់វា អាចបណ្តាល ឬមិនបណ្តាល មកពីការប្រើប្រាស់ថ្នាំបង្ការ។ ហេតុការណ៍នេះអាចស្ដែង ចេញក្រោមរូបភាពជារោគសញ្ញាមិនប្រក្រតីទាំងឡាយណាដែលបង្កការរំខានដល់អ្នកជំងឺ ជាលទ្ធផលមន្ទីរពិសោធន៍រកឃើញមិនប្រក្រតី ជាចង្កោមរោគសញ្ញា ឬជំងឺ។

បុគ្គលិកសុខាភិបាលត្រូវតែត្រៀមលក្ខណៈជាស្រេចក្នុងការផ្តល់សេវាថែទាំ ព្យាបាលឬបញ្ជូនសង្គ្រោះ ហេតុការណ៍កើតមានក្រោយផ្តល់ថ្នាំបង្ការ ដូចជាប្រតិកម្មថ្នាំបង្ការ (anaphylaxis) កំឡុងពេលផ្តល់សេវាថ្នាំបង្ការ តាមតាមស្ថាប័ណ្ឌសុខាភិបាល និងមូលដ្ឋាន។ មន្ទីរពេទ្យខេត្ត និងមន្ទីរពេទ្យបង្អែកស្រុកត្រូវមានឧបករណ៍ សម្រាប់គ្រប់គ្រងការសង្គ្រោះបន្ទាន់ និងត្រៀមរៀបចំជាស្រេចឱ្យមានរថយន្តសង្គ្រោះបន្ទាន់ដាក់ប្រចាំការ។ ស្របពេលនេះដែរ មណ្ឌលសុខភាពដែលមានរថយន្តសង្គ្រោះបន្ទាន់ក៏ត្រូវត្រៀមជាស្រេចដែរ។

## ១៣.២. ការរាយការណ៍អំពីហេតុការណ៍មិនល្អកើតមានក្រោយផ្តល់ថ្នាំបង្ការ

ហេតុការណ៍កើតមានក្រោយផ្តល់ថ្នាំបង្ការគួរតែត្រូវរាយការណ៍តាមគោលការថ្នាក់ជាតិ ហើយក្នុងករណីធ្ងន់ធ្ងរណាមួយ បុគ្គលិកសុខាភិបាលត្រូវតែរាយការណ៍ជាបន្ទាន់ទៅប្រធានស្រុកប្រតិបត្តិតាមទូរស័ព្ទចល័តភ្លាមៗបន្ទាប់ពីបានរកឃើញ។

សូមរាយការណ៍ហេតុការណ៍កើតមានក្រោយផ្តល់ថ្នាំបង្ការនៅពេលរកឃើញដូចតទៅៈ

១. រាល់ករណីធ្ងន់ធ្ងរកើតមានក្រោយផ្តល់ថ្នាំបង្ការ (AEFI)
- ហេតុការណ៍ដែលគម្រាមកំហែងដល់អាយុជីវិត ឬឈានដល់បាត់បង់ជីវិត ការសម្រាកនៅមន្ទីរពេទ្យ ការអាចធ្វើឱ្យពិការភាពធ្ងន់ធ្ងរ ឬការអាចធ្វើឱ្យជំងឺពីកំណើតមានភាពធ្ងន់ធ្ងរ។

២. ករណីមានប្រតិកម្មដោយមិនបានដឹងជាមុន (សញ្ញា)

៣. ហេតុការណ៍កើតមានក្រោយផ្តល់ថ្នាំបង្ការកើតមានជាក្រុម (រួមទាំងករណីស្រាល)

៤. រាល់ហេតុការណាដែលធ្វើឱ្យសហគមន៍មានការបារម្ភខ្លាំង

៥. បញ្ហាដែលកើតមានក្រោយផ្តល់ថ្នាំបង្ការស្រាលមាន៖ ហើម, កន្ទួល, ឈឺនៅកន្លែងចាក់ថ្នាំបង្ការ ប្រសិនបើវាមានរយៈពេលលើសពី៣ថ្ងៃ ឬមានហើមរីករាលដាលទៅតំបន់ម្ខាងទៀតនៃសន្លាក់នៅជិតបំផុត។

ខេត្តនិមួយៗត្រូវបង្កើតគណៈកម្មាធិការគ្រប់គ្រងហេតុការណ៍កើតមានក្រោយផ្តល់ថ្នាំបង្ការ សម្រាប់គ្រប់គ្រងករណីហេតុការណ៍កើតមានក្រោយផ្តល់ថ្នាំបង្ការ។ ខេត្តនិមួយៗក៏នឹងបង្កើតក្រុមបច្ចេកទេសខេត្តសម្រាប់ការស៊ើបអង្កេតលើករណីហេតុការណ៍កើតមានក្រោយផ្តល់ថ្នាំបង្ការ។ ការរាយការណ៍ទៅថ្នាក់លើ និងស៊ើបអង្កេតករណីហេតុការណ៍កើតមានក្រោយផ្តល់ថ្នាំបង្ការក្នុងកំឡុងពេលផ្តល់សេវា/យុទ្ធនាការចាក់ថ្នាំបង្ការបង្ការជំងឺកូវីដ-១៩ បុគ្គលិកសុខាភិបាលនឹងប្រើទម្រង់ការស៊ើបអង្កេតករណីហេតុការណ៍កើតមានក្រោយផ្តល់ថ្នាំបង្ការនិងទម្រង់រាយការណ៍ករណីជាប្រចាំ។

## ១៣.៣. សមាសភាពនៃគណៈកម្មាធិការខេត្តដើម្បីគ្រប់គ្រងហេតុការណ៍មិនល្អកើត មានក្រោយផ្តល់ថ្នាំបង្ការ

ខាងក្រោមនេះគឺជាសមាជិកភាពនៃគណៈកម្មាធិការខេត្តដើម្បីគ្រប់គ្រងហេតុការណ៍កើតមានក្រោយផ្តល់ថ្នាំបង្ការ

- អភិបាលខេត្ត ជាប្រធាន
- ស្នងការខេត្ត ជាអនុប្រធាន
- តុលាការ/ព្រះរាជអជ្ញាខេត្តជាសមាជិក
- ប្រធានមន្ទីរសុខាភិបាល ជាលេខាធិការ
- ប្រធានមន្ទីរពេទ្យខេត្ត ជាសមាជិក
- អភិបាលក្រុង/ស្រុក/ខណ្ឌ ជាសមាជិក
- ប្រធានកម្មវិធីខេត្តសម្រាប់ថ្នាំបង្ការ ជាសមាជិក
- សមាជិកផ្សេងទៀតតាមការចាំបាច់

## ១៣.៤. សមាសភាពនៃក្រុមបច្ចេកទេសខេត្តដើម្បីស៊ើបអង្កេតករណី ហេតុការណ៍កើតមានក្រោយផ្តល់ថ្នាំបង្ការ

ខាងក្រោមនេះគឺជាសមាជិកភាពនៃក្រុមបច្ចេកទេសខេត្តដើម្បីស៊ើបអង្កេតករណីហេតុការណ៍កើតមានក្រោយផ្តល់ថ្នាំបង្ការ

- ប្រធានមន្ទីរសុខាភិបលខេត្ត
- ប្រធានកម្មវិធីផ្តល់ថ្នាំបង្ការខេត្ត
- ប្រធានមន្ទីរពេទ្យខេត្ត
- ប្រធានការិយាល័យត្រួតពិនិត្យនិងបង្ការជំងឺ ខេត្ត
- វេជ្ជបណ្ឌិតនៃមន្ទីរពេទ្យខេត្ត
- អ្នកជំនាញមន្ទីរពិសោធន៍ នៃមន្ទីរពេទ្យខេត្ត
- ប្រធានការិយាល័យស្រុកប្រតិបត្តិ
- ប្រធានមណ្ឌលសុខភាព
- អាជ្ញាធរមូលដ្ឋាន

- សមាជិកផ្សេងទៀតតាមការចាំបាច់

ប្រទេសកម្ពុជានឹងអនុវត្តទាំងប្រព័ន្ធឃ្លាំមើលសកម្ម និងអកម្មក្នុងអំឡុងពេលយុទ្ធនាការ/ផ្តល់សេវាចាក់ថ្នាំបង្ការ បង្ការជំងឺកូវីដ-១៩ ហើយភ្លាមៗបន្ទាប់ពីនោះគឺអាចរកឃើញ និងវិភាគទិន្នន័យបន្ថែមទៀត។ កម្មវិធីជាតិផ្តល់ថ្នាំបង្ការ និង នាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខាពេទ្យ និងគ្រឿងសម្អាង នឹងធ្វើការរួមគ្នាសម្រាប់ធ្វើការឃ្លាំមើលយ៉ាងសកម្មនៅតាម មន្ទីរពេទ្យ មណ្ឌលសុខភាព និងសហគមន៍ជាទៀងទាត់ក្នុងកំឡុងពេលផ្តល់សេវា /យុទ្ធនាការចាក់ថ្នាំបង្ការនិងរហូតដល់ ៤ សប្តាហ៍បន្ទាប់ពីផ្តល់សេវា/ យុទ្ធនាការចាក់ថ្នាំបង្ការ។

សម្ភារៈសង្គ្រោះបន្ទាន់សម្រាប់ហេតុការណ៍កើតមានក្រោយផ្តល់ថ្នាំបង្ការ ត្រូវការរៀបចំឱ្យមានក្នុងកំឡុងពេលផ្តល់សេវាចាក់ថ្នាំនៅ មណ្ឌលសុខភាព/មន្ទីរពេទ្យបង្អែក។ មន្ទីរសុខាភិបាលខេត្ត និងស្រុកប្រតិបត្តិនិមួយត្រូវសម្របសម្រួល យ៉ាងជិតស្និទ្ធ រួមទាំងការចេញលិខិតទៅមន្ទីរពេទ្យបង្អែកខេត្ត និងមន្ទីរពេទ្យបង្អែករៀងៗខ្លួនក្នុងករណីមានការសង្គ្រោះបន្ទាន់។ ក្រុមការងារចាក់ថ្នាំបង្ការនីមួយៗគួរតែមានសេរ៉ូ Promethazine សម្រាប់រក្សាទុកជាមួយក្នុងកំឡុងពេលយុទ្ធនាការថ្នាំបង្ការនៅមូលដ្ឋាន។

## ១៣.៥. សម្ភារបរិក្ខាសម្រាប់កញ្ចប់ឃីត ហេតុការណ៍កើតមានក្រោយផ្តល់ថ្នាំបង្ការ:

### សម្ភារបរិក្ខាដែលចាំបាច់ត្រូវតែមាន៖

១ថ្នាំ . Adrenaline* អំពូលប្រភេទមួយ (១: ១០០០ ក្នុង ១ម.១ម = ល.ក្រល.ម/)

២ថ្នាំ . Adrenaline* អំពូលប្រភេទពីរ (១: ១០០០០ .១ម=ក្រ.១០ម/ល)

៣សំឡីអាល់កុលសម្រាប់ជូត .២សន្លឹក

៤ល.ស៊ីរាំង ១ ម .ចំនួន២

៥ម្ជុល លេខ១៨ ឬ ១៩ក្រ .ចំនួន២

៦ ម្ជុល លេខ .២៣ក្រ x ៣២មម ចំនួន២

៧. តារាងណែនាំកម្រិតប្រើថ្នាំ Adrenaline (ឬថ្នាំ Epinephrine)

### សម្ភារបរិក្ខាបន្ថែម៖

៨. ថ្នាំAntihistamines

៩. ថ្នាំSteroids

១០. សេរ៉ូម Dextrose (50%) ampules

១១. សេរ៉ូម Normal Saline

១២. ឧបករណ៍សង្គ្រោះដង្ហើម

១៣. ម៉ាសមុខ

១៤. ស្តេតូ និង ប្រដាប់វាស់សម្ពាធឈាម

១៥. ប្រដាប់សង្កត់អណ្តាតកន្ត្រៃ/

១៦. ខ្សែបង្ហូសេរ៉ូម (e.g., ខ្សែចងរកសរសៃចាក់សេរ៉ូម(tourniquet)

១៧. ខ្យល់អុកស៊ីហ្សែន និងឧបករណ៍ដែលពាក់ព័ន្ធ

សម្រាប់ការគ្រប់គ្រងប្រតិកម្មថ្នាំ (anaphylaxis) ត្រូវមានទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព ការគ្រប់គ្រងវិបត្តិ និងសម្រាប់បញ្ហានានា សូមប្រើ គោលការណ៍ណែនាំប្រតិបត្តិសម្រាប់ការឃ្លាំមើល " ហេតុការណ៍កើតមានក្រោយផ្តល់ថ្នាំបង្ការ "។

ដើម្បីទទួលបានការគាំទ្រលើរបាយការណ៍ហេតុការណ៍កើតមានក្រោយផ្តល់ថ្នាំបង្ការ ពីកម្មវិធីជាតិផ្តល់ថ្នាំបង្ការ សូមធ្វើការទំនាក់ទំនងជាមួយវេជ្ជបណ្ឌិត យុង វុឌ្ឍីកុល អនុប្រធានកម្មវិធីជាតិផ្តល់ថ្នាំបង្ការ។

## ១៣.៦. ការវាយតម្លៃមូលហេតុ

ក្រសួងសុខាភិបាលបានបង្កើត" គណៈកម្មាធិការប្រឹក្សាជំនាញសុវត្ថិភាពឱសថ" នឹងពិនិត្យឡើងវិញនូវរបាយការណ៍ស៊ើបអង្កេត និងឯកសារដទៃទៀតដើម្បីធ្វើការវាយតម្លៃលក្ខណៈជាប្រព័ន្ធនូវព័ត៌មានអំពីករណីហេតុការណ៍កើតមានក្រោយផ្តល់ថ្នាំបង្ការ ដើម្បីកំណត់មូលហេតុនៃការផ្សារភ្ជាប់គ្នារវាងហេតុការណ៍មិនល្អ និងថ្នាំបង្ការដែលបានទទួល។

### ករណី AEFI ខាងក្រោមនេះដែលបានផ្តល់អនុសាសន៍ក្នុងការរៀបចំកមូលហេតុ

- ករណីហេតុការណ៍កើតមានក្រោយផ្តល់ថ្នាំបង្ការធ្ងន់ធ្ងរដូចក្នុងនិយមន័យ (ហេតុការណ៍ដែលគម្រាមកំហែងដល់អាយុជីវិតឬ ស្លាប់ ការចូលសម្រាកមន្ទីរពេទ្យ ពិការភាពធ្ងន់ធ្ងរ ឬភាពខុសធម្មតាពីកំណើត)។
- ហេតុការណ៍ជាចង្កោមដែលលើសពីការគិតទុក ឬធ្ងន់ធ្ងរជាងការគិតើ
- សញ្ញា៖ សញ្ញាដែលបង្កើតឡើងដោយករណីបុគ្គលម្នាក់ៗ ឬជាចង្កោមក្រុមដែលអាចប៉ះពាល់ដល់សុខភាពសាធារណៈយ៉ាងធ្ងន់ធ្ងរ ។
- ហេតុការណ៍ចម្លងៗដែលមិនបានពន្យល់ដែលបង្កឱ្យកើតឡើងបន្ទាប់ពី៣០ថ្ងៃនៃការចាក់ថ្នាំបង្ការ (និងមិនបានបញ្ជាក់នៅក្នុងស្លាកសញ្ញាផលិតផល) និង
- ហេតុការណ៍ដែលបង្កឱ្យមានការព្រួយបារម្ភណ៍ដល់ឪពុកម្តាយ ឬសហគមន៍។

### ចំណុចគន្លឹះ៖

- ថ្នាំបង្ការជំងឺកូវីដ-១៩ ជាថ្នាំបង្ការថ្មី។ វាមានសារៈសំខាន់ណាស់ក្នុងការទទួលការបណ្តុះបណ្តាលគ្រប់គ្រាន់ពីថ្នាក់ជាតិដល់មណ្ឌលសុខភាព។ បុគ្គលិកសុខាភិបាលទាំងអស់ត្រូវដឹងពីរបៀបស្វែងរក រាយការណ៍ និងស៊ើបអង្កេត។
- មន្ទីរសុខាភិបាលខេត្តនិមួយៗនឹងបង្កើតជាក្រុមបច្ចេកទេសស៊ើបអង្កេត និងគណៈកម្មាធិការគ្រប់គ្រង (សូមមើលខាងលើ) ដើម្បីទទួលខុសត្រូវចំពោះការស៊ើបអង្កេត និងការគ្រប់គ្រងករណីហេតុការណ៍កើតមានក្រោយផ្តល់ថ្នាំបង្ការណាមួយដែលបានរាយការណ៍។
- មន្ទីរពេទ្យខេត្ត និងមន្ទីរពេទ្យបង្អែកនឹងធានាឱ្យបាននូវឃីតសង្គ្រោះបន្ទាន់ និងត្រៀមសង្គ្រោះ
- គ្រប់មន្ទីរពេទ្យខេត្ត មន្ទីរពេទ្យបង្អែកស្រុក និងមណ្ឌលសុខភាពដែលមានរថយន្តសង្គ្រោះបន្ទាន់ត្រូវត្រៀមជាប្រចាំសម្រាប់ការបញ្ជូនបន្ត
- រាល់ករណីហេតុការណ៍កើតមានក្រោយផ្តល់ថ្នាំបង្ការធ្ងន់ធ្ងរ និងករណីផ្សេងទៀតដែលមានរៀបរាប់(ដូចខាងលើ) នឹងបញ្ជូនសម្រាប់ការវាយតម្លៃអំពីហេតុផលនៅថ្នាក់ជាតិ ដែលនឹងត្រូវត្រួតពិនិត្យដោយគណៈកម្មាធិការជំនាញ។

- មន្ត្រីកម្មវិធីជាតិផ្តល់ថ្នាំបង្ការ និងនាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខាពេទ្យ និងគ្រឿងសម្អាងគ្រប់ជាន់ថ្នាក់នឹងធ្វើការស្រាវជ្រាវករណីសកម្មនៅតាមមន្ទីរពេទ្យ/ មណ្ឌលសុខភាព/ សហគមន៍ជាប្រចាំក្នុងកំឡុងពេលផ្តល់សេវា/យុទ្ធនាការចាក់ថ្នាំបង្ការ និងរហូតដល់៤សប្តាហ៍បន្ទាប់ពីផ្តល់សេវា/យុទ្ធនាការផ្តល់ថ្នាំបង្ការ។
- ឱសថសារវន្តចាំបាច់សម្រាប់គ្រប់គ្រងករណីហេតុការណ៍កើតមានក្រោយផ្តល់ថ្នាំបង្ការត្រូវតែត្រៀមឱ្យមានជាស្រេចមុនពេលផ្តល់សេវា/យុទ្ធនាការថ្នាំបង្ការ
- ឱសថទាំងឡាយនឹងត្រូវរក្សាទុកមន្ទីរពេទ្យខេត្ត/មន្ទីរពេទ្យបង្អែកស្រុកប្រតិបត្តិ/មណ្ឌលសុខភាព និងឱសថចាំបាច់មួយចំនួនទៀតដែលត្រូវរក្សាទុកជាមួយក្រុមការងារចាក់ថ្នាំបង្ការ។

# ជំពូកទី ១៤ - ការបញ្ចប់យុទ្ធនាការផ្តល់ថ្នាំបង្ការជំងឺកូវីដ-១៩

ការវាយតម្លៃនឹងត្រូវបានធ្វើឡើងហើយរបាយការណ៍ស្តីពីការផ្តល់ថ្នាំបង្ការជំងឺកូវីដ-១៩ នឹងត្រូវបានរៀបចំឡើងនៅពេលយុទ្ធនាការផ្តល់ថ្នាំបង្ការបានបញ្ចប់។ នៅក្នុងរបាយការណ៍នោះ មេរៀនដែលបានជួបប្រទះ ចំណុចខ្លាំងនិងចំណុចខ្សោយ តាមជំពូកនីមួយៗនឹងត្រូវបានរាប់ រួមមានរបាយការណ៍អត្រាគ្របដណ្តប់ តាមក្រុមប្រជាជនចំណុចអាទិភាព ព្រមទាំង ធនធានដែលបានប្រើ និង មិនត្រូវបានប្រើ ធនធានមនុស្ស ធនធានហិរញ្ញវត្ថុ ថ្នាំបង្ការនិងសម្ភារៈចាំបាច់ ឧបករណ៍ប្រព័ន្ធត្រជាក់និងការគ្រប់គ្រងកាកសំណល់។ របាយការណ៍នេះនឹងមានប្រយោជន៍សម្រាប់យុទ្ធនាការ ផ្តល់ថ្នាំបង្ការនាពេលអនាគត។ កម្មវិធីជាតិផ្តល់ថ្នាំបង្ការ នឹងទទួលខុសត្រូវក្នុងការរៀបចំរបាយការណ៍ដោយមានការគាំទ្រពីភាគីពាក់ព័ន្ធ។

រាល់ថ្នាំបង្ការនិងហិរញ្ញវត្ថុដែលមិនបានប្រើប្រាស់ទាំងអស់នឹងត្រូវប្រគល់ជូនទៅថ្នាក់ជាតិវិញ។

ក្រុមការងារត្រៀមរៀបចំនិងអនុវត្តន៍គម្រោងផ្តល់ថ្នាំបង្ការ កូវីដ-១៩ របស់ក្រសួងសុខាភិបាលនឹងប្រកាសបញ្ចប់ ការផ្តល់ថ្នាំបង្ការជំងឺកូវីដ-១៩ នៅពេលរាល់ប្រតិបត្តិការនិងការវាយតម្លៃត្រូវបានបញ្ចប់។

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធ ទី១៖ បញ្ជីចុះឈ្មោះអតិថិជន

## ថ្នាំបង្ការជំងឺកូវីដ-១៩- បញ្ជីចុះឈ្មោះអតិថិជន

ខេត្ត៖............................ ស្រុក/ខណ្ឌ៖............................ ឃុំ/សង្កាត់៖............................ ភូមិ៖............................

ការិយាល័យស្រុកប្រតិបត្តិ៖............................ មណ្ឌលសុខភាព៖............................ ឈ្មោះស្ថាប័ន៖............................

ឈ្មោះអ្នកកត់ត្រា៖............................ លេខទូរស័ព្ទ៖............................

| ល.រ | លេខកាត | ឈ្មោះអតិថិជន | ភេទ | អាយុ | ថ្ងៃ/ខែ/ឆ្នាំ កំណើត | លេខទូរសព្ទ | មុខរបរ | ថ្ងៃ/ខែ/ឆ្នាំ និង ទីកន្លែងទទួលថ្នាំបង្ការ | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | ចាក់លើកទី១ | កន្លែងទទួលថ្នាំបង្ការ | ចាក់លើកទី២ | កន្លែងទទួលថ្នាំបង្ការ |
| | | | | | ....../....../....... | | | ....../....../....... | | ....../....../....... | |
| | | | | | ....../....../....... | | | ....../....../....... | | ....../....../....... | |
| | | | | | ....../....../....... | | | ....../....../....... | | ....../....../....... | |
| | | | | | ....../....../....... | | | ....../....../....... | | ....../....../....... | |
| | | | | | ....../....../....... | | | ....../....../....... | | ....../....../....... | |
| | | | | | ....../....../....... | | | ....../....../....... | | ....../....../....... | |
| | | | | | ....../....../....... | | | ....../....../....... | | ....../....../....... | |
| | | | | | ....../....../....... | | | ....../....../....... | | ....../....../....... | |
